ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# លើសំណើសុំឲ្យដោះលែង "នួន ជា, អៀង ធីរិទ្ធ និង ខៀវ សំផន" ជាបន្ទាន់
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ

**ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១**

**ម៉ោង ០៩:៣២ នាទី**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

លោកស្រីចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន

*(Judge Jean-Marc Lavegne)*

ចៅក្រម ធូ មណី

ចៅក្រម យូរ ឧត្តរា

លោកស្រីចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក លឹម ស៊ុយហុង

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាតាចា វីស៊ែល រីសឺ

*(Ms. Natacha Wexels-Riser)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក អាន់ឌ្រូ ខេលៃ *(Mr. Andrew CAYLEY)*

លោក សេង ប៊ុនឃាង

លោកស្រី កូលីន ហ្គីល *(Mr. Collen GILG)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោកស្រី អៀង ធីរិទ្ធ

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ *(Mr. Jasper Pauw)*

លោក ផាត់ ពៅស៊ាង

លោក ខាន់ សិរីវុទ្ធី

លោក ស សូវាន

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូ ហ្វត

*(Ms. Elizabeth SIMONNEAU FORT)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោកស្រី ជា លាង | ខ្មែរ |
| លោក អាន់ឌ្រូ ខៀលៃ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ហ្សាស្តេី ប៉ៅ | អង់គ្លេស |
| លោក ផាត់ ពៅសឺាង | ខ្មែរ |
| លោក ស សូវាន | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក អៀង ធីរិទ្ធ | ខ្មែរ |
| លោក ខៀវ សំផន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:៣១:៥០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអស់លោក លោកស្រីអង្គុយចុះ!

ថ្ងៃនេះ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានសមាសភាពចៅក្រមដូចខាងក្រោម៖

មួយ គឺរូបយើង និល ណុន ជាប្រធាន, ពីរ ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍, បី ចៅក្រម យ៉ា សុខន, បួន ចៅក្រម ហ្សង់ម៉ាក ឡាវែន៍, ប្រាំ ចៅក្រម ធូ មណី និងចៅក្រមបម្រុងចំនួនពីររូបគឺ៖ មួយ ចៅក្រម យូរ ឧត្តរា, ពីរ ចៅក្រម ក្លូឌា ហ្វេនស៍។

ប្រកាសបើកសវនាការជាសាធារណៈដើម្បីពិភាក្សាដេញដោលលើសំណើសុំចំនួនបី។ សំណើសុំរបស់មេធាវីការពារក្តីឱ្យលោក នួន ជា ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ ដែលបានស្នើសុំឱ្យអង្គជំនុំជម្រះដោះលែងជនជាប់ចោទឈ្មោះ នួន ជា ជាបន្ទាន់។

ពីរ សំណើសុំរបស់មេធាវីការពារក្តីឱ្យលោក ខៀវ សំផន ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ ២០១១ ដែលបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងដោះលែងជនជាប់ចោទឈ្មោះ ខៀវ សំផន ឱ្យមានសេរីភាពដោយយោងតាមវិធាន៨២(៣) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

បី សំណើសុំរបស់មេធាវីការពារក្តីឱ្យលោកស្រី អៀង ធីរិទ្ធ ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០១១ ដែលបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងដោះលែងជនជាប់ចោទឈ្មោះ អៀង ធីរិទ្ធ ជាបន្ទាន់។

ផ្អែកតាមសំណុំរឿងអង្គសេចក្តីលេខ០០២ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧/អវតក ជនជាប់ចោទឈ្មោះ នួន ជា ភេទប្រុស កើតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៦ (ស៊ីក) ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ននៅមន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះសាលាដំបូងវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧។

ជនជាប់ចោទ ឈ្មោះ ខៀវ សំផន ភេទប្រុស កើតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៣១ ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ននៅមន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧។

[០៩:៣៥:២៥]

និងឈ្មោះ អៀង ធីរិទ្ធ ភេទស្រី កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៣២ ត្រូវបានឃុំខ្លួនជាបណ្ដោះអាសន្ននៅមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧។

ជនជាប់ចោទទាំងបីនាក់នេះ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកក្រុម ចាម និង វៀតណាម។ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

ក្រឡាបញ្ជី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានអ្នកដែលត្រូវបានអញ្ជើញចូលរួមនៅក្នុងសវនាការសម្រាប់ថ្ងៃនេះ។ សូមអញ្ជើញ!

[០៩:៣៦:៣១]

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន, អ្នកដែលត្រូវបានចូលរួមនៅក្នុងសវនាការថ្ងៃនេះមានវត្តមាន និងអវត្តមានដូចតទៅ៖

សហព្រះរាជអាជ្ញា មានវត្តមានគ្រប់ចំនួន។

ជនជាប់ចោទ លោក នួន ជា, លោក ខៀវ សំផន និង លោកស្រី អៀង ធីរិទ្ធ មានវត្តមាន។

មេធាវីការពារឲ្យជនជាប់ចោទ លោក នួន ជា មានវត្តមានមេធាវីជាតិ លោក សុន អរុណ ប៉ុន្តែអវត្តមានមេធាវីអន្តរជាតិ លោក លោក មីសែល ផេសមេន និងលោក វ៉ិចទ័រ កូប៉េ ដោយមូលហេតុមិនអាចចូលរួមបាន។

មេធាវីការពារឲ្យជនជាប់ចោទ លោក ខៀវ សំផន មេធាវីជាតិលោក ស សូវាន អវត្តមាននៅពេលនេះ ប៉ុន្តែលោកបានជូនដំណឹងថា នឹងអញ្ជើញមកយឺតនៅចន្លោះម៉ោងដប់ ឬ ដប់សាមសិបនាទី និង អវត្តមានមេធាវីអន្តរជាតិលោក ហ្សាក់ វែកហ្សេស និង ហ្វីលីព ហ្គ្រេស្យាណូ ដោយមូលហេតុមិនអាចចូលរួមបាន។

មេធាវីការពារឲ្យជនជាប់ចោទ លោកស្រី អៀង ធីរិទ្ធ មានវត្តមាន។ មេធាវីជាតិ លោក ផាត់ ពៅស៊ាង ប៉ុន្តែអវត្តមានមេធាវីអន្តរជាតិ លោកស្រី ដាយអាណា អេលីល ដោយមូលហេតុមិនអាចចូលរួមបាន។

[០៩:៣៧:៣៧]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី សែ កុលវុឌ្ឍី។ ស្ថានភាពវត្តមាន និងអវត្តមានភាគីដែលត្រូវបានអញ្ជើញចូលរួមនៅក្នុងសវនាការនេះត្រូវកត់ត្រាចូលនៅក្នុងប្រតិចារឹក។

នៅក្នុងសវនាការព្រឹកនេះអង្គជំនុំជម្រះនឹងស្តាប់សេចក្តីថ្លែងការណ៍របស់ភាគីទាក់ទងទៅនឹងសំណើសុំទាំងបីខាងលើនេះ គឺសុំឲ្យដោះលែងជនជាប់ចោទជាបន្ទាន់។ ក្រុមមេធាវីការពារក្តីនីមួយៗនឹងមានរយៈពេល៣០នាទី ដើម្បីធ្វើសេចក្តីថ្លែងការណ៍ពាក់ព័ន្ធទៅនឹងសំណើសុំរបស់ខ្លួន។ សហព្រះរាជអាជ្ញានឹងមានរយៈពេល៦០នាទីដើម្បីឆ្លើយតបទៅនឹងសំណួរទាំងនោះ។ បន្ទាប់មកក្រុមមេធាវីការពារក្តីជនជាប់ចោទនីមួយៗនឹងមានរយៈពេល១០នាទីដើម្បីឆ្លើយតប។

[០៩:៣៨:៣៧]

មុននឹងចាប់ផ្តើមកិច្ចដំណើរការពិភាក្សា អង្គជំនុំជម្រះសាលាដំបូងសូមរំឭកដល់ភាគីដើម្បីឲ្យដំណើរការសវនាការពិភាក្សាដេញដោលប្រព្រឹត្តទៅបានត្រឹមត្រូវ ច្បាស់លាស់ល្អ គប្បីចងចាំនិងអនុវត្តឲ្យបានល្អនូវសំណើរបស់អង្គភាពបកប្រែភាសា ដើម្បីធានាដល់ការធ្វើប្រតិចារឹកនៃដំណើរការនីតិវិធីដូចខាងក្រោមនេះ៖

ភាគីគប្បីចងចាំថា អង្គជំនុំជម្រះសាលាដំបូងជាតុលាការដែលប្រើប្រាស់ភាសាបី បីភាសា និងមានចម្រុះវប្បធម៌។ ដូច្នេះ គប្បីឡើងធ្វើសេចក្តីថ្លែងការណ៍ប្តឹងសុំ ឬសេចក្តីថ្លែងការណ៍តបគប្បីនិយាយឲ្យបានយឺតៗ ហើយច្បាស់។

ភាគីគប្បីអាននូវតួលេខ ឬកាលបរិច្ឆេទឲ្យបានយឺតៗហើយច្បាស់ ប្រសិនបើអាចធ្វើបានស្នើសុំបញ្ជាក់ឡើងវិញម្តងទៀត។

ភាគីត្រូវប្រកបឈ្មោះទាំងឡាយដែលមានអក្ខរាវិរុទ្ធច្រើន និងឬពិបាកសរសេរ។

ភាគីត្រូវបានបើកកុងតាក់មីក្រូហ្វូនជាមុនសិនមុននឹងចាប់ផ្តើមនិយាយ ហើយនិងនិយាយឲ្យចំក្បាលមីក្រូហ្វូន។

[០៩:៣៩:៥៧]

ករណីភាគីចាប់ផ្តើមនិយាយហើយ ទើបបានដឹងថាមិនទាន់បើកុងតាក់មីក្រូហ្វូន សុំបើកកុងតាក់មីក្រូហ្វូន ហើយចាប់ផ្តើមនិយាយសាជាថ្មីឡើងវិញម្តងទៀត នូវចំណុចទាំងឡាយណាដែលខ្លួនបាន

និយាយដោយមិនបានចុចកុងតាក់បើកក្បាលមីក្រូហ្វូន ពីព្រោះអ្នកបកប្រែមិនអាចចាប់ផ្ដើមបកប្រែភាសាពាក់កណ្ដាលប្រយោគបានទេ។

ប្រសិនបើមានការនិយាយឆ្លើយឆ្លងគ្នារវាងភាគីដែលនិយាយភាសាតែមួយ ភាគីម្ខាងទៀតត្រូវចងចាំភាគី-- ត្រូវរង់ចាំភាគីម្ខាងដែលបាននិងកំពុងតែនិយាយបញ្ចប់នូវការនិយាយរបស់គាត់ជាមុនសិន មុនពេលខ្លួនចាប់ផ្ដើមនិយាយ ដើម្បីទុកលទ្ធភាពឲ្យអ្នកបកប្រែអាចបកប្រែបានចប់សព្វគ្រប់។

[០៩:៤០:៤៨]

មុននឹងឈានចូលដល់កិច្ចពិភាក្សាដេញដោល អង្គជំនុំជម្រះសូមអញ្ជើញមេធាវីជាតិដែលការពារក្ដីឲ្យជនជាប់ចោទនីមួយៗឡើងសុំទទួលស្គាល់មេធាវីអន្តរជាតិជាដៃគូរបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងជាមុនសិន ស្របតាមវិធាន២២(២)(ក) នៃវិធានផ្ទៃក្នុង។ ប្រសិនបើមេធាវីអន្តរជាតិមានវត្តមាននៅក្នុងពេលសវនាការនេះ។

សូមអញ្ជើញលោកមេធាវី សុន អរុណ!

[០៩:៤១:៣៣]

**លោក សុន អរុណ៖**

សូមអរគុណ សូមគោរពលោកប្រធាននៃក្រុមប្រឹក្សានៃអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក។ ជាដំបូងសូមគោរពក្រុមប្រឹក្សានៃអង្គជំនុំជម្រះសាលាដំបូងអ.វ.ត.ក។ ខ្ញុំសូមបង្ហាញខ្លួនខ្ញុំបាទជាមេធាវីខ្ញុំឈ្មោះ សុន អរុណ ជាមេធាវីការពារឲ្យលោក នួន ជា ដែលជាជនដែលត្រូវចោទ។ ហើយលោក ហ្សាស្តេី ប៉ៅ គឺជាសហមេធាវីអន្តរជាតិ ដែលតំណាងជំនួសលោក ម៉ៃខល ផេសមេន ដែលលោក ម៉ៃខល ផេសមេន មិនមានវត្តមាននៅពេលនេះ។ សូម--

[០៩:៤២:២៩]

**លោក ហ្សាស្តេី ប៉ៅ៖**

សូមគោរពលោកប្រធាន, ខ្ញុំមានកិត្តិយសណាស់ដែលសហមេធាវីជាតិលោកបានជម្រាបលោកប្រធានឲ្យបានជ្រាបអំពីវត្តមានរបស់ខ្ញុំ។ ខ្ញុំជាមេធាវីអន្តរជាតិដើម្បីនឹងសហការការពារកូនក្ដីរបស់ខ្ញុំបាទជាមួយមេធាវី សហមេធាវីកម្ពុជា។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ឥឡូវនៃ លោក ហ្សាស្តេី ប៉ៅ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួល

ស្គាល់ស្របតាមគោលបំណងនៃវិធាន២២(២)(ក) យោងទៅតាមការទទួលស្គាល់នេះ លោកមានសិទ្ធិ និងបុព្វសិទ្ធិដូចគ្នានឹងមេធាវីជាតិដែរសម្រាប់សវនាការនីតិវិធីប្រព្រឹត្តទៅចំពោះមុខអង្គជំនុំជម្រះ។

[០៩:៤៣:៣២]

ចំពោះមេធាវីក្រុមផ្សេងទៀត ការពារឲ្យ ខៀវ សំផន ហើយនិងលោកស្រី អៀង ធីរិទ្ធ គឺមេធាវីអន្តរជាតិគឺអវត្តមាន។ ដូច្នេះ នៅក្នុងកិច្ចដំណើរសនាការនាព្រឹកនេះមិនអាចឲ្យមេធាវីជាតិធ្វើការបង្ហាញនូវមេធាវីអន្តរជាតិជាដៃគូរបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះបានទេ។

អំមិញនេះ ឃើញលោកមេធាវី ផាត់ ពៅស៊ាង មានលើកដៃ ប្រហែលជាមានបំណងនិយាយអ្វីហើយ។ សូមអញ្ជើញលោកមេធាវី ផាត់ ពៅស៊ាង ប្រសិនបើមានបញ្ហា។

[០៩:៤៤:១៥]

**លោក ផាត់ ពៅស៊ាង៖**

ដើម្បីគោរពទៅតាមវិធានដែលក្រុមប្រឹក្សាជំនុំជម្រះសាលាដំបូងបានប្រកាស គឺថាជាបឋមខ្ញុំបាទ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះសាលាដំបូង សូមគោរពអង្គសវនាការទាំងមូល។ ខ្ញុំបាទឈ្មោះ ផាត់ ពៅស៊ាង ជាមេធាវីជាតិ ដែលការពារក្តីឲ្យអ្នកស្រី អៀង ធីរិទ្ធ សូមជម្រាបជូនក្រុមប្រឹក្សាជំនុំជម្រះថា មេធាវីអន្តរជាតិរបស់ខ្ញុំបាទ គឺដោយសារគាត់ជាប់បេសកកម្មមិនអាចមកចូលរួមនៅពេលសវនាការនាពេលថ្ងៃនេះ ខ្ញុំបាទគឺគ្មានអ្វីជាបង្ហាញទេ ក៏ប៉ុន្តែមុននឹងចាប់ផ្តើមចូលទៅដល់ហៅថា អង្គ--រឿងនាថ្ងៃនេះ ខ្ញុំបាទសុំអនុញ្ញាតលើកឡើងនូវសេចក្តីសម្រេចលេខ E26។ ក្នុងសេចក្តីសម្រេច E26 នេះ គឺបានកំណត់ថា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនតម្រូវឲ្យមានវត្តមានក្នុងសវនាការនាថ្ងៃនេះទេ។ ដូច្នេះ នៅក្នុងសេចក្តីសម្រេច E26 នេះ បើសម្រេចអ៊ីចឹងហើយ គឺដើម្បីបន្តការងារតទៅទៀត ខ្ញុំបាទស្នើសុំការអនុញ្ញាតពីក្រុមប្រឹក្សាជំនុំជម្រះ មេត្តាស្នើសុំឲ្យខាងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចាកចេញពីសាលសវនាការនេះ។ បាទ, សូមអរគុណ។

[០៩:៤៥:៥៧]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ផាត់ ពៅស៊ាង។ នៅក្នុងសេចក្តីសម្រេចនោះគឺជាការពិតណាស់ អង្គជំនុំជម្រះដែលលោកទទួលស្គាល់ថា ពិតជាមិនតម្រូវឲ្យមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចូលនៅក្នុងដំណើរការនីតិវិធីសវនាការនេះមែន ដោយសារពាក្យថា “មិនតម្រូវ” មានន័យថា មិនមែនហាម

ឃាត់គាត់ទេ គ្រាន់តែមិនតម្រូវឲ្យគាត់ចូល។ ពីព្រោះនៅក្នុងនីតិវិធីនៃកិច្ចពិភាក្សាដេញដោលលើសំណើសុំដោះលែងជនជាប់ចោទនៅក្រៅឃុំបណ្តោះអាសន្ន ច្បាប់មិនតម្រូវឲ្យភាគីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឬក៏តំណាងនាំមុខដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិ មានមតិយោបល់អ្វីទេ។ ប៉ុន្តែ កាលពីព្រឹកមិញនេះ គាត់បានធ្វើសំណើសុំមកអង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះបានប្រជុំគ្នាពិចារណាទៅ គឺគប្បីអនុញ្ញាតឲ្យគាត់ចូល ដោយគាត់ដាក់លក្ខខណ្ឌថា គាត់គ្រាន់តែចូលស្តាប់ដំណើរការសវនាការប៉ុណ្ណោះ គាត់មិនមានមតិយោបល់អ្វីនៅក្នុងរឿងនេះទេ។

[០៩:៤៧:០២]

អ៊ីចឹង ពាក្យនេះគឺគ្រាន់តែមិនតម្រូវទេ តែបើសិនជាគាត់អាចអញ្ជើញចូល បាន គ្រាន់តែគាត់គោរពទៅតាមលក្ខខណ្ឌនៃដំណើរការនីតិវិធី មិនមានមតិយោបល់ ឬក៏សេចក្តីសន្និដ្ឋានអ្វីនៅក្នុងកិច្ចដំណើរការនេះទេ។ នេះសូមជ្រាប។

ហើយតុលាការអង្គជំនុំជម្រះសាលាដំបូងបានប្រជុំព្រឹកមិញ គឺបានឯកភាពគ្នាជាឯកច្ឆន្ទ មុននឹងអនុញ្ញាតឲ្យគាត់មានវត្តមាននៅក្នុងសាលសវនាការនេះ។

សូមអញ្ជើញ!

[០៩:៤៧:៤៣]

**លោក សុន អរុណ៖**

ដោយយោងទៅលើដីកាលេខ E26 ដូចលោកមេធាវី ផាត់ ពៅស៊ាង បានមានប្រសាសន៍អំមិញ។ មួយ មិនតម្រូវឲ្យមានការកត់សម្គាល់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយក៏មិនតម្រូវឲ្យមានវត្តមានពួកគេក្នុងសវនាការនេះដែរ។ អាហ្នឹងមួយ។ ទីពីរ នៅក្នុងដីកាលេខ E19.1 គាត់និយាយដូចគ្នា មានន័យថាដីកាពីរ។ បើកាលណាតុលាការមិនតម្រូវឲ្យចូល មានន័យថាអ្នកណាដែលចូលនៅក្នុងសាលប្រជុំ ជាសាធារណជន មិនមែនជា-- ក្នុងឋានៈជាមេធាវីទេ។ ហើយអំមិញលោកប្រធានថា អង្គសវនាការ-- អង្គចៅក្រមបានជំនុំថានឹងអនុញ្ញាតពីព្រឹកមិញ ប៉ុន្តែខាងមេធាវី--ផ្នែកខាងមេធាវីមិនបានទទួលដីកា ដើម្បីបញ្ជាក់ថាអនុញ្ញាតឲ្យចូលទេ។

[០៩:៤៨:៤៦]

ម្ល៉ោះហើយ ខ្ញុំនៅតែទទូចថា សុំឲ្យមេធាវីខាងរដ្ឋ-- ដើមបណ្តឹងរដ្ឋប្បវេណីអ្នកនាំមុខនេះ ជាសាធារណជននៅខាងក្រៅ។ ហ្នឹងសូមទោស សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណនូវមតិកត់សម្គាល់របស់មេធាវី សុន អរុណ អំពីវត្តមានរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ និងអន្តរជាតិនៅក្នុងសវនាការនេះ។ ប៉ុន្តែ អង្គជំនុំជម្រះសូមជម្រាបលោកមេធាវីជ្រាបថា កាលពីមានសំណើសុំ គឺអង្គជំនុំជម្រះបានធ្វើការពិចារណាយ៉ាងដិតដល់លើបញ្ហានេះ ហើយក៏បានសម្រេចអនុញ្ញាតរួចហើយ។ ហើយកិច្ចដំណើរការនីតិវិធីហ្នឹង គឺមិនមានអ្វីដែលគាត់ត្រូវចូលរួមនៅក្នុង ជាមតិយោបល់ ឬក៏ធ្វើសេចក្តីសន្និដ្ឋាន កត់សម្គាល់អ្វីនោះទេ គាត់គ្រាន់តែចូលរួមនៅក្នុងនីតិវិធីសង្កេតមើលនូវដំណើរការតែប៉ុណ្ណោះ។

[០៩:៥០:១១]

អ៊ីចឹង អង្គជំនុំជម្រះរក្សាសិទ្ធិនៅក្នុងការសម្រេចរបស់ខ្លួនទុកឲ្យមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបមានវត្តមាននៅទីនេះ ដោយមិនឲ្យគាត់មានមតិយោបល់អ្វីពាក់ព័ន្ធជាមួយនឹងកិច្ចដំណើរការនីតិវិធីនេះទេ។

ឥឡូវនេះ មុននឹងប្រគល់វេទិកាទៅមេធាវីការពារក្តីនិងជនជាប់ចោទ អង្គជំនុំជម្រះសូមសង្ខេបអំពីប្រវត្តិនីតិវិធីទាក់ទងទៅនឹងសំណើទាំងនេះ ក៏ដូចជាទាក់ទងទៅនឹងសវនាការថ្ងៃនេះផងដែរ ដូចខាងក្រោមនេះ៖

[០៩:៥១:០៣]

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេត បានចេញដីកាដំណោះស្រាយចំពោះសំណុំរឿងលេខ០០២ និងបានបង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទទាំងបួនរូប រហូតដល់ពេលដែលពួកគាត់ត្រូវបាននាំមកបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ មេធាវីការពារក្តីទាំងបួនក្រុមបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយខាងលើនៅចំពោះមុខអង្គបុរេជំនុំជម្រះ។ មានតែមេធាវីការពារក្តីឲ្យ អៀង សារី ទេ ដែលបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តការឃុំខ្លួន ដូចដែលបានបង្គាប់នៅក្នុងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។

នៅថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ទាំងនេះ ដោយមិនមានសំអាងហេតុគាំទ្រ ដោយបានបញ្ជាក់ថា សំអាងហេតុជាក់លាក់នឹងចេញនៅពេលក្រោយ។ ដីកានេះបានសម្រេចបន្តឃុំខ្លួនជនជាប់ចោទ ទាំងបួនរូបរហូតដល់ត្រូវបាននាំខ្លួនមកបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

នៅថ្ងៃទី១៨ និងថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើសុំដោះលែងឲ្យនៅក្រៅឃុំពីក្រុមមេធាវីការពារក្តីឲ្យឈ្មោះ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ។

[០៩:៥២:៤២]

នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០០១ (ស៊ីក) អង្គបុរេជំនុំជម្រះបានចេញសំអាងហេតុទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនអៀង សារី។ នៅថ្ងៃដដែលនេះដែរ អង្គបុរេជំនុំជម្រះក៏បានចេញនូវសំអាងហេតុស្តីពីការបន្តឃុំខ្លួនជនជាប់ចោទបីរូបទៀតផងដែរ គឺនួន ជា, អៀង សារី និង អៀង ធីរិទ្ធ។

នៅថ្ងៃទី ២៤ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានចេញសំអាងហេតុទាក់ទងនឹងការបន្តឃុំខ្លួនលោក អៀង សារី ដោយហេតុថា អង្គជំនុំជម្រះបានទទួលនូវសំណើសុំលាយលក្ខណ៍អក្សររួចហើយនោះ អង្គជំនុំជម្រះបានស្នើឲ្យមេធាវីការពារក្តីឆ្លើយតបទៅនឹងសំណួរចំនួនពីររបស់អង្គជំនុំជម្រះសាលាដំបូង។ ទីមួយ តើអ្វីទៅដែលជាការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ ដោយសារតែសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ មិនមាននូវសំអាងហេតុនោះ? ពីរ ហេតុអ្វីបានជាលោក លោកស្រីមេធាវីនិយាយថា មានការដោះលែងភ្លាមៗ គឺជាសំណងមួយដ៏សមរម្យសម្រាប់ដោះស្រាយនូវការរំលោភលើសិទ្ធិរបស់ជនជាប់ចោទនោះ?

[០៩:៥៤:៣៩]

បាទ, មុននឹងបន្តកិច្ចនីតិវិធី អំមិញនេះគឺជាមានវត្តមានលោកមេធាវី ស ស្វាន មេធាវីការពារក្តីឲ្យលោក ខៀវ សំផន។

**លោក ស ស្វាន៖**

ទើបមកដល់អំមិញ ហត់ពេក រត់អំមិញ។ បាទ, ជម្រាបប្រសាសន៍ សូមមេត្តានិយាយបន្តិចទៀតទាន ខ្ញុំអត់-- ស្តាប់អត់បាន។

[០៩:៥៥:០៩]

**ប្រធានអង្គជំនុំ៖**

ខ្ញុំអំមិញបានធ្វើការកត់សម្គាល់អំពីវត្តមានរបស់លោក ដោយសារពេលចាប់ផ្តើមដំបូង ក្រឡាបញ្ជីបានរាយការណ៍ថា លោកអវត្តមាន ហើយលោកនឹងមានវត្តមានក្នុងអំឡុងពេលប្រហែលជាម៉ោងដប់កន្លះ ឬក៏ម៉ោងដប់មួយ។ ប៉ុន្តែឥឡូវនេះលោកមានវត្តមាន អ៊ីចឹងអង្គជំនុំជម្រះបានសុំបញ្ជាក់ថា ឥឡូវនេះមានវត្តមានលោកមេធាវី ស ស្វាន ដែលជាមេធាវីការពារក្តីឲ្យលោក ខៀវ សំផន ហើយ។

**លោក ស សុវាន៖**

ខ្ញុំ-- ខ្ញុំបាទសប្បាយចិត្តណាស់ ដោយលោកបញ្ជាក់មូលហេតុ ខ្ញុំចេះតែភ័យខ្លាចលើកទៅថ្ងៃក្រោយទៀត ខ្ញុំក៏ចង់បានក្នុងពេលនេះដែរ។ សូមអរគុណ ហើយសូមទោស ដោយមានការយឺតយ៉ាវ។ អរគុណ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត សូមអញ្ជើញលោកមេធាវី សុន អរុណ ឡើងធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់អំពីការស្នើសុំមូលហេតុ ព្រមទាំងសំអាងហេតុនៃការស្នើសុំដោះលែងលោក នួន ជា ដែលជាកូនក្តីរបស់លោក។ សូមអញ្ជើញ!

[០៩:៥៦:១០]

**លោក សុន អរុណ៖**

ខ្ញុំបាទសូមឲ្យដែ-- សហមេធាវីខ្ញុំជនបរទេស ឡើងធ្វើសេចក្តីសន្និដ្ឋានមុន ហើយបានខ្ញុំធ្វើបន្ទាប់។

**ប្រធានអង្គជំនុំ៖**

សូមផ្អាកបន្តិច។

[០៩:៥៦:៤៣]

ឥឡូវនេះមុននឹងបន្តនីតិវិធីទៀតហ្នឹង គឺអង្គជំនុំជម្រះដោយសារពេលកន្លងមកនេះ អង្គជំនុំជម្រះបានទទួលនូវសំណើសុំរបស់លោកស្រី អៀង ធីរិទ្ធ ដែលគាត់ស្នើសុំរក្សាសិទ្ធិនៅក្នុងការបដិសេធមិនចូលរួមដំណើរការសវនាការជំនុំជម្រះនៅថ្ងៃនេះ។ ប៉ុន្តែ ដោយសារទម្រង់នៃលិខិតហ្នឹង សរសេរទៅមិនមានលក្ខណៈច្បាស់លាស់ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះតម្រូវអញ្ជើញគាត់មកសវនាការនៅពេលនេះ។

[០៩:៥៧:៣០]

ហើយឥឡូវនេះ ក៏មុននឹងកិច្ចដំណើរការដេញដោល អង្គជំនុំជម្រះសូមសួរទៅលោកស្រី អៀង ធីរិទ្ធ ឬក៏មេធាវីរបស់លោកស្រី ថាតើលោកស្រីនៅតែប្រកាន់ជំហរនៅក្នុងការថា សូមមិនបញ្ចូល ចូលខ្លួនមកស្តាប់នូវកិច្ចដំណើរការសវនាការនេះដដែល ឬក៏មានការផ្លាស់ប្តូរកែប្រែនូវគំនិតថា ត្រឡប់មកជាការចូលរួមវិញ? ដើម្បីយើងដោះស្រាយនឹងសំណើនេះជាមុនសិន មុននឹងបន្តកិច្ចដំណើរការនីតិវិធី។

សូមអញ្ជើញលោកស្រី អៀង ធីរិទ្ធ!

[០៩:៥៨:១៤]

**លោកស្រី អៀង ធីរិទ្ធ៖**

*(គ្មានសំឡេងនិយាយ)*

**លោក ផាត់ ពៅស៊ាង៖**

ខ្ញុំបាទសូមអនុញ្ញាតឲ្យកូនក្ដីខ្ញុំបាទអង្គុយបានទេ? ពីព្រោះគាត់លំបាកនៅក្នុងការឈរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំរបស់លោកមេធាវី។ បាទ, ឲ្យគាត់អង្គុយនិយាយបាន។

**លោក ផាត់ ពៅស៊ាង៖**

អរគុណបាទ--

**ប្រធានអង្គជំនុំ៖**

--ឲ្យគាត់អង្គុយនិយាយបាន។

**លោកស្រី អៀង ធីរិទ្ធ៖**

យ៉ាងម៉េចហើយ ធ្វើម៉េច? គេឲ្យធ្វើម៉េច? ម៉េចអ៊ីចឹង ខ្ញុំអត់យល់ទេនេះ?

[០៩:៥៩:២៥]

ខ្ញុំ អៀង ធីរិទ្ធ សូមបដិសេធសិទ្ធិក្នុងការចូលរួមសវនាការស្ដីពីការឃុំខ្លួន លើពាក្យស្នើសុំរបស់ខ្ញុំ ដែលធ្វើឡើងនៅថ្ងៃនេះ។ ពីរ ខ្ញុំនឹងយកមូលដ្ឋានដែលបានលើកឡើងនៅក្នុងពាក្យស្នើសុំរបស់ខ្ញុំ ដែលមេធាវីរបស់ខ្ញុំបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូងជាផ្លូវការ។

**ប្រធានអង្គជំនុំ៖**

លោកស្រី អៀង ធីរិទ្ធ ឥឡូវនេះ លោកស្រីស្នើសុំដោយបញ្ជាក់សិទ្ធិនៅក្នុងការបដិសេធមិនចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ ហើយប្រគល់សិទ្ធិទៅឲ្យលោកមេធាវីរបស់លោកស្រី ហើយនិងសេចក្ដីសារណាដើម្បីដាក់ស្នើសុំដោះលែងនៅក្រៅឃុំនេះ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់លោកស្រី។ អនុរក្សមន្ទីរឃុំឃាំង នាំលោកស្រី អៀង ធីរិទ្ធ ទៅកាន់-- ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញចុះ!

[១០:០២:១៦]

ឥឡូវនេះយើងបន្តកិច្ចនីតិវិធីទៅទៀត។ សូមអញ្ជើញលោកមេធាវី សុន អរុណ មេធាវីការពារក្ដីឲ្យលោក នួន ជា ឡើងធ្វើសេចក្ដីសន្និដ្ឋានបញ្ជាក់អំពីការស្នើសុំ មូលហេតុ ព្រះទាំងសំអាងហេតុនៃការស្នើសុំដោះលែងកូនក្ដីរបស់លោកជាបន្ទាន់។ សូមអញ្ជើញ!

[១០:០២:៣៦]

**លោក សុន អរុណ៖**

ខ្ញុំ សុន អរុណ មេធាវីជាតិរបស់លោក នួន ជា ជាបឋមខ្ញុំសូមស្នើទៅលោកប្រធាន ឲ្យកូនក្ដីខ្ញុំបាទបានពាក់វ៉ែនតាពណ៌ខ្មៅពីព្រោះគាត់ ភ្នែកគាត់មិនស្រួលរួចាំងថ្ងៃ ចាំងពន្លឺច្រើនណាស់។ ពេលណាត្រូវការឡើងនិយាយអាហ្នឹងបានគាត់ដោះវ៉ែនតាវិញ។ អនុញ្ញាតឲ្យបានទេ?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត បើដោយសារមានមូលហេតុសមស្រប។

[១០:០៣:០៦]

**លោក សុន អរុណ៖**

បន្តទៅទៀតខ្ញុំបាទ នឹងសូមជូនទៅលើ ហ្សាស្តេ ប៉ៅ ជាសហមេធាវីអន្តរជាតិឡើងធ្វើសេចក្ដីសន្និដ្ឋានមុននឹង-- ខ្ញុំនឹងធ្វើជូនតាមក្រោយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិ ហ្សាស្តេ ប៉ៅ។

**លោក ហ្សាស្តេ ប៉ៅ៖**

សូមអរគុណលោកប្រធាន និងក្រុមប្រឹក្សាអង្គជំនុំជម្រះ និងតំណាងអយ្យការ ក្រឡាបញ្ជី។ សូមអរគុណដែលអនុញ្ញាតឲ្យខ្ញុំបង្ហាញខ្លួននៅចំពោះមុខអង្គចៅក្រមនៅថ្ងៃនេះ ហើយខ្ញុំសូមថ្លែងអំណរគុណលោក សុន អរុណ ជាសហមេធាវីការពារក្ដីដែលណែនាំបង្ហាញខ្លួនខ្ញុំនៅក្នុងតុលាការនេះ។

[១០:០៣:៥១]

ខ្ញុំសូមធ្វើការលើកឡើងដោយសង្ខេប ដោយសារភាសាអង់គ្លេសមិនមែនជាភាសាដើមរបស់ខ្ញុំទេ ប្រហែលជាខ្ញុំនិយាយទៅមានកំហុសខ្លះ។ តែយ៉ាងណាក៏ដោយខ្ញុំសូមអនុញ្ញាត សូមអភ័យទោសទៅក្រុមប្រឹក្សាជំនុំជម្រះ និងអ្នកបកប្រែផងដែរ ចំពោះភាសាដែលខ្ញុំប្រើប្រាស់ ហើយខ្ញុំនឹងធ្វើនិយាយដោយយឺតៗតាមការស្នើសុំពីអង្គភាពបកប្រែ។

អង្គជំនុំជម្រះបានស្នើសុំឲ្យក្រុមមេធាវីការពារក្តីលើកឡើងចំពោះសំណើដែលទាក់ទងទៅនឹងការប៉ះពាល់ទៅដល់ជនជាប់ចោទក្នុងរយៈពេលនៃការឃុំខ្លួន ថាតើមានដំណោះស្រាយអ្វីខ្លះត្រូវផ្តល់ទៅគាត់? ហើយខ្ញុំនឹងលើកឡើងបញ្ហានេះនៅក្នុងថ្ងៃនេះ។ យ៉ាងណាក៏ដោយខ្ញុំសូមលើកឡើងនូវសេចក្តីសន្និដ្ឋានពីខាងក្រុមមេធាវីការពារក្តីថា បញ្ហានេះយើងលើកឡើងបានរួចមកហើយ។ ហើយក៏មានការចែងយ៉ាងច្បាស់នៅក្នុងវិធានផ្ទៃក្នុង ហើយក៏មានការលើកឡើងនៅក្នុងកិច្ចប្រជុំពេញអង្គកាលពីថ្ងៃទី៤ ខែកុម្ភៈ ២០០៨ ផងដែរ។

[១០:០៤:៥៩]

ក្រុមប្រឹក្សាជំនុំជម្រះជាទីគោរពក៏បានឆ្លើយតបទៅនឹងបញ្ហាហ្នឹងជូនចំពោះក្រុមមេធាវីការពារក្តីផងដែរ។ ដូច្នេះ ក្រុមមេធាវីការពារក្តីលើកឡើងថា ចម្លើយនោះគឺវាឆ្លើយតបនៅក្នុងវិធាន៦៨ នៃវិធានផ្ទៃក្នុង។ ដូច្នេះ នៅពេលនេះ ខ្ញុំសូមលើកសេចក្តីសន្និដ្ឋានតែមួយ ថាតើសាលដីការបស់អង្គបុរេជំនុំជម្រះនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ នោះ វាស្របទៅតាមវិធានផ្ទៃក្នុងរបស់តុលាការនេះដែរឬទេ? ខ្ញុំសូមឆ្លើយថា ចម្លើយនោះគឺសាលដីកាមិនត្រឹមត្រូវឡើយ។ ខ្ញុំនឹងលើកឡើងបញ្ហានេះនៅពេលក្រោយ ហើយខ្ញុំនឹងលើកឡើងហេតុអ្វីបានក្រុមមេធាវីការពារក្តីយល់ឃើញថា ចម្លើយរបស់អង្គបុរេអង្គជំនុំជម្រះសាលាដំបូងគឺ បានបង្ហាញស្របទៅតាមវិធាន៦៨។ ដូចដែរ អង្គជំនុំជម្រះបានលើក-- បានដឹងហើយវិធាន៦៨ មិនបានលើកឡើងអំពីការបន្តការឃុំខ្លួននៅក្នុងករណីបណ្តឹងឧទ្ធរណ៍ទៅលើដីកាដំណោះស្រាយនោះទេ។ វិធានត្រូវបានវិសោធនកម្មឲ្យអង្គបុរេជំនុំជម្រះ និងសាលាដំបូងមានពេលវេលាគ្រប់គ្រាន់ ដើម្បីធ្វើការសម្រេចទៅលើដីកាដំណោះស្រាយ រួមទាំងរៀបចំពេលវេលាក្នុងការធ្វើសវនាការ។

[១០:០៦:១៥]

វិធាន៦៨ថ្មី បានចែងថា នេះគឺជាចំណុចមួយដែលខ្ញុំសង្កេតឃើញថាសំខាន់។ វិធាន៦៨ គឺបានបង្ហាញរយៈពេលមួយថ្មី ហើយមានចែងនិងលើកឡើងនៅកិច្ចប្រជុំពេញអង្គ។ ដូច្នេះហើយក៏មានការបញ្ចូលនៅក្នុងហ្នឹងរួចហើយ។ ហើយវិធាននេះបានពិភាក្សាយ៉ាងល្អិតល្អន់។ វិធាន៦៨ បានបង្ហាញយ៉ាងច្បាស់លាស់ចំពោះការឆ្លើយទៅនឹងករណី ឌុច ផងដែរ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើង។ ប្រសិនបើមិនមានសាលដីការបស់អង្គបុរេជំនុំជម្រះក្នុងរយៈពេលបួនខែនោះទេ គឺផលប្រយោជន៍ត្រូវផ្តល់ឲ្យលោក នួន ជា គឺគាត់ត្រូវតែទទួលបានប្រយោជន៍ពី-- ផលប្រយោជន៍ដទៃៗទៀត មិនមានត្រូវឲ្យធ្វើតុល្យភាពទៅនឹងផលប្រយោជន៍ណាផ្សេង ដូចជាការឃុំខ្លួននោះទេ។

[១០:០៧:១៦]

ដូច្នេះហើយវាជាហេតុផលដែលលើកឡើងដោយកិច្ចប្រជុំពេញអង្គ ប្រសិនបើក្នុងរយៈពេលបួនខែនោះវាគ្មានហេតុផលអ្វីត្រូវធ្វើការឃុំខ្លួនលោក នួន ជា នោះឡើយ។ ផលប្រយោជន៍នេះ គឺត្រូវតែទទួលបាន យោងទៅតាមវិធាន។ ដូច្នេះ មានន័យនៅក្នុងថ្ងៃនេះ យើងមិនចាំបាច់ធ្វើការដេញដោលទៅលើករណីនេះទេ ដោយសារតែកិច្ចប្រជុំពេញអង្គបានធ្វើការវិភាគទៅលើចំណុចនេះហើយតាំងពីឆ្នាំ២០០៨។ ការវិភាគនោះ បានចែងយ៉ាងច្បាស់ដូចដែលមានលើកឡើងនៅក្នុងវិធាន៦៨។ បានន័យថា រយៈពេលបួនខែ ប្រសិនបើមិនមានសាលដីការបស់អង្គបុរេជំនុំជម្រះ គឺត្រូវតែឲ្យប្រយោជន៍ទៅខាងជនជាប់ចោទ។ យើងគួរកត់សម្គាល់ថា វិធាននេះគឺស្របទៅនឹងនីតិវិធីរបស់កម្ពុជា ហើយនិងទស្សនទានមួយចំនួននៅក្នុងប្រព័ន្ធច្បាប់នេះ។

[១០:០៨:១២]

វិធាន២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានន័យថា បួនខែក្រោយពីដីកាដំណោះស្រាយ ជនជាប់ចោទត្រូវយកមកបង្ហាញខ្លួននៅចំពោះមុខសាលាដំបូង។ បើមិនដូច្នោះទេ ដីកាឃុំខ្លួននឹងមិនមានអនុភាពទៀតឡើយ តម្រូវឲ្យដោះលែងគាត់។ យើងដឹងហើយថា នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌក៏មានចែងអំពីរយៈពេលបួនខែផងដែរ គឺតម្រូវផ្តល់ផលប្រយោជន៍ទៅឲ្យជនជាប់ចោទ លើប្រយោជន៍ដទៃៗទៀត។ ដូច្នេះបញ្ហាចោទដែលត្រូវលើកឡើង និងដោះស្រាយដោយសាលាដំបូងនៅថ្ងៃនេះ និងអង្គបុរេជំនុំជម្រះ គឺត្រូវធ្វើឲ្យស្របទៅតាមវិធានផ្ទៃក្នុង។ ក្រុមមេធាវីការពារក្តី គួរតែលើកឡើងថា យើងមិនអាចឃុំខ្លួនបន្តទៀតនោះទេ។ ដូច្នេះហើយ នៅក្នុងវិធានផ្ទៃក្នុងក៏មានចែងអំពីសាលដីកាតម្រូវឲ្យមានផ្តល់សំអាងហេតុ។

[១០:០៩:១៣]

វិធាន៧៧ ក៏មានការលើកឡើង ហើយក៏មានចែងអំពីករណី អ.វ.ត.ក ភាគីទាំងឡាយត្រូវតែផ្តល់សំអាងហេតុ ចំពោះហេតុផលដែលខ្លួនបានលើកឡើង។ ដូច្នេះ អង្គបុរេជំនុំជម្រះ នៅពេលអតីតកាលក៏បានឲ្យភាគីផ្តល់សំអាងហេតុ ដូច្នេះចំពោះអង្គបុរេជំនុំជម្រះដែលបង្ហាញថា សំណើ ឬក៏បណ្តឹងរបស់ក្រុមមេធាវីការពារក្តីមិនមានសំអាង-- មិនមានលក្ខណៈទទួលយកបាននោះ គឺត្រូវផ្តល់សំអាងហេតុ។ អង្គបុរេជំនុំជម្រះមិនបានផ្តល់សំអាងហេតុ និយាយដោយសាមញ្ញនៅក្នុងអង្គបុរេជំនុំជម្រះនោះ គឺត្រូវតែផ្តល់សំអាងហេតុនៅក្នុងសាលដីកា។ ហើយគឺវាតម្រូវជាដាច់ខាត់ទៅដល់អង្គបុរេជំនុំជម្រះ។

[១០:១០:០៧]

ដូច្នេះហើយសាលដីកានោះមិនអាចចាត់ទុកថា ជាសេចក្តីសម្រេចនោះទេ។ អនុលោមតាមវិធានផ្ទៃក្នុង ដោយមិនមានផ្តល់មូលដ្ឋានអង្គច្បាប់ចំពោះការបន្តការឃុំខ្លួន។ អាស្រ័យហេតុនេះហើយ ដោយសាតែអង្គបុរេជំនុំជម្រះមិនចេញសាលដីកាសេចក្តីសម្រេចតាមវិធានផ្ទៃក្នុង ដីកាក្នុងការបន្តការឃុំខ្លួនលោក នួន ជា មិនមានអនុភាពទៀតទេ ក្រោយពីថ្ងៃ១៦ ខែមករា ឆ្នាំ២០១១។ ដូច្នេះ នួន ជា ត្រូវដោះលែងនៅក្នុងថ្ងៃនេះ។

វិធានផ្ទៃក្នុងមានចែង ហើយក្រុមមេធាវីការក្តីក៏គិតថាយើងមិនចាំបាច់ពិភាក្សាគ្នាទៅលើចំណុចនេះទេ វាមានចែងយ៉ាងច្បាស់លាស់។ ប៉ុន្តែ តាមពាក្យពេចន៍និងចោទសួរពីក្រុមប្រឹក្សាជំនុំជម្រះ ក្រុមមេធាវីការពារក្តីនោះ គឺសួរយើងថាតើមានផលប៉ះពាល់យ៉ាងម៉េចទៅដល់កូនក្តីរបស់យើងខ្ញុំ។ ជាបឋម ដោយសារតែមិនមានផ្តល់សំអាងហេតុនៅសាលដីកា ការរៀបចំសម្រាប់ការធ្វើអញ្ញត្រកម្មវាប៉ះពាល់ទៅដល់យើង។ ដូច្នេះ មេធាវីការពារក្តីមិនអាចយល់ និងដឹងអំពីសំអាងហេតុរបស់អង្គបុរេជំនុំជម្រះលើការបដិសេធបណ្តឹងឧទ្ធរណ៍របស់យើងនោះទេ។

[១០:១១:២៨]

អង្គជំនុំជម្រះសាលាដំបូង មិនមានកាតព្វកិច្ចគោរពតាមការយល់ឃើញរបស់អង្គបុរេជំនុំជម្រះនោះទេ។ សេចក្តីសម្រេច ឬសាលដីការបស់អង្គបុរេជំនុំជម្រះនោះគួរតែផ្តល់នូវសំអាងហេតុ។ ហើយក្រុមមេធាវីការពារក្តីក៏មិនអាចពិចារណាផងដែរ នៅពេលដែលខ្លួនលើកឡើងសេចក្តីសន្និដ្ឋានរបស់ខ្លួនដោយសារតែសំអាងហេតុរបស់អង្គបុរេជំនុំជម្រះមានភាពចាំបាច់។ ប្រសិនបើមិនចាំបាច់ ហេតុអ្វីបានជាយើងតម្រូវឲ្យគាត់ផ្តល់សំអាងហេតុ? មេធាវីការពារមិនអាចលើកឡើងសេចក្តីសន្និដ្ឋានរបស់ខ្លួនទេ ប្រសិនបើមិនមានសំអាងហេតុ។

[១០:១២:១០]

កាលពីសប្តាហ៍មុន វាបានបង្ហាញថា មេធាវីការពារក្តីមិនចាំបាច់មានសំអាងហេតុដើម្បីធ្វើអញ្ញត្រកម្មនោះទេ។ ខ្ញុំសូមលើកឡើងថា ការមិនមានផ្តល់សំអាងហេតុនឹងប៉ះពាល់ទៅដល់ក្រុមមេធាវីការពារក្តី។ ដូច្នេះហើយវារាំងមិនឲ្យមេធាវីការពារក្តីលើកឡើងអញ្ញត្រកម្មរបស់ខ្លួនបាន ជាពិសេសអញ្ញត្រកម្មដូចដែលក្រុមប្រឹក្សាជំនុំជម្រះបានដឹងហើយគឺវា ជាយុត្តាធិការ វាស្ថិតនៅក្នុងក្របខ័ណ្ឌនៃយុត្តាធិការរបស់អង្គជំនុំជម្រះ។ ដូច្នេះ វាប៉ះពាល់យ៉ាងខ្លាំងទៅដល់កូនក្តីរបស់យើង។

[១០:១២:៥២]

ចំណុចទីពីរ ចំណុចដែលខ្ញុំយល់ឃើញថា ការប៉ះពាល់នោះគឺ អង្គជំនុំជម្រះនេះគឺមិនគោរពតាមច្បាប់ បើសិនបើមិនដូច្នោះទេ។ វិធានមានចែង និងការពារផលប្រយោជន៍របស់លោក នួន ជា ហើយក៏បានកំណត់អំពីរយៈពេលនៃការឃុំខ្លួនទៅលើជននេះផងដែរ។ វិធាន៦៨(៣) បង្ហាញអំពីសិទ្ធិរបស់លោក នួន ជា ហើយសិទ្ធិនេះគឺត្រូវបានរំលោភដោយកិច្ចរបស់អង្គបុរេជំនុំជម្រះ។ ដូច្នេះប្រសិនបើអង្គបុរេជំនុំជម្រះនោះ បំពេញកិច្ចតាមត្រឹមត្រូវនោះវាមិនបង្កជាការរំលោភសិទ្ធិនោះទេ។

[១០:១៣:៣៣]

អង្គបុរេជំនុំជម្រះធ្វើការរំលោភលក្ខខណ្ឌនៅក្នុងវិធានផ្ទៃក្នុង។ ដូច្នេះមិនចាំបាច់ធ្វើការឃុំខ្លួនលោក នួន ជា នៅក្នុងមន្ទីរឃុំឃាំងនោះទេ។ ចំណុចនេះយើងលើកឡើងថា អង្គបុរេជំនុំជម្រះបានធ្វើដូច្នេះពីរដងហើយ វាប៉ះពាល់ទៅដល់យើង ដែលនៅពេលនោះ អង្គបុរេជំនុំជម្រះបានចេញតែសាលដីការបស់ខ្លួនដើម្បីតម្រូវឲ្យចៅក្រមស៊ើបអង្កេតធ្វើការចេញដីការបស់ខ្លួននៅក្នុងពេល រយៈពេលមួយសមស្រប។ ដូច្នេះហើយវាប៉ះពាល់ទៅដល់កូនក្ដីរបស់យើង វាជាការរំលោភកូនក្ដីជនជាប់ចោទនៅក្នុង អ.វ.ត.ក។ ដូច្នេះ វាមិនផ្ដល់សិទ្ធិសមភាពទៅដល់កូនក្ដីរបស់យើងនោះទេ ដោយសារតែអង្គបុរេជំនុំជម្រះមិនបានចេញសេចក្ដីសម្រេចក្នុងរយៈពេលបួនខែ។

[១០:១៤:២៩]

យើងដឹងហើយថា វាមានចែងយ៉ាងច្បាស់បើសិនបើមិនគោរពវិធាន៦៨(៣) ទេ វានឹងប៉ះពាល់ទៅដល់កូនក្ដីរបស់យើង។ ដើម្បីសន្និដ្ឋានសរុបទៅលើសំណួរទីពីរ របស់ក្រុមប្រឹក្សាជំនុំជម្រះ ខ្ញុំគិតថាវាក៏ដូចនឹងអ្វីដែលខ្ញុំលើកឡើងដូចមុននោះផងដែរ។ ប្រសិនបើកអង្គជំនុំជម្រះស្របជាមួយនឹងក្រុមមេធាវីការពារក្ដីថា សេចក្ដីសម្រេច សាលដីការបស់អង្គបុរេជំនុំជម្រះនោះមិនស្របទៅនឹងវិធានផ្ទៃក្នុងមិនមានសំអាងហេតុគ្រប់គ្រាន់នោះ។ ដូច្នេះ យើងនឹងគោរពទៅតាមវិធាន៦៨ របស់យើង។ វិធាន៦៨ បង្ហាញអំពីដំណោះស្រាយដែលយើងត្រូវធ្វើឡើង គឺដោះលែងឲ្យមានសេរីភាព។

[១០:១៥:១២]

សេចក្ដីសន្និដ្ឋានក៏អាចទាញចេញមកពីចំណុចនេះផងដែរថា យើងបានលើកឡើងយ៉ាងច្បាស់នៅក្នុងសេចក្ដីសន្និដ្ឋានរបស់យើង ហើយអង្គបុរេជំនុំជម្រះ គួរតែធ្វើការបំពេញក្នុងលក្ខណៈកម្រិត ចំណុះ-ប៉ុណ្ណោះចំពោះការឃុំខ្លួនជនជាប់ចោទ។

**លោក សុន អរុណ៖**

សូមអភ័យទោស រំខាន ដោយសារកូនក្ដីខ្ញុំបាទ ឈឺក្បាល ហើយវិលមុខខ្លាំង សូមឲ្យទៅពេទ្យពិនិត្យនៅពេលឥឡូវនេះ សូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ អនុរក្សមន្ទីរឃុំឃាំងនាំគាត់ទៅឲ្យពេទ្យពិនិត្យ!

**លោក ហ្សាស្ដេី ប៉ៅ៖**

សូមសួរទៅក្រុមប្រឹក្សាជំនុំជម្រះ តើខ្ញុំតម្រូវឲ្យរង់ចាំរហូតដល់លោក នួន ជា ត្រឡប់មកវិញ ឬក៏យ៉ាងណា?

*(ជនជាប់ចោទចាកចេញពីបន្ទប់សវនាការ)*

[១០:១៧:៣៣]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ វាជាគោលការណ៍ យើងដំណើរការកិច្ចនីតិវិធីចំពោះមុខជនជាប់ចោទ លើកលែងតែជនជាប់ចោទបានបោះបង់សិទ្ធិរបស់គាត់ជាក់លាក់នៅក្នុងកិច្ចដំណើរការនីតិវិធី ដូចជាករណី អៀង ធីរិទ្ធ ដែលបានបង្ហាញអំពីព្រឹកមិញនេះ ជូនចំពោះមុខអង្គសវនាការទាំងមូលរួចហើយ។ ប៉ុន្តែ ឥឡូវនេះ លោកចង់សួរបញ្ជាក់បញ្ហាថា តើកិច្ចដំណើរការនីតិវិធីនេះ តើធ្វើតទៅទៀតបានដែរឬអត់? អ៊ីចឹងទេ អង្គជំនុំជម្រះសួរទៅមេធាវីការពារក្ដីឲ្យលោក នួន ជា សូមលោកបញ្ជាក់មើល៍ ថាតើសួរលោកកូនក្ដីរបស់លោកមើល៍ ថាតើកូនក្ដីរបស់លោកហ្នឹងផ្ដល់សិទ្ធិឲ្យលោក ឬក៏អង្គជំនុំជម្រះដំណើរការនីតិវិធីដោយមិនមានវត្តមានរបស់គាត់ដែរឬទេ នៅក្នុងអំឡុងពេលដែលគាត់មានបញ្ហានេះ?

[១០:១៨:៣៣]

**លោក សុន អរុណ៖**

មុននឹងខ្ញុំបាទសុំអនុញ្ញាតពីលោកប្រធានថា កូនក្ដីខ្ញុំបានសុំចេញដោយសារមានវិលមុខ ហើយនឹងឈឺក្បាលខ្លាំង មិនអាចអង្គុយទ្រាំបាន គាត់អនុញ្ញាតឲ្យខ្ញុំបាទស្នើសុំទៅអង្គជំនុំជម្រះថា សូមគាត់ចេញ ដើម្បីទុកពេលឲ្យមេធាវីហ្នឹងបន្តការនីតិវិធីទាល់ចប់ គាត់បានជជែកគ្នាហើយ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងសូមអញ្ជើញ សូមអញ្ជើញលោកមេធាវី ហ្សាស្ដេី ប៉ៅ សូមអញ្ជើញបន្ត។

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន ខ្ញុំមិនមានច្រើនត្រូវបន្ថែមនោះទេ ប៉ុន្តែខ្ញុំនឹងបញ្ចប់នូវអ្វីដែលខ្ញុំត្រូវតែលើកឡើង។ ខ្ញុំបានលើកឡើងហើយនៅពេលដែលយើងឈប់អម្បាញ់មិញ ទាក់ទងទៅនឹងគោលការណ៍ដំណោះស្រាយចុងក្រោយដែលអង្គជំនុំជម្រះនេះត្រូវគោរពតាម ហើយអង្គបុរេជំនុំជម្រះ ប្រសិនបើគោរពតាមគោលការណ៍នេះ អ្វីដែលខ្លួនបានធ្វើនោះ ខ្លួនមិនគួរធ្វើការចេញនូវសេចក្តីសម្រេចមួយដែលមានវិការៈ នៅថ្ងៃទី១៣ ខែមករា នោះឡើយ។ ដូច្នេះដីកាឃុំខ្លួនរបស់ចៅក្រមស៊ើបអង្កេត គឺមិនមានអនុភាពទៀតទេ។ នៅក្នុងចំណុចនេះ វានឹងមានការគិតគូរប្រសិនបើយើងគិតថា ការឃុំខ្លួនរបស់លោក នួន ជា មិនបានផ្តល់មូលដ្ឋានសុំត្រឹមត្រូវ។ នៅក្នុងថ្ងៃនេះ យើងក៏មិនទទួលបានសេចក្តីសម្រេចមួយដោយមានសំអាងហេតុទៅលើបណ្តឹងឧទ្ធរណ៍ផងដែរ។ ដូច្នេះយើងត្រូវតែធ្វើការប៉ះប៉ូវ កែតម្រូវដោះស្រាយទៅលើបញ្ហានេះ គឺដោះស្រាយភ្លាមៗ។

[១០:២០:២៣]

លោក នួន ជា បានលើកឡើងហើយ យើងលើកឡើងថា តុលាការនេះនឹងធ្វើបំពានទៅលើវិធានផ្ទៃក្នុង ដូច្នេះយើងមិនចង់ឲ្យមានករណីនោះទេ វាមិនមានភាពសមស្របនោះឡើយ។ អ.វ.ត.ក គឺជាតុលាការគំរូសម្រាប់សង្គមកម្ពុជា។ លោក នួន ជា គួរតែធ្វើយ៉ាងណាត្រូវបានគេសម្រេចឲ្យស្របទៅតាមវិធានផ្ទៃក្នុង ហើយ អ.វ.ត.ក ត្រូវការគោរពទៅលើវិធាននិងច្បាប់ និងគោរពឲ្យបានសមស្របពិចារណាឲ្យបានត្រឹមត្រូវ។ ដូច្នេះខ្ញុំអស់ហើយ ខ្ញុំសូមអនុញ្ញាតផ្តល់វេទិកានេះទៅឲ្យលោកសហមេធាវីជាតិ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី សុន អារុណ!

[១០:២១:០០]

**លោក សុន អរុណ៖**

ខ្ញុំសូមគោរព និងសូមអរគុណសាជាថ្មីចំពោះលោកប្រធាន ហើយនឹងក្រុមប្រឹក្សាអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក។

ជាបឋមអនុលោម តាមវិធាន៨២(២) និងវិធាន៦៨(៣) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ខ្ញុំជាសហមេធាវីការពារលោក នួន ជា ដែលជាជនត្រូវចោទពីតុលាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ

កម្ពុជា សូមធ្វើការតវ៉ានិងបដិសេធអំពីការបន្តការឃុំឃាំងលោក នួន ជា ជាកូនក្តីរបស់ខ្ញុំ ដោយអង្គបុរេជំនុំជម្រះបានធ្វើខុសច្បាប់ ហើយបន្តការឃុំឃាំងលោក នួន ជា បន្តទៅទៀតជាបណ្តោះអាសន្នដោយពុំមានការបង្ហាញពីការសំអាងហេតុជាក់លាក់អំពីសំណាក់អង្គបុរេជំនុំជម្រះ ក្រោយពីសហចៅក្រមស៊ើបអង្កេតបានបញ្ជូនដីកាដំណោះស្រាយទៅសាលាដំបូងបានបួនខែរួចមកហើយនោះ។

[១០:២២:១៥]

ត្រូវបានឃុំខ្លួនបណ្តោះអាសន្នដោយសហចៅក្រមស៊ើបអង្កេតរយៈពេលមួយឆ្នាំនៅមន្ទីរឃុំឃាំង អ.វ.ត.ក ចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧។ រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ននោះ លោក នួន ជា ត្រូវបានពន្យារពេលមួយឆ្នាំបន្ថែមទៀតនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ ហើយបន្តមួយឆ្នាំទៀតរហូតដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩។ លុះដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបន្តការឃុំខ្លួន លោក នួន ជា រហូតដល់ពេលនាំខ្លួនទៅជំនុំជម្រះនៅសាលាដំបូងនៃ អ.វ.ត.ក។

នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានសម្រេចបន្តឃុំខ្លួនបណ្តោះអាសន្នលោក នួន ជា រហូតដល់ពេលបាននាំខ្លួនទៅមុខអង្គជំនុំជម្រះសាលាដំបូងអ.វ.ត.ក។ បច្ចុប្បន្ននេះលោក នួន ជា ត្រូវបានឃុំខ្លួននិងត្រួតពិនិត្យនៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃនៃរាជាណាចក្រកម្ពុជា។

[១០:២២:២៦]

វិធាន៦៨ នៃវិធានផ្ទៃក្នុង ចែងពីអានុភាពរបស់ដីកាដំណោះស្រាយទៅលើការឃុំខ្លួនបណ្តោះអាសន្នដូចខាងក្រោម៖

មួយ ការចេញដីកាដំណោះស្រាយទៅលើការឃុំខ្លួនបណ្តោះអាសន្ន និងដីកាសម្រេចទាំងឡាយនៅពេលដែលរយៈពេលកំណត់នៅក្នុងការប្តឹងឧទ្ធរណ៍ត្រូវផុតរលត់។ ប៉ុន្តែ នៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា លក្ខខណ្ឌទាំងឡាយសម្រាប់បង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នក្រោមវិធាន៦៣ នៅតម្រូវឲ្យសហចៅក្រមស៊ើបអង្កេត សម្រេចបន្តឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្នតទៅទៀតរហូតដល់ជនជាប់ចោទនេះ ត្រូវនាំខ្លួនទៅជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក។

នៅក្នុងករណីណាក៏ដោយ សេចក្តីសម្រេចរបស់ចៅក្រមស៊ើបអង្កេត ឬសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដើម្បីបន្តការឃុំឃាំងជាបណ្តោះអាសន្នតទៅទៀតនោះ ត្រូវអស់អានុភាពក្នុងពេល

បួនខែក្រោយ លើកលែងជនជាប់ចោទត្រូវបាននាំខ្លួន ទៅជំនុំជម្រះនៅមុខសាលាដំបូងក្នុងអំឡុងពេលបួនខែនោះ។

[១០:២៤:៥២]

វិធាន៧៧(១៤)ចែងដែលទាក់ទងថា សេចក្តីសម្រេចទាំងអស់ស្ថិតក្នុងវិធាននេះ ត្រូវមានសំអាងហេតុ។ សេចក្តីសម្រេចកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ គឺជាសេចក្តីសម្រេចក្រោមវិធាននេះ វិធាន-- និងសេចក្តី-- នឹង-- ដូច្នេះត្រូវតែមានសំអាងហេតុ។ ចំពោះការនិយាយជាទូទៅអំពីការតម្រូវឲ្យមានសំអាងហេតុ គឺស្ថិតនៅក្រោមប្រព័ន្ធទាំងមូលនៃវិធាននិងហេតុផលនេះ។ ស្ទើរតែនៅគ្រប់ពេលគ្រប់សកម្មភាពជាវិជ្ជមានដែលត្រូវអនុវត្តដោយភាគីនានា ត្រូវតែមានសំអាងហេតុ។

ការតម្រូវឲ្យសេចក្តីសម្រេចមានសំអាងហេតុ គឺវាឆ្លុះបញ្ចាំងពីបទដ្ឋានគតិយុត្តិអន្តរជាតិ ដូចជាក្នុងតុលាការសិទ្ធិមនុស្សអឺរ៉ុប។ នៅក្នុងច្បាប់របស់ខ្លួន តុលាការជាញឹកញាប់បានប្រកាសថា សំអាងហេតុដែលបានផ្តល់ក្នុងសេចក្តីសម្រេច គឺទាក់ទងយ៉ាងជិតស្និតទៅនឹងសេចក្តីបារម្ភ ដើម្បីធានាឲ្យបានតុលាការត្រឹមត្រូវ។ ដើម្បីធានាឲ្យបានសិទ្ធិការពារក្តី ការសំអាងហេតុ គឺសំខាន់ណាស់សម្រាប់យុត្តិធម៌ដ៏មានគុណភាព និងផ្តល់នូវការការពារប្រឆាំងនឹងសេចក្តីសម្រេចមិនសមរម្យ។

[១០:២៦:២២]

រដ្ឋធម្មនុញ្ញចែងថា ការចោទប្រកាន់ ការចាប់ខ្លួន ឬការឃុំខ្លួនជនណានឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តទៅតាមបញ្ញត្តិច្បាប់។ ការសំអាងរដ្ឋធម្មនុញ្ញ-- ព្រមទាំងបញ្ញត្តិដែលពាក់ព័ន្ធនឹងកតិកាសញ្ញាអន្តរជាតិពីសិទ្ធិពលរដ្ឋនិងនយោបាយ កិច្ចព្រមព្រៀងនិងច្បាប់បង្កើតអ.វ.ត.ក ព្រមជាមួយលិខិតតូបករណ៍ ធម្មនុញ្ញ ទទួលស្គាល់គោលការណ៍នីត្យានុកូលភាព ដែលបានអនុវត្តនៅអ.វ.ត.ក ត្រូវតែអនុវត្តតាមបញ្ញត្តិច្បាប់កម្ពុជា។

[១០:២៧:០៧]

ហើយការចោទប្រកាន់ ការស៊ើបអង្កេត និងការជម្រះក្តីជនណាម្នាក់ ត្រូវអនុវត្តតាមនីតិវិធីដែលមានស្រាប់។ ជាពិសេសលក្ខខណ្ឌនៃការចាប់ចោទ និងការឃុំខ្លួនជនជាប់ចោទ ត្រូវតែស្របតាមច្បាប់ដែលមានស្រាប់។ គោលការណ៍នៃការសម្រេចខ្ពស់បំផុតដែលត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ ដែលចែងនៅក្នុងករណីមានមធ្យោបាយផ្នែកច្បាប់ដទៃទៀត ដែលអាចការពារផលប្រយោជន៍ខាងយុត្តិធម៌ដោយមិនចាំបាច់បញ្ជូនត្រឡប់ទៅក្នុងពន្ធនាគារវិញ។ ឧទាហរណ៍៖ តាមរយៈការដោះលែងឲ្យមាន

សេរីភាព ឬដាក់នៅក្រោមការត្រួតពិនិត្យរបស់តុលាការ ដែលជាជម្រើសមួយត្រូវតែបានអនុវត្ត។ អាចអនុវត្តបានដូចគ្នានេះ ដូចគ្នានៅអ.វ.ត.ក ដោយសារតែគោលការណ៍នេះត្រូវបានទទួលស្គាល់នៅក្នុងមាត្រា៩(៣) នៃ *អាយ.ស៊ី.ស៊ី.ភី.អ័រ (ICCPR)*។

[១០:២៨:១២]

មាត្រា៩(៣) ចែងថា "ការឃុំខ្លួនមនុស្សដើម្បីរង់ចាំការជំនុំជម្រះក្តី មិនមែនវិធានការទូទៅទេ" បទប្បញ្ញត្តិនេះត្រូវបានគាំទ្រដោយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានិងវិធានផ្ទៃក្នុង ឧទាហរណ៍៖ វិធាន៦៨ ចែងពីអានុភាពបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន ហើយមាត្រា២៤៩ នៃនីតិវិធីក្រមព្រហ្មទណ្ឌកម្ពុជា ចែងពីការដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំដោយឯងៗ បន្ទាប់ពីផុតកំណត់នៃរយៈពេលបួនខែ។

ចំណុចបង្ហាញពីភាពលម្អៀង ចំពោះស្ថានភាពដែលជនជាប់ចោទអាចត្រូវផ្តល់សិទ្ធិ ដោះលែងជាបណ្តោះអាសន្ន ប្រសិនបើបន្ទាប់ពីការ-- ពីដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយអង្គបុរេជំនុំជម្រះកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១។ អង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក បច្ចុប្បន្នកំពុងកាន់សំណុំរឿងសាលាដំបូងនៃអ.វ.ត.ក អាចគ្រប់គ្រង-- អាចគ្រប់ពេលនៃកិច្ចដំណើរការនីតិវិធីដោះលែងជនជាប់ចោទ។ ជនជាប់ចោទក៏អាចស្នើដល់អង្គបុរេ-- អង្គសាលាដំបូងជំនុំជម្រះនៃអ.វ.ត.ក ឲ្យដោះលែងខ្លួនបាន។

ការបកស្រាយសមស្របថាសំណើបែបនេះអាចដាក់គ្រប់ពេលនៃកិច្ចដំណើរការនីតិវិធី។ អាស្រ័យហេតុនេះ សំណើនេះអាចទទួលយកបាន។

[១០:៣០:០០]

អនុលោមតាមវិធាន ៦៨(៣) ដីកាចុះចុងក្រោយរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបន្តឃុំខ្លួន នួន ជា អស់អានុភាពសម្រាប់រយៈពេលបួនខែ បន្ទាប់ពីកាលបរិច្ឆេទចេញដីកាដំណោះស្រាយរបស់ខ្លួននៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ លុះត្រាតែជនជាប់ចោទត្រូវបាននាំខ្លួនទៅអង្គជំនុំជម្រះសាលាដំបូងនៅមុនរយៈពេលនេះ នួន ជា បាននាំខ្លួនទៅ-- បាននាំខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលបួនខែនេះ។ ដូច្នេះ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លែងមានអានុភាពតទៅទៀតហើយ។ អនុលោមតាមច្បាប់ដដែលនេះ ប្រសិនបើដីកាដំណោះស្រាយត្រូវបានប្តឹងឧទ្ធរណ៍ការបន្តការឃុំខ្លួនបណ្តោះអាសន្នអាចពន្យារពេលទៀតបានដោយសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍។

[១០:៣១:០៧]

អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចបែបនេះនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ក៏ប៉ុន្តែ សេចក្តីសម្រេចនេះមិនអាចចាត់ទុកថាជាសេចក្តីសម្រេចឡើយ នៅក្រមវិធាន ៦៨(២) និង (៣) នឹង ត្រូវតែចាត់ទុកថា មិនអាចទទួលយកបាន។ វិធាន៧៧ ចែងថា រាល់សេចក្តីសម្រេចរបស់អង្គបុរេជំនុំ ជម្រះត្រូវបានសំអាងហេតុ តែសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពុំមានសំអាងហេតុទេ។ ផ្ទុយទៅវិញ សេចក្តីសម្រេចលើកឡើងថា ការចេញសំអាងហេតុសម្រាប់គាំទ្រសាលដីកានេះនឹងធ្វើទៅតាមពេល វេលាសមស្រប។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលមិនមានសំអាងហេតុ គឺចាត់ទុកថាមិន មានជាសេចក្តីសម្រេចដូចដែលបង្កើតដោយវិធាន។

[១០:៣២:០១]

អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះមិនទាន់អាចត្រូវបានចាត់ទុកថា បានចេញសេចក្តីសម្រេច លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដូចដែលបានតម្រូវដោយវិធាន និងមិនទាន់បានពន្យារ ការឃុំខ្លួនបណ្តោះអាសន្ននៅឡើយទេ។ និយាយម្យ៉ាងទៀតថា សេចក្តីសម្រេចដែលចេញដោយអង្គបុរេ ជំនុំជម្រះនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ មិនបានផ្តល់មូលហេតុច្បាប់គ្រប់គ្រាន់សម្រាប់ការឃុំខ្លួន បណ្តោះអាសន្នលើ នួន ជា បានឡើយ ដោយសារសេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើប អង្កេតបន្តឃុំខ្លួន នួន ជា បានអស់អានុភាពនៅត្រឹមថ្ងៃទី១៥ ខែមករា ឆ្នាំ២០១១ ហើយអង្គបុរេជំនុំ ជម្រះមិនបានចេញសេចក្តីសម្រេច អនុលោមតាមនិយមន័យលើលក្ខខណ្ឌនេះនៅក្រោមវិធាន។ ដូចនេះ ការបន្តឃុំខ្លួនបណ្តោះអាសន្នលើរូបគាត់ គឺខ្វះមូលដ្ឋានច្បាប់គ្រប់គ្រាន់ និងគ្រាន់តែ-- និងគាត់ត្រូវតែ បានដោះលែង។

[១០:៣៣:១២]

ហេតុផលតែមួយគត់ដែលថា សេចក្តីសម្រេចនេះមិនមានសំអាងហេតុគ្រប់គ្រាន់ដើម្បីសន្និដ្ឋាន ថា នេះមិនមែនជាសេចក្តីសម្រេចដោយអនុលោមតាមវិធាន និងថា នួន ជា ត្រូវតែបានដោះលែង។ សេចក្តីសន្និដ្ឋាននេះក៏គាំទ្រដោយ ប៉ុន្តែមិនពឹងផ្អែកលើមូលដ្ឋានដែលថា សកម្មភាពរបស់អង្គបុរេជំនុំ ជម្រះបង្ហាញពីការមិនគោរពយ៉ាងច្បាស់លើគោលការណ៍ដំណោះស្រាយខ្ពស់បំផុត និងដូចនេះហើយក៏ មិនគោរពដល់សិទ្ធិរបស់លោក នួន ជា ដែរ។ នៅក្នុងភាពយុត្តិធម៌ គឺមិនអាចបដិសេធបានទេដែលថា អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចក្នុងរយៈពេលបួនខែ ដើម្បីបញ្ចៀសការដោះលែង នួន ជា

ដោយស្វ័យប្រវត្តិ វាជាហេតុផលល្អឥតខ្ចោះសម្រាប់អង្គបុរេជំនុំជម្រះ ចេញសេចក្តីសម្រេចមួយដែលមានទស្សនៈរបស់ខ្លួន ដើម្បីការពារមិនឲ្យមានការដោះលែងជនជាប់ចោទ ដែលគួរតែនៅបន្តឃុំខ្លួនបណ្តោះអាសន្ន។

[១០:៣៤:២៣]

ការធ្វើដូច្នេះ គឺជាការមិនសមហេតុផលទាល់តែសោះ ដោយសារផ្ទុយនឹងកាតព្វកិច្ចច្បាស់លាស់របស់វិធានដែលគ្រប់គ្រងអង្គជំនុំជម្រះនេះ។ ការចេញសេចក្តីសម្រេចបែបនេះក្នុងស្ថានភាពបែបនេះបង្កើតបានជាការរំលោភអំណាចដោយអង្គជំនុំជម្រះនេះ។ វិធីធ្វើឡើងអង្គបុរេជំនុំជម្រះខកខានក្នុងការទទួលស្គាល់ថា ពេលវេលាកំណត់ដ៏រឹតត្បិតក្នុងវិធាន៦៨ មានជាសំខាន់សម្រាប់ការការពារជនជាប់ចោទ ដែលការកំណត់ពេលវេលាបែបនេះបង្ហាញពីសិទ្ធិរបស់គាត់ក្នុងការទទួលបានការកាត់ក្តីដោយពេលវេលាសមស្រប ហើយសំខាន់ទៀតនោះ គឺគោរពតាមគោលការណ៍ឃុំខ្លួនបណ្តោះអាសន្ន ដូចមានក្នុងដំណោះស្រាយខ្ពស់បំផុត ជនជាប់ចោទត្រូវ-- សុំទោស-- ជនជាប់ចោទមានសិទ្ធិទទួលបានសេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ខ្លួនក្នុងរយៈពេលបួនខែ ព្រោះតែការឃុំខ្លួនបណ្តោះអាសន្ន គឺជាបន្ទុកដ៏ធ្ងន់លើបុគ្គលមួយ និងមិនត្រូវចាត់ទុកថាមិនមែនធម្មតាទេ ប៉ុន្តែខុសពីធម្មតា។

[១០:៣៥:៤៥]

វិធានដែលអនុវត្តដោយអង្គបុរេជំនុំជម្រះនាំទៅរកលទ្ធផលផ្ទុយនឹងច្បាប់ អង្គបុរេជំនុំជម្រះចាំបាច់ត្រូវតែចេញសេចក្តីសម្រេចក្នុងរយៈពេលបួនខែ តាមរយៈច្បាប់ដែលមានគោលបំណងការពារផលប្រយោជន៍ជនជាប់ចោទ ក្នុងការព្យាយាមដើម្បីគោរពពេលកំណត់នេះ ខ្លួនបានធ្វើឲ្យប៉ះពាល់ផលប្រយោជន៍ជនជាប់ចោទទៅវិញ តាមរយៈការចេញសេចក្តីសម្រេចដោយមិនមានសំអាងហេតុ ដោយមិនគោរពដល់បញ្ញត្តិ និងគោលគំនិតនៃវិធានផ្ទៃក្នុងនៅក្នុងការប៉ុនប៉ងដើម្បីធានាដល់ការពន្យារពេលឃុំខ្លួនបណ្តោះអាសន្នដែលគាត់នឹងត្រូវបានដោះលែង បើពុំមានសេចក្តីសម្រេចបែបនេះ។

[១០:៣៦:៣៥]

ការអនុវត្តរបស់អង្គបុរេជំនុំជម្រះ បង្ហាញពីការយល់មិនត្រឹមត្រូវលើគោលការណ៍ដំណោះស្រាយខ្ពស់បំផុតដូចបានបង្ហាញនៅមាត្រា៦៨។ ការឃុំខ្លួនបណ្តោះអាសន្ន គឺមិនមែនដើម្បីតែឃុំខ្លួននោះទេ ប៉ុន្តែអង្គបុរេជំនុំជម្រះ ព្រមទាំងការិយាល័យសហចៅក្រមស៊ើបអង្កេតតែងតែធ្វើដូចនេះ។ សំខាន់ជាង

នេះទៅទៀត ចំពោះការបន្តរក្សាឃុំខ្លួនលោក នួន ជា គឺថាខ្លួនបានអនុវត្តក្នុងរបៀបស្រដៀងគ្នានេះនៅក្នុងអំឡុងពេលប៉ុន្មានខែរហូតដល់ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០។ ក្នុងរយៈពេលនោះខ្លួនបានចាប់ផ្តើមទទួលយកអនុវត្តចេញសេចក្តីសម្រេច ដោយមិនមានសំអាងហេតុ-- ដោយចេញសំអាងហេតុនៅពេលក្រោយ បើទោះជាគ្មានវិធានការមួយអនុញ្ញាតលទ្ធភាពបែបនេះក៏ដោយ បើទោះជាមិនត្រូវបានអះអាងជាក់ស្តែងណាមួយក៏ដោយ ប៉ុន្តែជាការច្បាស់ណាស់សម្រាប់គ្រប់ភាគីទាំងអស់ថា ខ្លួនធ្វើបែបនេះត្រូវការប៉ុនប៉ងអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយនៅមុនថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១០ ជាថ្ងៃដែល នួន ជា នឹងត្រូវបានឃុំខ្លួនសម្រាប់រយៈពេលបីឆ្នាំ នឹងត្រូវបានដោះលែងបើពុំមានដីកាដំណោះស្រាយ។

[១០:៣៨:០៥]

ភាពមមាញឹកក្រៃលែងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងការចេញដីកាដំណោះស្រាយក្នុងរយៈពេលបីឆ្នាំនេះបង្ហាញការគោរពមិនត្រឹមត្រូវលើគោលការណ៍ដំណោះស្រាយខ្ពស់បំផុត។ ការយកចិត្តទុកដាក់ជាចម្បងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងការអនុវត្តការស៊ើបអង្កេតរបស់ខ្លួនគួរតែត្រូវបានបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួនតាមរបៀបអាចទទួលយកបាន ជាជាងការប្រឹងប្រែងឲ្យបានចប់ការស៊ើបអង្កេតក្នុងរយៈពេលបីឆ្នាំ ដែលបានទៅដៅទុកដើម្បីការពារមិនឲ្យមានការដោះលែង នួន ជា។

អង្គបុរេជំនុំជម្រះបន្ទាប់មកបន្តការគាំទ្រការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងការយល់មិនត្រឹមត្រូវនេះ ដោយចេញសេចក្តីសម្រេចមិនមានសំអាងហេតុ ឬអាចនិយាយថា នេះមិនមែនជាលើកដំបូងទេ ដែលអង្គបុរេជំនុំជម្រះបានជ្រើសរើសការអនុវត្តការអានមិនសុក្រឹតនូវវិធាន ដើម្បីសម្រួលដល់ការបន្តឃុំខ្លួនលោក នួន ជា។

[១០:៣៩:១៨]

ជាថ្មីម្តងទៀត ផ្ទុយទៅវិញមេធាវីការពារក្តីមិនអះអាងថា ការពន្លឿនផ្នែកយុត្តិធម៌មិនមែនជាអ្វីដែលត្រូវតែសោកស្តាយនោះទេ តែការពន្លឿនផ្នែកយុត្តិធម៌ជាមួយនឹងគោលបំណងតែមួយគត់ក្នុងការរក្សាជនជាប់ចោទនៅក្នុងមន្ទីរឃុំឃាំង នឹងមិនអើពើទាល់តែសោះចំពោះបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង ផលប្រយោជន៍របស់ជនជាប់ចោទ គោលការណ៍ដំណោះស្រាយខ្ពស់បំផុតត្រូវបានគោរពយ៉ាងត្រឹមត្រូវតាមច្បាប់ ប្រសិនបើគោលបំណងមួយរបស់តុលាការនេះ គឺស្តារឡើងវិញនូវទំនុកចិត្តចំពោះនីតិរដ្ឋ

តុលាការនេះត្រូវគោរពវិធានរបស់ខ្លួន និងមិនត្រូវពាក់ព័ន្ធជាមួយនឹងការអនុវត្តវិធានដែលមានលក្ខណៈប្រឌិត និងខូចប្រយោជន៍របស់ជនជាប់ចោទឡើយ។

[១០:៤០:១៥]

មូលដ្ឋានដាច់ដោយឡែកសម្រាប់សំណើសុំដោះលែងជាបន្ទាន់ ដោយសារតែសេចក្តីសម្រេចមិនមានសំអាងហេតុជាក់លាក់ទៅនឹងមូលដ្ឋាន និងមូលហេតុសម្រាប់ការបន្តឃុំខ្លួន បើទោះជាវិធានមិនចែងច្បាស់ឲ្យអង្គបុរេជំនុំជម្រះផ្តល់សំអាងហេតុសម្រាប់ការឃុំខ្លួនបន្តក៏ដោយ ក៏កាតព្វកិច្ចបែបនេះមាននៅក្នុងប្រព័ន្ធវិធានផ្ទៃក្នុងដែលត្រូវចាត់ទុកថា សម្រាប់អនុវត្តគ្រប់វិធានទាំងអស់។ អនុលោមតាមវិធានរាល់សេចក្តីសម្រេចផ្សេងទៀត លើការឃុំខ្លួនបណ្តោះអាសន្នត្រូវតែមានសំអាងហេតុ។ អនុលោមតាមគោលការណ៍និត្យានុកូលភាព គ្មានហេតុផលជាគោលការណ៍អនុញ្ញាតឲ្យអង្គបុរេជំនុំជម្រះមិនគោរពតាមតម្រូវការដូចគ្នានូវគោលការណ៍ដំណោះស្រាយខ្ពស់បំផុតនោះទេ និងតម្រូវការដើម្បីចេញសេចក្តីសម្រេចមានសំអាងហេតុក្នុងលក្ខខណ្ឌទូទៅ។

[១០:៤១:១៨]

អាស្រ័យហេតុនេះ ការពិតដែលថា អង្គបុរេជំនុំជម្រះមិនគ្រាន់តែខកខានមិនបានផ្តល់សំអាងហេតុលើសេចក្តីសម្រេចប៉ុណ្ណោះទេ តែថែមទាំងខកខានមិនបានផ្តល់ហេតុផលណាមួយ សម្រាប់សមាសភាពការឃុំខ្លួនបណ្តោះអាសន្ន និងថែមទាំងគាំទ្រសេចក្តីសន្និដ្ឋានរបស់-- បន្តឃុំខ្លួនលោក នួន ជា ដែលខ្វះមូលដ្ឋានច្បាប់គ្រប់គ្រាន់។ ការបន្តឃុំខ្លួនលោក នួន ជា បន្ថែមទៀតប្រាកដជាខុសច្បាប់ ដោយសារតែគ្មានមូលដ្ឋានច្បាប់ជាធរមាន សម្រាប់ការឃុំខ្លួនបន្ត។ ដូចនេះការដោះលែងលោក នួន ជា ជាបន្ទាន់គឺជាជម្រើសផ្លូវច្បាប់តែមួយគត់។

[១០:៤២:០៧]

ទីបញ្ចប់ អាស្រ័យហេតុដូចជម្រាបហេតុផលខាងលើ ខ្ញុំបាន-- ខាងលើប៉ុន្មានមកនេះមេធាវីការពារក្តីស្នើសុំតុលាការសាលាដំបូងនៃអង្គជំនុំជម្រះ នៃអ.វ.ត.ក ចេញដីកាដោះលែងលោក នួន ជា ជាបន្ទាន់ដើម្បីបង្ហាញឲ្យឃើញជាក់លាក់ថា តុលាការ អ.វ.ត.ក បានអនុវត្តនូវនីតិវិធីនៃច្បាប់របស់ខ្លួនប្រកបដោយយុត្តិធម៌ សីលធម៌ និងសច្ចធម៌ ហើយដោយមិនរំលោភលើសិទ្ធិរបស់កូនក្តីរបស់ខ្ញុំជាជនត្រូវចោទផងនោះទេ។

ខ្ញុំសូមអរគុណលោកប្រធាន និងសូមអរគុណក្រុមប្រឹក្សាជំនុំជម្រះ។ សូមអស់។

[១០:៤២:៥១]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះសាលាដំបូងប្រកាសសម្រាករយៈពេល២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោង១១ សូមអញ្ជើញចូលមកវិញដើម្បីបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សូមអញ្ជើញសម្រាក។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ ឲ្យរូតវាំងននបិទភ្លាមបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងចេញផុតពីបន្ទប់សវនាការ ហើយនិងឲ្យបើកវិញនៅបានមុនពេលអង្គជំនុំជម្រះចូលត្រលប់មកកាន់សាលសវនាការវិញ។

សូមអញ្ជើញ!

[១០:៤៣:២៣]

**លោក សុន អរុណ៖**

សូមៗថែមមួយម៉ាត់ទាន។ សូមទោស! កូនក្តីខ្ញុំបាទឥឡូវនេះនៅបន្ទប់បណ្តោះអាសន្ន ពេទ្យកំពុងមើល ប៉ុន្តែក្នុងនេះពេទ្យគេបានសុំការអនុញ្ញាតពីខាងតុលាការ ដើម្បីបញ្ជូនទៅកាន់មន្ទីរឃុំឃាំងវិញ ពីព្រោះអីស្ថានភាពគាត់ដូចជាមិនល្អ អានេះតាមពេទ្យគេស្នើមកតាមរយៈខ្ញុំបាទ។

**ប្រធានអង្គជំនុំ៖**

អូខេ អ៊ីចឹងខ្ញុំសម្រេចចិត្តថា គាត់មិនធ្វើការថ្លែងការណ៍បន្ថែមលើសេចក្តីថ្លែងការណ៍របស់មេធាវីទេ អ៊ីចឹងអ្វែស?

[១០:៤៣:៥៩]

**លោក សុន អរុណ៖**

បាទ។

**ប្រធានអង្គជំនុំ៖**

បានន័យថា គាត់បោះបង់សិទ្ធិ ហើយគាត់សុំត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ។

អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតតាមការស្នើសុំនេះ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនៃ អ.វ.ត.ក នាំជនជាប់ចោទឈ្មោះ នួន ជា ដែលគាត់មានបញ្ហាសុខភាពហ្នឹងឲ្យនាំគាត់ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤៥នាទី ដល់ម៉ោង១១:០៨)*

[១១:០៨:២៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ អស់លោក លោកស្រី អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្ត កិច្ចដំណើរការពិភាក្សាដេញដោលលើសំណើសុំរបស់មេធាវីការពារក្តីតទៅទៀត។ ហើយជាបន្ទាប់នេះ សូមអញ្ជើញលោកមេធាវី ស សូវាន ឡើងធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់អំពីការស្នើសុំមូលហេតុ ព្រមទាំងសំអាងហេតុនៃការស្នើសុំដោះលែងលោក ខៀវ សំផន ដែលជាកូនក្តីរបស់លោកជាបន្ទាន់។ សូមអញ្ជើញ!

[១១:០៩:១៣]

**លោក ស សូវាន៖**

សូមអរគុណលោកប្រធាន។ សូមអរគុណសមាជិកចៅក្រម។ សូមអរគុណ ដែលបានអនុញ្ញាតឲ្យខ្ញុំធ្វើសេចក្តីថ្លែងហេតុដើម្បីការពារកូនក្តីរបស់ខ្ញុំ។ សូមថ្លែងអំណរគុណនិងគោរពសមាជិកអយ្យការនៅមុខខ្ញុំ និងសហភាតាខ្ញុំ និងមហាជនទាំងអស់។

ថ្ងៃនេះ គិតមកដល់ថ្ងៃនេះ កូនក្តីខ្ញុំជាប់ពន្ធនាគារបណ្តោះអាសន្ន បីឆ្នាំ បួនខែ ដប់បួនថ្ងៃ។ អង្គបុរេជំនុំជម្រះបានលើកចោលបណ្តឹងឧទ្ធរណ៍ដើម្បីដោះលែងកូនក្តីខ្ញុំ ហើយបានបញ្ជូនកូនក្តីខ្ញុំតាមដីកាចុះថ្ងៃ១៣ ខែមករា មកឲ្យសាលាដំបូងជំនុំជម្រះនៅពេលនេះ។

[១១:១០:២៧]

ខ្ញុំសូមលើកចំណុចតែពីរទេ ដើម្បីការពារ ថាសុំឲ្យដោះលែងជាស្វ័យប្រវត្តិ មិនប៉ានប្រើពាក្យជាបន្ទាន់។ ចាំជជែកបន្តិច។ ហើយខ្ញុំសូមកត់សម្គាល់អ៊ីចេះ ពីព្រោះខ្ញុំបានទទួលសាលដីកា-- សូមទោស-- ខ្ញុំបានទទួលដីការបស់សាលាជំនុំជម្រះសួរខ្ញុំពីរ។ ពីរសំណួរ។ ខ្ញុំសូមអាន សួរខ្ញុំពីរសំណួរថា តើអ្វីដែលជាការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ ដោយសារតែសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃ១៣ ខែមករា ២០១១ មិនមានសំអាងមូលហេតុ?

[១១:១១:១២]

នៅត្រង់កន្លែងនេះ ខ្ញុំចំពោះកូនក្តីខ្ញុំ លោកប្រធានរដ្ឋ លោក ខៀវ សំផន ក៏គេមិន-- អង្គបុរេជំនុំជម្រះមិនបានសំអាងហេតុដែរ។ ដូច្នេះ ខ្ញុំគ្រាន់តែកត់សម្គាល់ថា កាលដែលមិនសំអាងហេតុនេះមានកំហុសវិធី ដូចសហភាតាលោក សុន អរុណ គាត់មានប្រសាសន៍។ ចំពោះខ្ញុំ ខ្ញុំមិនយកជាចំណុចធំទេ ខ្ញុំនឹងជម្រាប។ ប៉ុន្តែសំណួរនេះ មិនពាក់ព័ន្ធនឹងការលើកចោលបណ្តឹងឧទ្ធរណ៍របស់ខ្ញុំទេ។

ខ្ញុំតទៅទៀត សំណួរទីពីរ ហេតុអ្វីបានជាអ្នកនិយាយថាការដោះលែងភ្លាមៗ គឺជាសំណងមួយដ៏សមរម្យសម្រាប់ដោះស្រាយនូវការរំលោភសិទ្ធិរបស់ជនជាប់ចោទ?

[១១:១២:១៦]

នៅក្នុងបណ្តឹងឧទ្ធរណ៍ខ្ញុំ ទោះបីជាបារាំងក្តី ខ្មែរក្តី ខ្ញុំមិនបានទាមទារសំណង ពីព្រោះឥឡូវខ្ញុំកត់សម្គាល់ថា កូនក្តីខ្ញុំជាប់ឃុំឃាំងបណ្តោះអាសន្នហ្នឹងលើសបួនដណ្តប់ថ្ងៃ(១៤ថ្ងៃ)។ តាមទស្សនៈរបស់ខ្ញុំគឺថា ជាប់ឃុំឃាំងនេះខុសច្បាប់ ប៉ុន្តែរឿងខុសរឿងត្រូវច្បាប់ខ្ញុំសូមជម្រាបក្រោយ។ ហើយខ្ញុំជម្រាបអង្គជំនុំជម្រះថា ខ្ញុំអត់ទាមទារ កូនក្តីខ្ញុំអត់មានទាមទារ នែ៎ៗជាថ្នូរ បួនដណ្តប់ថ្ងៃហ្នឹងជាថ្នូរការដោះលែងទេ។ នេះទីមួយ។

[១១:១២:៥៥]

ឥឡូវខ្ញុំសូមជម្រាបយ៉ាងខ្លី ពីព្រោះកាន់តែនេះហើយ នែ៎!ចំណុចខ្ញុំពីរ។ ឥឡូវហ្នឹងខ្ញុំនិយាយអំពីចំណុចបន្ទាប់បន្សំនេះ។ នៅក្នុងដីកាលើកលែង នែ៎!ពាក្យបណ្តឹងឧទ្ធរណ៍របស់ខ្ញុំ ដូចខ្ញុំជម្រាបអ៊ីចឹងគ្មាននែ៎-- គេហៅថាគ្មាន-- បារាំងគេហៅថា *ម៉ូទីវ៉ាហ្សុង* គ្មានមូលហេតុ។ ខ្ញុំគ្រាន់ថា កាលណាវិធានគេឲ្យមាន-- កាលណាដីការបស់អង្គបុរេជំនុំជម្រះគ្មានមូលហេតុ គេថាខុសនឹងទម្រង់។ រាល់សេចក្តីសម្រេចរបស់តុលាការ កាលណាខុសនឹងទម្រង់វាអាចក្លាយទៅជាមោឃៈ។ ប៉ុន្តែ ខ្ញុំមិនគិតទាមទាររកមោឃៈអីទេ ខ្ញុំគ្រាន់ថាជានេះបន្ទាប់បន្សំ។

[១១:១៣:៥១]

អ្វីដែលសំខាន់ចំណុចទីពីរនេះ ខ្ញុំជម្រាបថា សហចៅក្រមស៊ើបអង្កេតបានដាក់កូនក្តីខ្ញុំ បីឆ្នាំបួនខែ បើយើងគិតពីថ្ងៃគាត់ត្រូវគេចាប់។ បើយើងគិត ហើយបើយើងគិតថា ចុងក្រោយបំផុតគេចាប់គាត់ថ្ងៃដប់មួយ ខែមួយដណ្តប់ (ខែ១១) ដូចជាប៉ុន្មានមើល៍ ពីរពាន់ប្រាំបី-- ពីរពាន់ប្រាំពីរ។

ឥឡូវនេះ គេពន្យារគាត់បួនខែទៀត បើយើងគិតថា ពេលដែលថ្ងៃពន្យារគាត់បួនខែទៀតហ្នឹងគឺថាសហចៅក្រមស៊ើបអង្កេតគេមានលក្ខណៈ គេមានសិទ្ធិនឹងពន្យារគាត់បួនខែតទៀត។ បួនខែតទៀត

បើខ្ញុំគិតទៅថ្ងៃ១៦ ខែ៩ ២០១០ មកដល់ថ្ងៃ១៦ ខែ១ ពី២០១១ វាបួនខែហើយ។ ថ្ងៃ១៦ ខែមករា ២០១១ វាបួនខែ។

[១១:១៥:០៥]

នៅក្នុងវិធានផ្ទៃក្នុងមាត្រា៦៨(១) និងវិធានផ្ទៃក្នុងមាត្រា៦៨(៣) គេបានចែងយ៉ាងច្បាស់ថា លោកចៅក្រម សហចៅក្រមស៊ើបអង្កេតអាចដាក់ពន្ធារបួនខែ ក៏ប៉ុន្តែនៅក្នុងរយៈបួនខែនេះ កាលណាមិនបានកោះហៅកូនក្តីខ្ញុំទៅឲ្យបង្ហាញមុខ គឺថានៅក្នុងរយៈបួនខែ បើយើងគិតថាថ្ងៃ១៣ មកថ្ងៃ១៦ អត់មានហៅកូនក្តីខ្ញុំឡើងទៅតុលាការទេ។ ដូច្នេះ ចាប់តាំងពីថ្ងៃ១៦ គឺថាបួនខែនោះវាចប់ហើយ។ ដូច្នេះ គាត់ត្រូវលែងពីថ្ងៃ១៦ ខែ១ ឆ្នាំ២០១១។ ដូច្នេះ យើងគិតរាប់ថាពីថ្ងៃ១៧ នេះ ខែ១ ២០១១ មករហូតដល់ថ្ងៃនេះ ថ្ងៃ៣១ ខែ០១ ឆ្នាំ២០១១ មាន១៤ថ្ងៃ។ ដូច្នេះ មេធាវីខ្ញុំថាមិនបាច់រៀបរាប់អំពីវិធាន ដូចខ្ញុំជម្រាបអំមិញអ៊ីចឹងថា វាលើសពី-- លើសពីរសប្តាហ៍ ខ្ញុំក៏មិនសុំ ន៎!ទាមទារជាថ្នូរអ្វីដែរ ហើយខ្ញុំមានជំនឿថាអស់លោកសមាជិកក្រុមប្រឹក្សាជំនុំជម្រះ ជាពិសេសលោកប្រធានគ្មានប្រយោជន៍អ្វី នឹងធ្វើបាបកូនក្តីខ្ញុំទេ។ ខ្ញុំសូមឲ្យលោកមេត្តាពិចារណាពីរឿងវិធាននៃច្បាប់ដែលគ្រប់គ្រងមេធាវីក្តី គ្រប់គ្រងចៅក្រម លោកប្រធាន គ្រប់គ្រងទាំងអស់ដើម្បីស្វែងរកយុត្តិធម៌។

[១១:១៧:១២]

ដូច្នេះ ខ្ញុំមិនបាច់និយាយអីទៀតទេ ពីព្រោះនៅក្នុងនីតិវិធីក្រមអាជ្ញាបច្ចុប្បន្ននេះដែលទើបនឹងអនុវត្ត ក៏គេមានចែងនៅក្នុងមាត្រា២៤៩។ ឃើញទេ! គេថាត្រូវតែដោះលែង បើកាលណានៅក្នុងរយៈពេលឃុំបន្ថែមបួនខែនេះ នៅក្នុងរយៈពេលហ្នឹង មិនបានកោះហៅកូនខ្ញុំទៅបង្ហាញនៅអង្គបុរេជំនុំជម្រះក្តីអង្គសាលាដំបូងក្តី គឺថាត្រូវតែលែងជាស្វ័យប្រវត្តិ។

[១១:១៧:៥០]

ដូច្នេះ វិធានផ្ទៃក្នុងគ្រប់គ្រងតុលាការនេះ និងច្បាប់នីតិវិធីអាជ្ញាដែលទើបតែនឹងឲ្យអនុវត្តក៏និយាយដូចគ្នាដែរ។ ដូច្នេះ ខ្ញុំសូមលោក-- អង្គសាលាដំបូងជំនុំជម្រះ មេត្តាពិចារណារឿងច្បាប់។ ខ្ញុំសូមឲ្យដោះលែងកូនក្តីខ្ញុំថ្ងៃនេះ ម៉ោងនេះ ពីព្រោះការដាក់បន្តទៅទៀតគ្មានច្បាប់អីដាក់តទៅទៀតទេ។ ខ្ញុំមិនចេះអីក្រៅច្បាប់ ខ្ញុំចេះតែច្បាប់ ន៎! ខ្ញុំសូមថា បើច្បាប់យើងសរសេរ យើងបកស្រាយមិនត្រូវគ្នាម៉េច អាហ្នឹងយើងជជែកនៅពេលនេះ។ ខ្ញុំជជែករឿងថា ដាក់កូនក្តីខ្ញុំមកដល់ថ្ងៃនេះខុស ខុសច្បាប់បួនដណ្តប់ថ្ងៃហើយ។ ហើយមិនទាមទារអីទេ សូមឲ្យតែលែងភ្លាម។ បើកាលណាលែងភ្លាម មាន

ន័យថា តុលាការនេះគោរពច្បាប់។ ហើយខ្ញុំហ្នឹងទៀត សូមបញ្ជាក់ សាធារណជន មិនមែនថា លែងហើយឲ្យគាត់រួចខ្លួនទេ ពីព្រោះយើងដាក់បណ្ដោះអាសន្នហ្នឹង វាបីឆ្នាំ បួនខែហើយ។ រួចយើងចេះតែដំណើរការយូរពេក ចេះតែដាក់រហូតម៉េច លែងឲ្យមានសេរីភាព។ លើកលែងតែគាត់លែងទៅ គាត់មានធ្វើបទល្មើសអីទៀត លោកប្រធាននិងអង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិចាប់គាត់មកវិញ បណ្ដោះអាសន្នទៀតទៅ។ ទម្រាំតែយើងរែកញែករកហេតុផលថាគាត់ត្រូវយ៉ាងម៉េច?

សូម្បីតែគាត់រាល់ថ្ងៃហ្នឹង គេទុកជាជនមិនទាន់ពិរុទ្ធទេ បើជាប់ពិរុទ្ធនៅត្រង់កន្លែងក្រចកសេះនេះហើយ។

[១១:១៩:៣១]

ដូច្នេះ មុននឹងចប់ ខ្ញុំសុំ សុទ្ធតែអស់លោកសាលាច្បាប់ សាកលវិទ្យាល័យពេញពិភពលោកព្រោះតែរឿងច្បាប់មួយ សូមមេត្តាបកស្រាយឲ្យកូនក្ដីខ្ញុំទទួលបានយុត្តិធម៌។ ខ្ញុំគ្មានពេលនឹងជជែកពីរឿងមិនប្រក្រតីអង្គបុរេជំនុំជម្រះទេ ពីព្រោះឥឡូវវាបីឆ្នាំបួនខែហើយ ជិតចូលឆ្នាំចិនហើយ ខ្ញុំមិនមែនចិនទេ។ ក៏ប៉ុន្តែ សូមមេត្តាថ្ងៃហ្នឹង ម៉ោងហ្នឹង ហើយបើនៅដាក់តទៅទៀត គឺខុសច្បាប់។

សូមអរគុណលោកប្រធាន។ សូមអរគុណអ្នកទាំងអស់គ្នា។

[១១:២០:០២]

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី ស សូវាន។ ជាកិច្ចបន្ត សូមអញ្ជើញលោកមេធាវី ផាត់ ពៅស៊ាង ឡើងធ្វើសេចក្ដីសន្និដ្ឋានបញ្ជាក់អំពីប្ដឹងសំណើសុំ មូលហេតុ និងសំអាងហេតុនៃការស្នើសុំឲ្យដោះលែងកូនក្ដីរបស់លោក។ សូមអញ្ជើញបាទ!

[១១:២០:២៨]

**លោក ផាត់ ពៅស៊ាង៖**

សូមគោរពអង្គជំនុំជម្រះសាលាដំបូងជាទីគោរព សូមគោរពអង្គសវនាការទាំងមូល។ ខ្ញុំបាទឈ្មោះ ផាត់ ពៅស៊ាង ជាមេធាវីការពារក្ដីឲ្យអ្នកស្រី អៀង ធីរិទ្ធ។ ខ្ញុំបាទសូមអនុញ្ញាត ធ្វើសេចក្ដីថ្លែងការណ៍ការពារក្ដីជុំវិញ ដែលហៅថា សំណួរនៅក្នុងសេចក្ដីសម្រេចលេខ E26 ចុះថ្ងៃទី២៧ មករា ២០១១ របស់អង្គជំនុំជម្រះសាលាដំបូង។

[១១:២១:១៥]

ជុំវិញបញ្ហាទាក់ទងដល់កូនក្តីខ្ញុំបាទ អៀង ធីរិទ្ធិ នេះ គឺខ្ញុំបាទសូមអនុញ្ញាតជម្រាបជូនអង្គសវនាការមេត្តាជ្រាបថា កូនក្តីខ្ញុំបាទ អៀង ធីរិទ្ធិ នេះ ត្រូវបានអង្គជំនុំជម្រះវិសាមញ្ញនៃ-- យើងនិយាយរួមថា អ.វ.ត.ក បានចាប់ខ្លួននៅថ្ងៃទី១២ ខែ១១ ឆ្នាំ២០០៧។ បន្ទាប់មក គឺនៅថ្ងៃទី១៤ ខែ១១ ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក គឺអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានសម្រេចឃុំខ្លួន។

ហើយបើយើងគិតអំពីការហៅថា ការឃុំខ្លួននេះ គឺដោយផ្អែកទៅតាមច្បាប់ក៏ដូចជា ផ្អែកទៅតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក គឺសហចៅក្រមស៊ើបអង្កេតមានសិទ្ធិអំណាចក្នុងការឃុំខ្លួន កូនក្តីខ្ញុំបាទមួយឆ្នាំ។ បន្ទាប់មកក៏បានបន្តរយៈពេលមួយឆ្នាំទៀត ពីរដងទៀត សរុបទាំងអស់គឺបីឆ្នាំ។ គឺហៅថា បន្ទាប់មក សហចៅក្រមស៊ើបអង្កេតបានសម្រេចនៅក្នុងដីកាដំណោះស្រាយបន្តឃុំខ្លួនកូនក្តីខ្ញុំបាទរយៈពេលបួនខែ ហើយនឹងបញ្ជូនទៅសាលាដំបូងដើម្បីជំនុំជម្រះ។ ប៉ុន្តែរហូតដល់ពេលនេះ គឺអត់-- កូនក្តីខ្ញុំបាទមិនទាន់បានទៅដល់បញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូងទេ។

[១១:២៣:០៧]

ហេតុនេះហើយបានជាគេឃើញនៅថ្ងៃទី១៣ មករា ឆ្នាំ២០១១ មានសេចក្តីសម្រេចមួយរបស់អង្គបុរេជំនុំជម្រះ គឺថាអង្គបុរេជំនុំជម្រះបានសម្រេចបន្តឃុំខ្លួនកូនក្តីខ្ញុំបាទរយៈពេលបួនខែទៀត។ ដូច្នេះបើយើងពិនិត្យមើលសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះហ្នឹង គឺអត់មានសំអាងហេតុទេ។ គឺថាបើយើងផ្អែកទៅតាមវិធាន៧៧(១៤) បានចែងយ៉ាងច្បាស់លាស់ថា សេចក្តីសម្រេចដែលគ្មានសំអាងហេតុនោះ មិនអាចទទួលយកជាការបានទេ។

ដូច្នេះ ខ្ញុំបាទបានកត់សម្គាល់ឃើញថា សេចក្តីសម្រេចរបស់បុរេជំនុំជម្រះ ដែលអត់មានសំអាងហេតុ មិនអាចទទួលយកជាការបាន ហើយឃុំខ្លួនកូនក្តីខ្ញុំបាទហ្នឹង គឺជាការរំលោភសិទ្ធិហើយ។ តាមការកត់សម្គាល់របស់ខ្ញុំបាទ គឺខ្ញុំបាទកត់សម្គាល់ឃើញអ៊ីចឹង គឺជាការរំលោភសិទ្ធិ។

[១១:២៤:៣០]

ហើយទន្ទឹមនឹងនោះ បើសិនជា-- បើយើងពិនិត្យមើលនៅក្នុងហៅថា វិធាន៦៨(៣) ហើយនឹងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ គឺបានកំណត់យ៉ាងច្បាស់លាស់ថា ការឃុំខ្លួនរយៈពេលបួនខែដោយមានសេចក្តីសម្រេច ត្រូវបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង។ ប៉ុន្តែរហូតដល់ពេលនេះ គឺថាកូនក្តីខ្ញុំបាទមិនត្រូវបានគេបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូងទេ។ ដូច្នេះខ្ញុំបាទបានពិនិត្យឃើញថា បើការឃុំខ្លួន

ដោយផ្អែកទៅតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដោយគ្មានសំអាងហេតុ គឺបានន័យថាមិនអាចយកជាការបាន គ្មានលក្ខណៈនីត្យានុកូល។

[១១:២៥:២៤]

ក្នុងករណីនេះ គឺថាជាការកត់សម្គាល់របស់ខ្ញុំបាទ ហើយក៏ជាការសំណូមពររបស់ខ្ញុំបាទដែរ គឺស្នើសុំអង្គជំនុំជម្រះតុលាការសាលាដំបូង មេត្តាពិនិត្យ ហើយដោះលែងកូនក្តីខ្ញុំបាទឲ្យមានសេរីភាព ដោយសារគ្មានលិខិត គ្មានសេចក្តីសម្រេចណាឃុំខ្លួនទេ គឺបើយើងពិនិត្យសេចក្តីសម្រេចចុងក្រោយរបស់អង្គបុរេជំនុំជម្រះគ្មានសំអាងហេតុ មិនមានសុពលទេ។ បើមិនមានសុពលអ៊ីចឹង គឺការឃុំខ្លួន បន្តឃុំខ្លួនកូនក្តីខ្ញុំបាទហ្នឹងគឺជាការរំលោភសិទ្ធិហើយ។ បើការរំលោភសិទ្ធិយ៉ាងដូច្នេះ ខ្ញុំបាទសំណូមសូមឲ្យអង្គជំនុំជម្រះសាលាដំបូងមេត្តាដោះលែងកូនក្តីខ្ញុំបាទជាបន្ទាន់ចាប់ពីពេលនេះតទៅ។ សូមអរគុណ។

[១១:២៦:០៧]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ផាត់ ពៅស៊ាង។ ជាកិច្ចបន្តហ្នឹង ដើម្បីឲ្យកាន់តែច្បាស់លាស់ថែមទៀត អង្គជំនុំជម្រះសូមសួរទៅមេធាវីការពារក្តីឲ្យជនជាប់ចោទទាំងបីនាក់ មេធាវីរបស់ នួន ជា, ខៀវ សំផន ហើយនិង អៀង ធីរិទ្ធ ថាតើលោកមេធាវីមានបំណងឡើងធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់បន្ថែមពាក់ព័ន្ធទៅនឹងខ្លឹមសារនៃវិធាន៦៣ អនុវិធាន៣ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ? ប្រសិនបើមាន សូមអញ្ជើញ!

[១១:២៧:០៨]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំលើកឡើងចំណុចមួយចំនួនតិចតែប៉ុណ្ណោះ ចំពោះវិធាន៦៣(៣) បើការបកប្រែថា វិធាន៦៨(៣)។ ប៉ុន្តែខ្ញុំសូមលើកឡើងវិញ ប្រហែលជាលើកឡើងអំពីវិធាន ៦៣(៣) ទេ។ ហេតុអ្វីខ្ញុំលើកឡើងដោយសង្ខេបទៅលើមូលដ្ឋានទាំងនោះនៅក្នុងវិធាន ដោយសារតែវាមិនចាំបាច់ក្នុងការពិចារណាទៅលើមូលដ្ឋានទាំងអស់នោះទេក្នុងការសម្រេចទៅលើសំណើសុំដោះលែងឲ្យមានសេរីភាពរបស់យើងនោះ។ ហើយវិធាន៦៣នោះ ប្រសិនបើហួសរយៈពេលបួនខែ គឺត្រូវដោះលែង មិនថាមានមូលដ្ឋាន ឬក៏យ៉ាងណានោះឡើយ។

[១១:២៧:៥៥]

ដូច្នេះហើយក្រុមមេធាវីការពារក្ដី សូមលើកឡើងថា មូលដ្ឋាននោះមិនមានទេ គឺត្រូវដោះលែងលោក នួន ជា។ ដើម្បីយកទៅជំនុំជម្រះ វាក៏គ្មានហេតុផលអ្វីដែលត្រូវការឃុំខ្លួនគាត់ដែរ។ លោក នួន ជា ចង់បង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងពន្យល់ទៅលើបញ្ហានានា។

[១១:២៨:១៨]

ចំពោះបញ្ហាសន្តិសុខរបស់ជនជាប់ចោទ អង្គបុរេជំនុំជម្រះ ប្រជាជនទាំងឡាយដឹងហើយថា នួន ជា គាត់រស់នៅទីណា ប្រសិនបើមានការចង់ធ្វើបាបគាត់នោះ គឺគេនឹងធ្វើឡើងរួចទៅហើយ។ ដូច្នេះគាត់ចង់ទៅផ្ទះរបស់គាត់វិញ គាត់គិតថាមិនមានអ្វីបញ្ហាទាក់ទងនឹងសន្តិសុខរបស់គាត់នោះទេ។

[១១:២៨:៤០]

ចំពោះសាធារណៈ-- សុវត្ថិភាពសាធារណៈវិញ ថាតើយ៉ាងម៉េចដែរ? នៅពេលដែលដោះលែងលោក នួន ជា ប្រហែលជាមានការខឹងសម្បា និងប៉ះពាល់សណ្ដាប់ធ្នាប់សាធារណៈ។ យើងគិតថាមិនជាការដូច្នោះនោះទេ។ តុលាការនេះបានបំពេញការងារយ៉ាងល្អ ហើយអាចពន្យល់ហេតុផលហេតុអ្វីបានជាយើងត្រូវលែងលោក នួន ជា ទៅតាមការធានាសណ្ដាប់ធ្នាប់សាធារណៈនេះ ហើយអាចធ្វើការបញ្ជូនព័ត៌មាននេះតាមកិច្ចការសាធារណៈ អំពីការដោះលែងលោក នួន ជា។ ហេតុដូច្នេះ សណ្ដាប់ធ្នាប់សាធារណៈនោះ វាមិនប៉ះពាល់នោះទេ។

[១១:២៩:២២]

ចំពោះការគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬការកម្ទេចភ័ស្តុតាងនោះ យើងខ្ញុំយល់ឃើញថា វាមិនមានការបង្ហាញណាមួយដែលលោក នួន ជា ចង់ធ្វើនោះទេ ឬក៏គាត់នឹងធ្វើការគាបសង្កត់ ឬក៏ការបំផ្លាញនោះទេ។ យើងដឹងហើយថា កិច្ចស៊ើបសួរបានធ្វើឡើងហើយ សាក្សីបានស្ដាប់ដោយការិយាល័យចៅក្រមស៊ើបអង្កេតរួចហើយ ហើយវាមានមូលដ្ឋានដែលអាចចាប់ផ្ដើមការជំនុំជម្រះ។

[១១:២៩:៥០]

ចំណុចចុងក្រោយ ដូចដែលអង្គជំនុំជម្រះបានជ្រាបហើយ ច្បាប់វិធានអន្តរជាតិ នៅពេលដែលពេលវេលាវិវត្តន៍ទៅមុខ ហើយការឃុំខ្លួននោះ វាបានឃុំខ្លួនរួចទៅហើយ យើងដឹងហើយថា ការឃុំខ្លួនជាងបីឆ្នាំហើយ។ ដូច្នេះហើយ ទោះបីជាមានមូលដ្ឋានយ៉ាងណាក៏ដោយ នៅក្នុងថ្ងៃនេះយើងស្នើសុំឲ្យមានការដោះលែងលោក នួន ជា ឲ្យមានសេរីភាព។ អ៊ីចឹង ខ្ញុំចង់សួរទៅកាន់លោកសហមេធាវីវិញ ថាតើលោកមានចំណុចណាត្រូវលើកឡើងបន្ថែមទៀតដែរឬទេ? សូមអរគុណ។

**លោក សុន អារុណ៖**

សូមគោរពលោកប្រធានសាជាថ្មី។ ក្នុងករណីការចោទប្រកាន់របស់តុលាការនៅក្នុងរឿងឃុំខ្លួនបណ្ដោះអាសន្នអស់រយៈពេលបីឆ្នាំ បួនខែរួចមកហើយ។ ការឃុំឃាំងនេះ ការចោទប្រកាន់ទាំងប៉ុន្មានខ្ញុំមើលឃើញថាដដែលៗ។ ឆ្នាំទីមួយ ក៏មេធាវីការពារលោក នួន ជា បានឡើងសវនាការតទល់ជាមួយនឹងព្រះរាជអាជ្ញាចំពោះមុខតុលាការ បង្ហាញហេតុផលសមរម្យជូនតុលាការរួចហើយ។

[១១:៣១:២០]

ហើយឆ្នាំទីពីរ មេធាវីការពារលោក នួន ជា ធ្វើជាលាយលក្ខណ៍អក្សរមិនបានមកតទល់ចំពោះមុខទេ ហើយនិងឆ្នាំទីបី ក៏មិនបានមកតទល់ចំពោះមុខដែរ។ យល់ឃើញថា ការតទល់ចំពោះមុខវាដដែលជាដដែល។ ហេតុផលដដែល ការចោទប្រកាន់ដដែល។

ខ្ញុំយល់ថា លោក នួន ជា មកដល់ថ្ងៃនេះគាត់អាយុ៦៥ អ៎! សមាលទោស សូមទោស ៨៥។ គាត់ដើរអត់រួចទេ ទាល់គេគ្រាគាត់ ហើយសុខភាពគាត់សព្វថ្ងៃមានពេទ្យមើលថែរក្សា ក៏ប៉ុន្តែមួយថ្ងៃកាត់ មួយថ្ងៃកោ ដូចអំមិញអ៊ីចឹង ហើយនេះជាលើកទីពីរ។ លើកទីមួយសវនាការជាមួយនឹងចៅក្រមស៊ើបអង្កេត ទើបមកដល់គាត់ត្រូវគ្រជាក់ត្រូវអ៊ីចឹង ឈាមគាត់ឡើងដល់២២ ហើយអំមិញនេះឈាមឡើងដល់២១កន្លះ។ ម្ល៉ោះហើយការអង្គុយដើម្បីធ្វើសវនាការ ជារឿងមួយដែលធ្វើឲ្យគាត់ពិបាក ពិបាកមែនទែន។

[១១:៣២:២៩]

ហើយខ្ញុំថា ការចោទប្រកាន់លោក នួន ជា អំពីហេតុផលមួយចំនួនដូចថា ការរត់គេចខ្លួន ដែលមិនបានដោះលែងគាត់ឲ្យនៅក្រៅឃុំ ការរត់គេចខ្លួនធ្វើឲ្យគាត់ហ្នឹងរួចខ្លួនពីការ-- ពីតុលាការអីទាំងអស់ហ្នឹង ខ្ញុំថារត់គេចខ្លួន រត់មិនរួចទេ លោក នួន ជា គាត់អាយុ៨៥ គាត់មិនរួចផង ឲ្យគាត់រត់ទៅណា។ គាត់អត់មានកម្លាំងទេ គាត់មានជំងឺ។ ហើយរឿងទីពីរ ការជ្រៀតជ្រែកទៅលើសាក្សី អានេះក៏រិតតែអត់សមទៀត គាត់អត់ដែលបាននិយាយជាមួយសាក្សីណា ពេលដែលគាត់ធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាល គាត់បានរស់នៅសុខសាន្តជាមួយនឹងគ្រួសារគាត់ នៅប៉ៃលិន ហើយនិងជាមួយនឹងប្រជាពលរដ្ឋក្នុងទីក្រុងប៉ៃលិន យ៉ាងសុខសាន្ត ធ្វើបុណ្យធ្វើទានជាមួយគ្នា។

[១១:៣៣:២៦]

ខ្ញុំបានលើកសម្ដីនេះនៅពេលសវនាការលើកទីមួយរួចទៅហើយ ប៉ុន្តែ ឥឡូវសូមរំឭកសាជាថ្មី

ដើម្បីក្នុងរឿងដដែល ក្នុងរឿងដែលសុំឲ្យគាត់នៅក្រៅឃុំ។ លោក នួន ជា មិនអាច។ រឿងមួយទៀត លោក នួន ជា មិនមានលិខិតឆ្លងដែនដើម្បីនឹងរត់ទៅឆ្លងដែនទៅប្រទេសមួយផ្សេងទៀតទេ ហើយនិងការណ៍-- ប្រទេសណាក៏គេមិនយកគាត់ គាត់អត់អាចរត់បានទេ គាត់អត់មានប៉ាស្ព័រទេ អត់មានលិខិតឆ្លងដែនទេ ហើយគាត់ដើរមិនរួច គាត់រត់អត់កើត។

[១១:៣៤:០៤]

ហើយការជ្រៀតជ្រែកទៅលើសាក្សី គឺប្រជាជននៅក្នុងតំបន់ប៉ៃលិន ទូសឹងតែ ទូទាំង ជិត៨០-៩០ភាគរយចូលចិត្តគាត់ ស្រឡាញ់គាត់ ស្រឡាញ់គ្រួសារគាត់។ ហើយបើចោទថាសណ្ដាប់ធ្នាប់សង្គម ធ្វើឲ្យខូចសណ្ដាប់ធ្នាប់សាធារណៈនិងសន្តិសុខផ្ទាល់ខ្លួនគាត់ ការសន្តិសុខផ្ទាល់ខ្លួនគាត់ បើគាត់ជាមនុស្សធ្វើល្អ បើប្រជាពលរដ្ឋ បើសាធារណជនយល់ថា លោក នួន ជា ហ្នឹងបម្រើជាតិ ដើម្បីបណ្ដោះជាតិពីអាណានិគមន៍បារាំង តាំងពីហ្នឹងមករហូតមកដល់គាត់ជាប់ឃុំ ប្រហែលជាមានការអនុគ្រោះចំពោះគាត់ខ្លាំង។ ប៉ុន្តែទាល់តែយល់ដល់តុលាការកាត់ដល់អង្គសេចក្ដី-- អង្គហេតុ និងអង្គសេចក្ដី អាហ្នឹងបានយល់ថា នួន ជា ជាមនុស្សយ៉ាងម៉េច? ឬថាធ្វើឲ្យខូចសណ្ដាប់ធ្នាប់សាធារណៈ ខ្ញុំថាដូចរឿងពីមុន ការចោទពីមុនអ៊ីចឹង គាត់មិនមានលទ្ធភាពស្អី នឹងធ្វើឲ្យខូចសណ្ដាប់ធ្នាប់សាធារណៈទេ គ្មានទាល់តែសោះ ខ្ញុំប៊ានធានា ហើយរហូតដល់ទៅ ខ្ញុំថា លើក-- កាលលើកទីមួយហ្នឹង ឆ្នាំទីមួយ ខ្ញុំសូមឲ្យតុលាការលើកលែងគាត់ ដើម្បីគាត់ជួបជុំគ្រួសារ ហើយបើសិនជាមាន ធ្វើអ្វីឲ្យប៉ះពាល់សណ្ដាប់ធ្នាប់សង្គម អាហ្នឹងនៅក្រោមការគ្រប់គ្រងរបស់តុលាការទេតើ។

[១១:៣៥:២៧]

ខ្ញុំយល់ថា បើកាលណាឲ្យគាត់នៅក្រៅឃុំ? មានការល្អ មានសុទិដ្ឋិនិយមមួយ គឺថាគាត់បានរស់នៅក្នុងជាមួយគ្រួសារ ជាមួយប្រពន្ធ ជាមួយកូន ជាមួយចៅទាំងអស់ ធ្វើឲ្យគាត់នឹងមានសុខភាព មានអារម្មណ៍ល្អ ជាជាងនៅនេះបីឆ្នាំបួនខែហើយ គាត់-- ទាល់សួរពេទ្យ ឬកងការពារនៅហ្នឹងបានដឹងថាគាត់ហ្នឹងយ៉ាងម៉េច។ ហើយខ្ញុំបានទៅជួបគាត់ញឹកញាប់ សឹងតែរាល់ថ្ងៃ ហើយខ្ញុំដឹងថាគាត់ហ្នឹងយ៉ាងម៉េច? អ៊ីចឹងថា ទទូចហើយទទូចទៀត ដើម្បីសុំឲ្យគាត់នៅក្រៅឃុំ ដើម្បីជួបគ្រួសារគាត់ ដើម្បីជួបសង្គមមួយឲ្យគាត់-- នៅកន្លែងមួយដែលមានបរិយាកាសល្អ ដើម្បីឲ្យគាត់ហ្នឹង ក្រែងលោគាត់បានមកជួយសហការជាមួយនឹងតុលាការវែងឆ្ងាយទៅទៀត។ បើមិនអ៊ីចឹងទេ ខ្ញុំថាតុលាការ រឿង នួន ជា ប្រហែលជាមិនអាចទៅវែងឆ្ងាយទេ។ ខ្ញុំសូមអរគុណ។

[១១:៣៦:៣១]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ បន្តទៀតសូមអញ្ជើញលោកមេធាវី ស សូវាន។

**លោក ស សូវាន៖**

សូមទោស អង្គជំនុំជម្រះសាលាដំបូង គោរពលោកប្រធាន ដែលបានអនុញ្ញាតឱ្យខ្ញុំធ្វើការអធិប្បាយទៅលើវិធាន៦៣(៣)។ ខ្ញុំចាប់អារម្មណ៍ ហើយសប្បាយទៀត បើលោកប្រធានសួរហ្នឹង ប៉ុន្តែខ្ញុំមិនប៉ាននិយាយទេ ពីព្រោះនៅក្នុងវិធាន៦៣(៣) នេះ លោកសហចៅក្រមស៊ើបសួរបានដាក់កូនក្តីខ្ញុំឱ្យនៅក្នុងឃុំបណ្តោះអាសន្នដើម្បីស្វែងរកការពិត។ ដូច្នេះ ខ្ញុំបានសូមឱ្យនៅក្រៅឃុំជាញឹកញាប់។ អង្គបុរេជំនុំជម្រះបានទទួលស្គាល់បីលក្ខខណ្ឌ ទទួលស្គាល់ថា កូនក្តីខ្ញុំមិនរត់ កូនក្តីខ្ញុំមិនបំបាត់ភ័ស្តុតាង កូនក្តីខ្ញុំមិនបំភិតបំភ័យ នៅសល់តែពីរហ្នឹងទេ លើកក្រោយហ្នឹងមិនឱ្យខ្ញុំទៀត។

[១១:៣៧:៣៧]

នែ៎! គេមិនលែងគាត់ គេភ័យថា-- ខ្លាចគេវាយគាត់ដូចឆ្នាំ៩០ ប៉ុន្មាន គាត់បែកក្បាលបែកអីនោះ ហើយគឺថាគេមិនលែងគាត់ទេ ខ្លាចលោក ខៀវ សំផន លែងអីចឹងទៅបង្កើតអស្ថិរភាពសណ្តាប់ធ្នាប់សាធារណៈ។ ឥឡូវនេះ ខ្ញុំវិលមកចំណុចពីរទៅទៀត តែពីរដដែលហ្នឹងទេ។ ខ្ញុំសូមថា ខ្ញុំមិនចង់និយាយដដែលខាតពេល ពីព្រោះខ្ញុំខ្លីទេ។ ខ្ញុំថា អរគុណហើយដែលថានឹកអំពីសុវត្ថិភាពកូនក្តី។ ចំណែកឯខ្ញុំបើគិតពីសុវត្ថិភាពខ្ញុំជាមេធាវីគាត់ ក៏ខ្ញុំរឹតតែសប្បាយចិត្តទៅទៀត។ ប៉ុន្តែ រហូតដល់ពេលនេះ ៥០០ នាក់គេធ្លាប់ឃើញមុខខ្ញុំហើយ មិនដែលអ្នកណាកំហែងគំរាមខ្ញុំដោយសារការពារលោក ខៀវ សំផន អតីតប្រធានរដ្ឋនៅក្នុងរបបលោក ប៉ុល ពត។

[១១:៣៨:៣០]

ឥឡូវខ្ញុំថា សុវត្ថិភាពគាត់បើលែងគាត់ថ្ងៃនេះម៉ោងនេះ គ្មានអ្នកណាទៅវៃគាត់ទេ ខ្ញុំនិយាយនេះនៅចំពោះមុខលោកព្រះរាជអាជ្ញានិងសហព្រះរាជអាជ្ញា ប៉ុន្តែលោកអាចឆ្លើយអីមិនដឹងទេ ប៉ុន្តែខ្ញុំថាខ្ញុំធានាថាអត់មានទេពីណាទៅវៃគាត់ទេ ព្រោះរដ្ឋាភិបាលគេបានខិតខំឱ្យមានសណ្តាប់ធ្នាប់ គោរពច្បាប់ សូម្បីតែតុលាការខ្មែរក្រហមពីដើម ភ័យមែន ប៉ុន្តែគេពន្យល់អ្នកស្រុក ថាមេធាវីស្វែងរកការពិត បើកូនក្តីខ្ញុំប្រព្រឹត្តខ្ញុំមិនដែលទៅប្រាប់ថាមិនប្រព្រឹត្តទេ អាហ្នឹងមេធាវីខ្ញុំលែងមេធាវីហើយ វាទៅជាអ្នកឃុបឃិតនឹងជនទុច្ចរិតប្រព្រឹត្តឧក្រិដ្ឋកម្មបណ្តាលឱ្យសង្គមយើងវេទនា។ អីចឹងបានពេលខ្លះខ្ញុំថា តែកាល

ណាយើងបង្កើតតុលាការ វាមានគុក ដាក់ទណ្ឌកម្ម។ ដូច្នេះ ហៅសាក្សីមកគេមិនសូវហ៊ានមកទេ ព្រោះគេមានភ័យខ្លាច។ ខ្ញុំសូមថា ឥឡូវនេះសូមលែងថ្ងៃហ្នឹង គឺថាគាត់គ្មានហានិភ័យលើរូបរាងគាត់ សូម្បីតែខ្ញុំមេធាវីនេះក៏ខ្ញុំមិនខ្លាចដែរ។

[១១:៣៩:៣១]

ចំណុចទីពីរ គេថាបើលែងគាត់សាធារណជន សណ្ដាប់ធ្នាប់សាធារណៈ រហូតដល់សហព្រះរាជអាជ្ញាកន្លងទៅនេះថា គាត់ធ្លាប់នៅប៉ៃលិន អត់មានអី មកពីកន្លែងហ្នឹងជាកន្លែងមណ្ឌលខ្មែរក្រហមចាស់។ ខ្ញុំថាចុះលោក រ៉ូប៊ឺត ពើទីត និងសហចៅក្រមស៊ើបអង្កេត និងឯកឧត្តម យូ ប៊ុនឡេង សហស៊ើបអង្កេតទៅបំផុសគំនិតឲ្យប្ដឹងលោក ខៀវ សំផន មុនគាត់ជាប់ចោទ គ្មានបានទទួលដុំឥដ្ឋដុំថ្មឯណាលើទេ បើសិនជាគេកាន់ជើងលោក ខៀវ សំផន។ គេគិតពីរឿងរកស៊ី។

[១១:៤០:១០]

ដូច្នេះ ដើម្បីឲ្យមានយុត្តិធម៌ ខ្ញុំថាលែងគាត់ទៅ លែងនេះបងប្អូនដូចអ្នកមិនចេះច្បាប់ខ្ញុំមិនមែនសូមឲ្យលែងរហូតទេ គឺនៅក្នុងបច្ចុប្បន្ននេះចូលក្នុងសមត្ថកិច្ចអង្គជំនុំជម្រះសាលាដំបូង សវនាការយកសាក្សីមកទាំងអស់ ដើម្បីរកការពិត ហើយខ្ញុំមានជំនឿចុងក្រោយទៀតថាអស់លោកចៅក្រមបរទេសចៅក្រមជាតិ សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិគ្មានគំនុំអីនឹងកូនក្ដីខ្ញុំទេ។ ខ្ញុំដឹងថា បើសិនជាលោកគោរពច្បាប់ សូមឲ្យទោសទាំងអស់ គឺថាកូនក្ដីខ្ញុំត្រូវលែងក្នុងម៉ោងហ្នឹងថ្ងៃហ្នឹង។

សូមអរគុណបាទ សូមអរគុណ។

[១១:៤០:៥១]

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកមេធាវី ស សូវាន ហើយមុននឹងជូនវេទិកាទៅមេធាវី ផាត់ ពៅស៊ាង អង្គជំនុំជម្រះសូមសួរទៅលោក ខៀវ សំផន ថាតើលោកមានចង់ធ្វើសេចក្ដីថ្លែងការណ៍អ្វីបន្ថែមបញ្ជាក់ពីលើសេចក្ដីថ្លែងការណ៍ ដែលធ្វើឡើងដោយមេធាវីរបស់លោកដែរឬទេ? បើមានសូមអញ្ជើញ!

[១១:៤១:១៥]

**លោក ខៀវ សំផន៖**

ខ្ញុំបាទសូមអរគុណលោកប្រធាន។ ខ្ញុំបាទមិនមានស្អីបញ្ជាក់ទេ មានសំណូមពរតែមួយគត់គឺអនុវត្តច្បាប់ មានអស់ប៉ុណ្ណឹងបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណបាទ។ សូមអញ្ជើញអង្គុយចុះ!

បន្តទៀតសូមអញ្ជើញលោកមេធាវី ផាត់ ពៅស៊ាង មេធាវីការពារក្តីឲ្យលោកស្រី អៀង ធីរិទ្ធ សូមឡើងធ្វើសេចក្តីបញ្ជាក់បន្ថែមពាក់ព័ន្ធនឹងវិធាន៦៣ អនុវិធាន៣ នៃវិធានផ្ទៃក្នុង បើសិនជាមានសូមអញ្ជើញ។

[១១:៤១:៥៦]

**លោក ផាត់ ពៅស៊ាង៖**

សូមអរគុណដល់លោកប្រធានអង្គជំនុំជម្រះសាលាដំបូងដែលអនុញ្ញាតឲ្យខ្ញុំបាទមានឱកាសដើម្បីឡើងបញ្ជាក់នូវវិធាន ៦៣(៣)។

គឺថាជាយោបល់របស់ខ្ញុំ ខ្ញុំបាទបានកត់សម្គាល់ឃើញថា វិធាន៦៣(៣) មកដល់បច្ចុប្បន្ននេះគឺថាហាក់បីដូចជាមិនចាំបាច់ទៀតទេ ដោយសារអី? ដោយសារថារយៈពេលនៃការឃុំខ្លួនកូនក្តីខ្ញុំបាទជាងបីឆ្នាំទៅហើយ ហើយការស៊ើបអង្កេត ការកោះហៅសាក្សីមកស៊ើបសួរ គឺថាបានប្រមូលភស្តុតាងអស់ហើយ មិនមានខ្វះចន្លោះអ្វីទៀតទេ ប្រសិនបើមានខ្វះចន្លោះ គឺថាសហចៅក្រមស៊ើបអង្កេតគាត់មិនធ្វើដីកាដំណោះស្រាយបញ្ជូនរឿងហ្នឹងទៅជំនុំជម្រះទេ។ ដូច្នេះ ខ្ញុំបាទបានពិនិត្យឃើញថា ដូចជាករណីដែលហៅថាការគំរាមគាបសង្កត់ទៅលើសាក្សីនោះ គឺគ្មានទេ បានន័យថាសាក្សីមកបំភ្លឺជូនអ្នកស៊ើបអង្កេតអស់ហើយ។

[១១:៤៣:១០]

ទីពីរ ដូចជាហៅថា ការបង្ក ហៅថា រក្សាសណ្តាប់ធ្នាប់សាធារណៈ គឺកូនក្តីខ្ញុំបាទមិនមានលទ្ធភាពអីទៅធ្វើឲ្យមានអចលាចលប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សាធារណៈទៀតទេ។ គឺកូនក្តីខ្ញុំបាទអាយុ៧៨ឆ្នាំហើយ។ ហើយអង្គសវនាការក៏បានឃើញដែរ គឺសុខភាពរបស់គាត់ទុរន់ទុរាណាស់ គឺយោងអាត្មាឲ្យតែរួចទៅ ហើយទៅបង្កអចលាចលធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈនោះវាមិនមានទេ។

[១១:៤៣:៤៨]

ហើយទន្ទឹមនឹងនោះ គឺថាការរក្សាភស្តុតាងក៏ហៅថា រយៈពេលនៃការស៊ើបអង្កេតបានប្រមូលភស្តុតាងស្វែងរកការពិតអស់ហើយ មិនមានអីចាំបាច់ទៀតទេ។ នៅសល់តែចំណុចដែលហៅថា ក្នុង

ហ្នឹងបានសរសេរថា "ការពារសន្តិសុខឲ្យជនត្រូវចោទ ហើយធានាអំពីវត្តមានរបស់ជនត្រូវចោទក្នុងដំណើរការនីតិវិធី"។ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូនថា ពីរចំណុចនេះគឺមិនមានការព្រួយបារម្ភទៀតទេ ពីព្រោះកូនក្តីខ្ញុំបាទ គឺបានន័យថាក្រោយពី ហៅថាតុលាការដោះលែងទៅ គឺគាត់ទៅរស់នៅភូមិដ្ឋានរបស់គាត់ គឺអត់មានបញ្ហាកើតឡើងទេ បើមានបញ្ហាកើតឡើងវាកើតឡើងយូរហើយ គឺគាត់ក្រោយពីសមាហរណកម្មជាមួយនឹងរាជរដ្ឋាភិបាល គឺអត់មានហេតុផលអ្វីដែលប៉ះពាល់ទៅដល់គាត់ទេ។

[១១:៤៤:៤៤]

លើសពីនេះទៅទៀត គឺថាការចូលរួមក្នុងនីតិវិធីរបស់តុលាការ គឺកូនក្តីខ្ញុំបាទបានសន្យា ហើយក៏ដូចជាខ្ញុំបាទជាមេធាវី គឺសន្យាថានៅពេលដែលមានដីកាកោះរបស់តុលាការ គឺកូនក្តីរបស់ខ្ញុំបាទនឹងចូលរួមគ្រប់ពេលវេលាមិនមានការអាក់ខានឡើយ។

ជាសំណូមពរ គឺខ្ញុំបាទនៅតែស្នើសុំទទូចស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូង មេត្តាដោះលែងកូនក្តីរបស់ខ្ញុំបាទឲ្យនៅក្រៅឃុំដោយសារអី? ដោយសារការឃុំខ្លួនកូនក្តីខ្ញុំបាទមានរយៈពេលជាង បីឆ្នាំ បានន័យថា បីឆ្នាំពីរខែហើយ។ សូមអរគុណ។

[១១:៤៥:២០]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

ឥឡូវនេះឃើញថា ពេលវេលានៅសល់តិចតួចដែលមិនគប្បីដំណើរការសវនាការតទៅទៀតទេដូច្នេះ ហើយម្យ៉ាងទៀតដល់ពេលត្រូវសម្រាកពិសាអាហារថ្ងៃត្រង់ផង។ អង្គជំនុំជម្រះប្រកាសឈប់សម្រាកត្រឹមនេះ ហើយសវនាការនៅរសៀលនេះនឹងធ្វើបន្តចាប់ពីម៉ោងដប់បីនិងសាមសិបនាទី។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញភាគី និងសាធារណជនដែលមានបំណងចូលរួមសវនាការ សូមអញ្ជើញមកកាន់សាលសវនាការឲ្យបានមុនម៉ោងដប់បី និងសាមសិបនាទីជាកំណត់។

សូមមអញ្ជើញសម្រាក!

ហើយអង្គជំនុំជម្រះក៏បង្គាប់ឲ្យអាជ្ញាធររដ្ឋបាលតុលាការ រូតវាំងននភ្លាមជាបន្ទាន់ក្រោយពេលអង្គជំនុំជម្រះចេញផុតពីបន្ទប់សវនាការនេះ ដើម្បីសម្រួលដល់អនុរក្សពន្ធនាគារសម្របសម្រួលចល័តជនជាប់ចោទទៅបន្ទប់សម្រាកខាងក្រោម ហើយនិងបង្គាប់ឲ្យនាំគាត់ទៅសម្រាកនៅបន្ទប់រង់ចាំខាងក្រោម ហើយឲ្យនាំគាត់ត្រឡប់មកវិញនៅរសៀលនេះឲ្យបានមុនម៉ោងបី និងសាមសិបនាទី (ស៊ីក)។

[១១:៤៦:២៨]

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៤៧នាទី ដល់ម៉ោង ១៣:៣៤នាទី)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអស់លោក លោកស្រី អង្គុយចុះ!

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ពិភាក្សាដេញដោលលើសំណើសុំដោះលែងជនជាប់ចោទ។

ព្រឹកមិញនេះយើងបានស្តាប់នូវសេចក្តីថ្លែងការណ៍ប្តឹងសុំរបស់មេធាវីការពារក្តីជនជាប់ចោទរួចហើយ លើសំណើសុំដោះលែងជាបន្ទាន់ ព្រមទាំងសេចក្តីថ្លែងការណ៍បញ្ជាក់បន្ថែមពាក់ព័ន្ធនឹងបទបញ្ញត្តិវិធាន៦៣ អនុវិធាន៣ នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

[១៣:៣៥:៥០]

ហើយតទៅទៀត គឺជាពេលវេលាសម្រាប់សហព្រះរាជអាជ្ញា តើភាគីសហព្រះរាជអាជ្ញាមានអ្វីត្រូវធ្វើសេចក្តីថ្លែងការណ៍តបទៅនឹងសំណើសុំនិងសេចក្តីថ្លែងការណ៍បញ្ជាក់របស់មេធាវីការពារក្តីជនចោទទាំងបីដែរឬទេ?

ទន្ទឹមនឹងនេះផងដែរ អង្គជំនុំជម្រះសូមបញ្ជាក់ថាសហព្រះរាជអាជ្ញាមានសិទ្ធិនៅក្នុងការធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់បន្ថែមពាក់ព័ន្ធនឹងបទបញ្ញត្តិនៃវិធាន៦៣(៣) នៃវិធានផ្ទៃក្នុងនៃអ.វ.ត.ក ប្រសិនព្រះរាជអាជ្ញាមានបំណង។

សូមអញ្ជើញ សហព្រះរាជអាជ្ញា! សូមអញ្ជើញជំទាវសហព្រះរាជអាជ្ញាជាតិ!

[១៣:៣៦:៣៧]

**លោកស្រី ជា លាង៖**

សូមអរគុណលោកប្រធាន។

ជាបឋមនេះ សូមគោរពអង្គជំនុំជម្រះសាលាដំបូង ក៏សូមគោរពអង្គសវនាការទាំងមូល។

ដោយសារកាលពីព្រឹកមិញនេះ គឺមានការឆ្លើយរបស់មេធាវីការពារក្តីគឺបីសរុបជាមួយគ្នាតែម្តងហើយសហព្រះរាជអាជ្ញាមានការបែងចែកគ្នាក្នុងការឆ្លើយតប ហើយខ្ញុំមានការបែងចែកគ្នា ដោយសារ

ការឆ្លើយតបនឹងសហមេធាវីការពារក្ដីរបស់ជនជាប់ចោទ នួន ជា ខ្ញុំនឹងទុកឲ្យខាងសហព្រះរាជអាជ្ញាអន្តរជាតិនឹងការឆ្លើយ ហើយបន្ទាប់ទៀត ខ្ញុំនឹងធ្វើការឆ្លើយតបដែលពាក់ព័ន្ធទៅនឹងសហមេធាវីការពារក្ដីរបស់ជនជាប់ចោទ ខៀវ សំផន ហើយនិងជនជាប់ចោទ អៀង ធីរិទ្ធ។

[១៣:៣៧:២០]

ដូច្នេះ ដំបូងនេះ ខ្ញុំសូមឲ្យខាងសហព្រះរាជអាជ្ញាអន្តរជាតិធ្វើការឆ្លើយតបជាដំបូងសិន។ ចាស, សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក អាន់ទ្រូ ខៃលៃ៖**

សូមអរគុណលោកស្រី ជា លាង។ សូមគោរពតុលាការ ខ្ញុំអនុញ្ញាតសុំលើកឡើងនូវការលើកឡើងរបស់លោក នួន ជា ខាងលោក នួន ជា ដូចដែលលោកស្រីសហព្រះរាជអាជ្ញាបានបញ្ជាក់អម្បាញ់មិញ។ បន្ទាប់មកលោកស្រីសហព្រះរាជអាជ្ញានឹងលើកឡើងតបទៅនឹងមេធាវី ខៀវ សំផន និង អៀង ធីរិទ្ធ។

[១៣:៣៨:០៣]

ចំពោះការឆ្លើយតបរបស់ខ្ញុំទៅលើសំណើលើកឡើងដោយមេធាវី នួន ជា ខ្ញុំលើកឡើងបីផ្នែក។ ផ្នែកទីមួយនៃការឆ្លើយតប ចម្លើយតបរបស់ខ្ញុំ គឺខ្ញុំសូមអនុញ្ញាតលើកឡើងអំពីភាពអាចទទួលយកបាននូវពាក្យសុំនោះ។ ទាក់ទងទៅនឹងបណ្ដឹង សំណើសុំថ្ងៃទី១៨ ខែមករា។ ទីពីរ គឺខ្ញុំលើកឡើងទៅលើឆ្លើយតបទៅនឹងអង្គសេចក្ដី ហើយឆ្លើយតបទៅនឹងសំណួររបស់អង្គសវនាការនៅក្នុងដីកាកំណត់កាលបរិច្ឆេទ។ ទីបី ខ្ញុំនឹងលើកឡើងឆ្លើយតបទៅនឹងសំណួរទីពីរ នៅក្នុងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង។ ចំណុចចុងក្រោយ ទាក់ទងទៅនឹងពាក្យសុំដែលធ្វើឡើង-- ទាក់ទងនឹងវិធាន៦៣(៣) ខ្ញុំស្នើសុំឲ្យបដិសេធសំណើនោះចោល។

[១៣:៣៩:០៣]

ខ្ញុំសូមលើកឡើងនូវផ្នែកទីមួយ នៃចម្លើយតបរបស់ខ្ញុំ។ ចម្លើយតបរបស់ខាងសហព្រះរាជអាជ្ញា គឺថា ពាក្យសុំរបស់ នួន ជា នៅថ្ងៃទី១៨ ខែមករា គឺមិនអាចទទួលយកបាននៅចំពោះមុខអង្គជំនុំជម្រះនេះ។ ដោយហេតុថា ពាក្យសុំនោះបានស្នើសុំឲ្យអង្គសវនាការធ្វើការពិនិត្យលើសេចក្ដីសម្រេចរបស់អង្គ

បុរេជំនុំជម្រះឲ្យកំណត់ទៅលើសុពលភាពនៃសំណើសុំ-- សេចក្ដីសម្រេចទៅលើសំណើសុំថ្ងៃទី១៨ ខែមករា។

[១៣:៣៩:៤៣]

វិធាននៃតុលាការ វិធានផ្ទៃក្នុង វិធាន៧២(១៣)ចែងថា សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះមិនត្រូវការពិនិត្យឡើងវិញនោះទេ។ ដូច្នេះហើយ អង្គជំនុំជម្រះសាលាដំបូងមិនមែនជាអង្គជំនុំជម្រះត្រូវការពិនិត្យលើសេចក្ដីសម្រេចនោះឡើងវិញនោះទេ។ ទោះបីជាយល់ឃើញថា អង្គសេចក្ដីនៅក្នុងសំណើសុំរបស់ នួន ជា នោះគឺយើងក៏មិនអាចធ្វើការពិនិត្យមើលសំណើសុំនោះសាជាថ្មីនោះដែរ។ យើងមិនមានយុទ្ធសាស្ត្រដូច្នោះទេ។ ខ្ញុំសូមលើកឡើងទៅលើចំណុចនេះ ការលើកឡើងនៅព្រឹកមិញ អង្គជំនុំជម្រះគឺយើងត្រូវពិចារណាទៅលើសំណើសុំរបស់លោក នួន ជា ដែលវាអាស្រ័យទៅលើកាលៈទេសៈដែលមានការផ្លាស់ប្ដូរ។ ដូច្នេះ ពាក្យសុំរបស់មេធាវី នួន ជា មិនអាចទទួលយកបាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

[១៣:៤០:៤៥]

ចំណុចចុងក្រោយខ្ញុំសូមបញ្ជាក់ បញ្ហានេះវាពាក់ព័ន្ធទៅនឹងទទ្បីករណ៍ទីមួយរបស់ខ្ញុំ និងទទ្បីករណ៍ក្រោយៗ យើងឃើញមានកំហុសជាមូលដ្ឋានលើកឡើងពីខាង នួន ជា។ មេធាវី នួន ជា លើកឡើងក្នុងកថាខណ្ឌ១១ នៃពាក្យសុំថា សាលាដំបូងទទួលបាននូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមរយៈសាលដីការបស់អង្គជំនុំជម្រះនៅថ្ងៃទី១៣ ខែមករា ២០១១។ សូមអង្គសវនាការមើលកថាខណ្ឌ១១នៃពាក្យសុំបន្ទាត់ទីមួយ។

[១៣:៤១:២០]

នៅក្នុងពាក្យសុំនោះផងដែរ ក៏បានលើកឡើងផងដែរថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះមិនមានសំអាងហេតុគ្រប់គ្រាន់ ដូច្នេះហើយវាមិនមែនជាសម្រេចមួយត្រឹមត្រូវ។ ដូច្នេះមេធាវីការពារក្ដីមិនអាចតវ៉ាថាការសម្រេចរបស់អង្គបុរេជំនុំជម្រះថ្ងៃទី១៣ ជាសេចក្ដីសម្រេចមិនមានសុពលភាព ហើយក្រោយតវ៉ាថាអង្គជំនុំជម្រះសាលាដំបូងបានទទួលដីកាចោទប្រកាន់ពីអង្គបុរេជំនុំជម្រះ។ ដូច្នេះយើងមិនអាច-- មេធាវីការពារក្ដីមិនអាចលើកឡើងចំណុចពីរនេះក្នុងពេលតែមួយនោះទេ។ ហើយយើងឃើញថាសំណើសុំទាក់ទងទៅនឹងការដោះលែងឲ្យមានសេរីភាព អនុលោមតាមវិធាន៨៣ ឬក៏វិធានដទៃទៀតនៃវិធានផ្ទៃក្នុងនោះ គឺមិនអាចទទួលយកបាន។

ខ្ញុំសូមចូលទៅដល់អង្គសេចក្តីនៃពាក្យសុំរបស់មេធាវីការពារក្តី ហើយខ្ញុំអនុញ្ញាតលើកឡើងទាក់ទងទៅនឹងការប៉ះពាល់ទៅដល់ជនជាប់ចោទ។

[១៣:៤២:៣២]

យើងខ្ញុំជាសហព្រះរាអាជ្ញាយល់ឃើញថាជនជាប់ចោទ នួន ជា មិនទទួលបាននូវការប៉ះពាល់ទៅលើសិទ្ធិរបស់គាត់នោះទេ។ ហេតុអ្វីបានជាយើងខ្ញុំលើកឡើងដូច្នេះ? ខ្ញុំសូមអនុញ្ញាតឆ្លើយតបទាក់ទងទៅនឹងភាពគ្រប់គ្រាន់នៃសំអាងហេតុរបស់តុលាការ។

ខ្ញុំលើកចំណុចនេះ ដោយសារតែខ្ញុំធ្វើការសន្និដ្ឋាននៅចំពោះមុខក្រុមក្រុមប្រឹក្សាអង្គជំនុំជម្រះដោយអាស្រ័យទៅលើការយល់ទៅលើច្បាប់។ ការខ្វះសំអាងហេតុនៅក្នុងតុលាការនេះ គឺវាអាស្រ័យទៅលើរឿងក្តីនិងកាលៈទេសៈនៃសេចក្តីសម្រេចដែលបានធ្វើឡើង។ កាលៈទេសៈមួយនោះ គឺវានាំឲ្យយើងយល់ថាវាមានសេចក្តីសម្រេចដែលបានធ្វើឡើងអាស្រ័យទៅលើសេចក្តីសន្និដ្ឋានរបស់ភាគី ហើយវាជាកាតព្វកិច្ចរបស់អង្គជំនុំជម្រះក្នុងការចេញសេចក្តីសម្រេច។

[១៣:៤៣:៣៣]

នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងទៅនឹងដីកាដោះស្រាយ គាត់មិនបានលើកឡើងទឡ្ហីករណ៍ណាមួយ ទាក់ទងទៅនឹងបន្តការឃុំខ្លួននោះទេ។ ដូច្នេះហើយ វាអាស្រ័យទៅលើចៅក្រមត្រូវពិចារណា គាត់មិនចាំបាច់ពិចារណានោះទេ។ នៅក្នុងសេចក្តីសម្រេចនៅថ្ងៃទី១៣ ខែមករា អង្គបុរេជំនុំជម្រះ បានបង្គាប់ឲ្យមានការបន្តការឃុំខ្លួន ដោយសារតែ នួន ជា មិនបានលើកឡើងទឡ្ហីករណ៍ទាក់ទងទៅនឹងការដោះលែងជាបណ្តោះអាសន្ន។ សេចក្តីសម្រេចនោះ គឺវាបង្គាប់ឲ្យតម្កល់នូវដីកាសម្រេចរបស់ចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៧ ខែ៩ ២០១០ ដែលក្នុងនោះគឺបានលើកឡើងហេតុផលដែលតម្រូវឲ្យបន្តឃុំខ្លួនលោក នួន ជា។

[១៣:៤៤:២៩]

ដូច្នេះ ថាតើសេចក្តីសម្រេច នៅថ្ងៃ១៣ ខែមករា ២០១១ របស់អង្គបុរេជំនុំជម្រះមានហេតុផលគ្រប់គ្រាន់ដែរឬទេនោះ គឺវាបង្ហាញយ៉ាងច្បាស់តាមរយៈដីកាបង្គាប់របស់ចៅក្រមស៊ើបអង្កេត ថ្ងៃទី១៧ ខែ៩ ២០១០ ថាហេតុអ្វីបានជាត្រូវការឃុំខ្លួនលោក នួន ជា? ហើយនៅក្នុងសេចក្តីសម្រេចថ្ងៃទី២១ នោះ ក៏បានលើកឡើងអំពីមូលដ្ឋានដែលតម្រូវឲ្យមានការឃុំខ្លួនបន្តលើជនជាប់ចោទបន្ថែមទៅលើដីកាថ្ងៃទី១៧ ខែ៩ ២០១០ ហេតុដូច្នេះហើយលោក នួន ជា អាចដឹង មូលដ្ឋាននៃការបន្តឃុំខ្លួន ចុះថ្ងៃទី១៣

ខែ១ ឆ្នាំ២០១១។

[១៣:៤៥:២១]

ដូច្នេះហើយពាក្យសុំដែលលើកឡើងក្នុង-- យោងទៅតាមវិធានផ្ទៃក្នុង៨៣ និង៦៣ នោះ វាអាស្រ័យទៅលើការគិតគូររបស់អង្គជំនុំជម្រះសាលាដំបូង។ ចំណុចទីបី នៅក្នុងពាក្យសុំរបស់លោក នួន ជា យើងឃើញមានបញ្ជីរៀបរាប់ទៅលើចំណុចជាច្រើន ហើយនៅក្នុងលេខជើងទំព័រលេខ២២ គឺបានពន្យល់ថាលោកមានមេធាវី នួន ជា មិនបានលើកឡើងទឡ្ហីករណ៍នៅក្នុងពាក្យសុំរបស់ខ្លួននោះទេ។

នៅក្នុងប្រទេសខ្ញុំការអនុវត្តដែលខ្ញុំធ្លាប់ធ្វើនោះ ចៅក្រមអាចចេញសេចក្តីសម្រេចភ្លាមៗ បន្ទាប់មកផ្តល់សំអាងហេតុនៅពេលក្រោយ។ នេះជាពេលទីមួយដែលមេធាវីការពាក្តី គាត់លើកឡើងថាសេចក្តីសម្រេចនេះមិនមានសំអាងហេតុ។

[១៣:៤៦:១៣]

ខ្ញុំសូមឆ្លើយតបទៅនឹងគោលការណ៍ដំណោះស្រាយខ្ពស់បំផុតដែលបានលើកឡើងនៅក្នុងពាក្យសុំម្តង។ ជាសំខាន់នោះ ទឡ្ហីករណ៍នោះខ្ញុំយល់ឃើញថា វាជាគោលការណ៍មួយជាក់លាក់នៅក្នុងច្បាប់របស់ប្រទេសហូល្លង់ វាកំណត់ទៅលើការសម្រេចមួយចំនួនរបស់អង្គជំនុំជម្រះ។ ដូច្នេះ គេលើកឡើងថាការឃុំខ្លួននោះ គឺជាដំណោះស្រាយ និងគោលការណ៍ចុងក្រោយបំផុត ដែលត្រូវធ្វើឡើង។

ខ្ញុំសូមលើកឡើងថា គោលការណ៍នោះគឺជាគោលការណ៍សន្ធិមួយខ្ពស់ណាស់ នៅក្នុងច្បាប់អន្តរជាតិ។ ជនដែលជាប់ឃុំត្រូវតែជាប់ឃុំរហូតទៅដល់ការជំនុំជម្រះ លើកលែងតែជនជាប់ចោទបានបង្ហាញអង្គជំនុំជម្រះថា មានកាលៈទេសៈប្រែប្រួល ហើយវាប៉ះពាល់ទៅនឹងសេចក្តីសម្រេចដែលលើកឡើង និងធ្វើឡើងកាលពីលើកមុនរបស់អង្គជំនុំជម្រះ ដែលតម្រូវឲ្យមានការដោះលែងក្នុងពេលនេះ។

[១៣:៤៧:២១]

ជាពិសេស យើងអាចមើលសេចក្តីសម្រេចរបស់តុលាការយូហ្គោស្លាវី របស់សហព្រះរាជអាជ្ញាទល់នឹងកូនក្តីមួយនៅក្នុងកថាខណ្ឌទី១១ នៃសេចក្តីសម្រេចរបស់តុលាការ *អាយ.ស៊ី.ធី.វ៉ាយ*។ គោលការណ៍នេះ គឺមានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់យើង ជាពិសេសវិធាន៨១ នៃវិធានផ្ទៃក្នុង ដែលក្នុងនោះចែងថា ជនជាប់ចោទគឺត្រូវតែមានសេរីភាព លើកលែងតែមានការបង្គាប់ពីអង្គជំនុំជម្រះឲ្យមានការឃុំខ្លួនរហូតដល់ពេលសវនាការ។ ជនជាប់ចោទត្រូវតែជាប់ឃុំរហូតដល់ពេលមានការចេញសាលក្រមរបស់អង្គជំនុំជម្រះអាស្រ័យទៅតាមវិធាន អនុវិធានទី២។

[១៣:៤៨:២១]

ខ្ញុំសូមអនុញ្ញាតលើកឆ្លើយតបទៅនឹងបញ្ហាសំណួរចោទទីពីរ ពាក់ព័ន្ធទៅនឹងការដោះលែងឲ្យមានសេរីភាពភ្លាមៗ ប្រសិនបើមានការប៉ះពាល់ទៅដល់ជនជាប់ចោទ។ ខ្ញុំសន្និដ្ឋានឃើញថា មិនមានការប៉ះពាល់ទៅដល់ជនជាប់ចោទនោះទេ។ ជាការពិត យើងឃើញមានយុត្តិសាស្ត្រអន្តរជាតិ គឺរឿងក្តីរដ្ឋអាជ្ញា និង *ផាប់អើហ្សីក* នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០០៧ ដែលនៅពេលនោះ ជនជាប់ចោទបានស្នើសុំឲ្យមានការដោះលែងជាបណ្តោះអាសន្នដាក់ជូនទៅអង្គជំនុំជម្រះសាលាដំបូង។ ពាក្យសុំនោះត្រូវបានអង្គជំនុំជម្រះសាលាដំបូងបដិសេធចោល បន្ទាប់មកជនជាប់ចោទធ្វើការប្តឹងសាទុក្ខ ប្តឹងឧទ្ធរណ៍ទៅកាន់តុលាការ *អាយ.ស៊ី.ធី.វ៉ាយ* ហើយជនជាប់ចោទក៏បានសម្រេចលើកឡើងថាអង្គជំនុំជម្រះនៅទីនោះ មិនបានផ្តល់សំអាងហេតុ។

[១៣:៤៩:១៨]

នៅក្នុងអង្គបុរេជំនុំជម្រះ នៅពេលអង្គជំនុំជម្រះតុលាការកំពូល ក្រោយមកបានរកឃើញថាអង្គបុរេជំនុំជម្រះមានកំហុស ប៉ុន្តែកំហុសនោះមិនមែនតម្រូវឲ្យមានការដោះលែងជនជាប់ចោទដោយបណ្តោះអាសន្ននោះទេ។ ហើយមិនមានករណីឲ្យធ្វើការដោះលែងជនជាប់ចោទនោះទេ ហើយនៅពេលនោះ គឺមានការបន្តការឃុំខ្លួនជនជាប់ចោទបន្តទៀត ហើយក្រោយមកអង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សំអាងហេតុបន្ថែមទៅលើសំអាងហេតុរបស់អង្គជំនុំជម្រះ។

ជាក្តីសន្និដ្ឋាន-- ជាសេចក្តីសន្និដ្ឋានទៅលើសំណើសុំរបស់មេធាវី នួន ជា ខ្ញុំសូមលើកឡើងដោយគោរពថា ពាក្យសុំនោះមិនអាចទទួលយកបាននោះទេ។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងលើកឡើងថា អាចទទួលយកបានក៏ដោយ ខ្ញុំយល់ឃើញថាការប៉ះពាល់ទៅដល់ នួន ជា នោះ គឺមិនមានឡើយ។ នៅពេលដែលយើងផ្អែកទៅលើយុត្តិសាស្ត្រអន្តរជាតិ យើងអាចមើលឃើញយុត្តិសាស្ត្រមួយចំនួនដែលបង្ហាញពាក់ព័ន្ធទៅនឹងករណីនេះ។ ដូចដែលខ្ញុំបានលើកឡើងយុត្តិសាស្ត្រអម្បាញ់មិញនេះ។

[១៣:៥០:៣៦]

ដំណោះស្រាយសមស្របសម្រាប់លោក នួន ជា នោះ គឺយើងគួរគោរពតាមវិធាន៨២(៣) និងវិធាន៦៣(៣) នៃវិធានផ្ទៃក្នុង។ ប្រសិនបើអនុញ្ញាត ខ្ញុំសូមចូលទៅដល់សំណើសុំដែលលើកឡើងតាមវិធាន៦៣(៣) គឺពាក្យសុំដែលបានលើកអម្បាញ់មិញនេះ ទាក់ទងទៅនឹងការសុំដោះលែងពីខាង នួន ជា។ ខ្ញុំសូមជំទាស់ទៅលើពាក្យសុំនោះ។

[១៣:៥១:១១]

ខ្ញុំលើកឡើងថា យើងគួរតែរក្សា នួន ជា ឃុំខ្លួនបណ្តោះអាសន្នបន្តទៀត។ ខ្ញុំសូមបញ្ជាក់ថា នៅក្នុងពាក្យសុំដែលបានលើកឡើងកាលពីព្រឹកមិញនេះ ភ័ស្តុតាងត្រូវតែបង្ហាញអំពីកាលៈទេសៈប្រែប្រួល មិនមែនចេះតែលើកឡើងថា មិនមានការប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សាធារណៈ មិនមានការភ័យព្រួយទៅលើសុវត្ថិភាពសន្តិសុខនោះទេ។ ត្រូវតែបញ្ជាក់អំពីកាលៈទេសៈដែលបានផ្លាស់ប្តូរ។

[១៣:៥១:៤៣]

ខ្ញុំសូមមើលវិធាន៦៣(៣) ដែលក្នុងនោះចែងមូលដ្ឋានមួយចំនួន។ មូលដ្ឋានទីមួយ គឺត្រូវតែមានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ នៅក្នុងខែមករា ឆ្នាំ២០១១ នេះ មានឯកសារសំណុំរឿងជាច្រើនដែលបង្ហាញថាលោក នួន ជា នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យមានការជាប់ពាក់ព័ន្ធទៅនឹងបទល្មើស ដែលដាក់បន្ទុកចំពោះគាត់។ ហើយប្រហែលជាមិនមានភ័ស្តុតាងណាមួយដែលបង្ហាញផ្ទុយទៅនឹងមូលដ្ឋានវិធាន៦៣(៣) នោះទេ ហើយយើងក៏មិនអាចចំណាយពេលគ្រប់គ្រាន់មើលពិចារណា ថាតើការសម្រេចទៅលើសំណុំរឿងទាំងអស់នោះយ៉ាងម៉េចនោះផងដែរ។

[១៣:៥២:៥៦]

ទាក់ទងទៅនឹងសម្រេច ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះបានសម្រេចថា ដីកានោះគឺបានសម្រេចនិងបង្ហាញថាជនជាប់ចោទគឺធ្លាប់បានប្រព្រឹត្តទៅលើបទល្មើសទាំងអស់នោះ។ លក្ខខណ្ឌមូល-ដ្ឋានមួយទៀត នៅក្នុងវិធាន៦៣(៣)(ខ) គឺជាវិធានការចាំបាច់ដើម្បីរារាំងកុំឲ្យជនជាប់ចោទគាបសង្កត់ទៅលើសាក្សី ឬក៏ត្រូវរ៉ូវជាមួយនឹងសាក្សី ហើយនិងអ្នកសមគំនិតចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។

[១៣:៥៣:៣៣]

ពេលវេលាដែលបានកន្លងផុតទៅនេះ មិនបានធ្វើឲ្យបាត់បង់នូវហានិភ័យនៃមូលដ្ឋាននេះទេ។ ហើយខ្ញុំសូមលើកឡើងថា ហានិភ័យមានការកើនឡើង ដោយសារតែសំណុំរឿង គឺជនជាប់ចោទអាចពិនិត្យមើលបាន គាត់ដឹងអំពីសាក្សី ដូច្នេះហើយហានិភ័យវាកាន់តែកើនឡើង មិនមែនថយចុះនោះទេ។ ហេតុផលដែលបានលើកឡើងដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ រួមទាំងសេចក្តី

សម្រេចដីកានៅក្នុងដីការបស់ចៅក្រមស៊ើបអង្កេត ថ្ងៃទី១៧ ខែ៩ ឆ្នាំ២០១០ គឺក៏បានបង្ហាញទៅលើចំណុចហ្នឹងទាំងអស់ផងដែរ។

[១៣:៥៤:១៦]

លោក លោកស្រីចៅក្រម ដោយមើលទៅលើជំហរ និងមុខនាទីរបស់ជនជាប់ចោទ ជនជាប់ចោទ អាចធ្វើការគាបសង្កត់ទៅលើសាក្សី ជាពិសេសសាក្សីទាំងឡាយដែលស្ថិតនៅក្រោមការបង្គាប់របស់ខ្លួន។ ហើយយើងក៏ឃើញមានភ័ស្តុតាងទាក់ទងទៅនឹងបញ្ហានេះផងដែរ គឺមានសរសេរនៅក្នុងសាលដីការបស់អង្គបុរេជំនុំជម្រះ ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩ ដែលក្នុងនោះបង្ហាញភ័ស្តុតាងថា នួន ជា បានធ្វើការគាបសង្កត់ទៅលើ ឌុច ទាក់ទងទៅនឹងការផ្លាស់ប្តូរចម្លើយសារភាពដែល ឌុច បានប្រមូលឡើងក្នុងនាម នួន ជា។ ខ្ញុំលើកឡើងថា វាមិនពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការគាបសង្កត់សាក្សីនោះទេ ប៉ុន្តែវាបង្ហាញអំពីលទ្ធភាពរបស់បុគ្គលម្នាក់អាចធ្វើការគាបសង្កត់ប្រើអំណាចទៅលើជនដែលស្ថិតនៅក្រោមបង្គាប់របស់ខ្លួន។

[១៣:៥៥:១៦]

ខ្ញុំសូមលើកឡើងផងដែរ សាក្សីនឹងមានការភ័យខ្លាចពីជនជាប់ចោទនេះ។ ដីកាសម្រេច និងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ គឺមិនមានការបង្ហាញអំពីការផ្លាស់ប្តូរកាលៈទេសៈណាមួយ ពីខាងក្រុមមេធាវីការពារក្តីដូចដែលបានលើកឡើងនោះទេ។ ជនជាប់ចោទបានព្យាយាមធ្វើការបំផ្លាញទៅលើភ័ស្តុតាង ខ្ញុំសូមលើកឡើងយោងទៅលើឯកសារ គ(២) ដែលក្រុមមេធាវីការពារក្តីបានលើកឡើងនោះ គឺមិនមានភ័ស្តុតាងផ្ទុយណាមួយថាបង្ហាញគាត់មិនព្យាយាមធ្វើការបំផ្លាញភ័ស្តុតាងនោះទេ។

យើងក៏ឃើញមាននៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា នៅក្នុងថ្ងៃទី២០ ខែមីនា ឆ្នាំ ២០០៨ ផងដែរ ដែលក្នុងនោះបង្ហាញទៅលើភ័ស្តុតាងនៅក្នុងការសម្ភាសន៍មួយថា នួន ជា បានធ្វើការបន្ទោស ឌុច ដែរថា ឌុច មិនបានបំផ្លាញភ័ស្តុតាង។ ដូច្នេះចំណុចនេះ វាបង្ហាញយ៉ាងច្បាស់ថា ឌុច ត្រូវបានរិះគន់យ៉ាងខ្លាំងពី នួន ជា។ ប៉ុន្តែយ៉ាងក៏ដោយ ឌុច គាត់នៅបន្សល់ភ័ស្តុតាងមួយចំនួន ដែលភ័ស្តុតាងនោះ វាជាភ័ស្តុតាងដាក់បន្ទុកទៅលើ នួន ជា។

ដូច្នេះ ចំណុចនេះលើកឡើងនៅក្នុងចំណុច ៣(ខ)(២)។ ខ្ញុំសូមលើកឡើងថា ខ្ញុំសូមទទួលស្គាល់ថា ជនជាប់ចោទគាត់មានការទន់ខ្សោយ ប៉ុន្តែគាត់បានប្រព្រឹត្តទៅលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ហើយប្រសិនបើត្រូវបានកាត់ឲ្យជាប់ទោសនោះ ជនជាប់ចោទអាចជាប់ទោសពីប្រាំឆ្នាំ រហូតអស់មួយជីវិត។

[១៣:៥៧:២០]

ដូច្នេះ យើងមានការសង្ស័យ ថាតើគាត់រត់គេចខ្លួនដែរឬទេ? ហើយគ្មានបុគ្គលណាម្នាក់ ឬក៏មេធាវីការពារក្តីបានលើកឡើងអំពីកាលៈទេសៈផ្លាស់ប្តូរ ដែលវាកើតឡើងចំពោះអង្គជំនុំជម្រះវិសាមញ្ញនេះទេ។ ខ្ញុំលើកឡើងសូមចំណុច ៣(ខ)(៤) ទាក់ទងទៅនឹងការការពារសុវត្ថិភាពរបស់ជនជាប់ចោទ។ ជនជាប់ចោទលើកឡើងថា គាត់ត្រូវបានធ្វើសមាហរណកម្មនៅក្នុងសង្គម ហើយគាត់មិនធ្វើការ-- មិនមានកំហឹងតវ៉ាណាមួយចំពោះគាត់នោះទេ។ ប៉ុន្តែយើងត្រូវមើលអំពីបរិបទ១៣ឆ្នាំនៃនិទ្ទណ្ឌភាព។

ផលប្រយោជន៍នៃតុលាការនេះ និងភ័ស្តុតាងទាំងឡាយនោះ យើងឃើញមានថាភ័ស្តុតាងមានកើនឡើង ដូច្នេះសុវត្ថិភាពហានិភ័យខ្ពស់។ វាបានបង្ហាញថា តាមភ័ស្តុតាងដំបូងៗ ជនជាប់ចោទគឺក្រោយពីការឃុំខ្លួនគឺមានភ័ស្តុតាងជាច្រើន ហើយយើងក៏មិនអាចគិតថា តើគាត់ទទួលគ្រោះថ្នាក់ ឬក៏យ៉ាងណានោះដែរ។

ខ្ញុំសូមជម្រាបថា ពាក្យសុំនោះគឺមិនបានលើកឡើង ពាក្យសុំរបស់ខាងមេធាវីការពារក្តីមិនលើកឡើងអំពីកាលៈទេសៈផ្លាស់ប្តូរនោះទេ។ ចំណុច៣(ខ)(៥) លើកឡើងអំពីសណ្តាប់ធ្នាប់សាធារណៈ។ ខ្ញុំសូមលើកឡើងថា វាមានការពិបាកជាមូលដ្ឋានក្នុងការពិបាកក្នុងការបង្ហាញ។ ប៉ុន្តែខ្ញុំសូមបញ្ជាក់ថាពេលវេលាដែលបានកន្លងផុតទៅ មិនបានបន្ថយអនុភាពនៃបទល្មើសនេះទេ។ ដូច្នេះ ហានិភ័យនៃបទល្មើសទាំងអស់នេះមានការកើនឡើង។

[១៣:៥៩:១០]

ប្រជាជនខ្មែរដែលទទួលរងគ្រោះផ្លូវចិត្តសាស្ត្រពីរយៈពេលដ៏កាចសាហាវនោះ គឺគាត់នៅតែប៉ះពាល់ដដែល។ តុលាការនេះ គឺធ្វើយ៉ាងណាត្រូវការការពារជនជាប់ចោទ។ យើងធានាសុវត្ថិភាពរបស់ជនជាប់ចោទ។ ដូច្នេះហើយ គឺជនជាប់ចោទមិនអាចលើកឡើងថា នឹងមិនមានការប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សាធារណៈនោះទេ។ ការប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈអាចរក្សាទៅបានរហូតទាល់តែយើងធ្វើការឃុំខ្លួនទៅដល់ជនជាប់ចោទ។ ដូច្នេះ ជាការសន្និដ្ឋាន ខ្ញុំសូមបញ្ជាក់ថានៅក្នុងពាក្យសុំរបស់មេធាវីការពារក្តី នួន ជា គាត់មិនបានបង្ហាញសូម្បីអ្វីមួយអំពីកាលៈទេសៈប្រែប្រួលក្នុងការដោះលែងជនជាប់ចោទ។ ការបញ្ជូនសំណុំរឿងពីអង្គបុរេជំនុំជម្រះទៅសាលាដំបូង គឺមិនអាចបង្ហាញថាវាជាកាលៈទេសៈប្រែប្រួលនោះទេ។ យើងខ្ញុំសូមជំទាស់ការស្នើសុំដោះលែងឲ្យមានសេរីភាពរបស់លោក នួន ជា ហើយខ្ញុំសូមឲ្យធ្វើការបន្តឃុំខ្លួនរបស់លោក នួន ជា រហូតដល់ការមានការជំនុំជម្រះ។

ខ្ញុំសូមអរគុណចំពោះក្រុមប្រឹក្សាជំនុំជម្រះដែលបានត្រងត្រាប់ស្តាប់នូវអ្វីដែលខ្ញុំលើកឡើង ហើយខ្ញុំសូមធ្វើការផ្តល់វេទិកានេះជូនលោកស្រី ជា លាង។

[១៤:០០:៥៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកជំទាវសហព្រះរាជអាជ្ញាជាតិ បាទ, សូមអញ្ជើញ!

**លោកស្រី ជា លាង៖**

សូមគោរពអង្គជំនុំជម្រះសាលាដំបូង ក៏ដូចជាអង្គសវនាការទាំងមូលសាជាថ្មីម្តងទៀត។ ខ្ញុំសូមធ្វើការឆ្លើយតបទៅនឹងសហមេធាវីការពារក្តីរបស់ជនជាប់ចោទ ខៀវ សំផន និងអៀង ធីរិទ្ធ ដែលបានប្តឹងមកអង្គជំនុំជម្រះសាលាដំបូង ដែលទាក់ទងនឹងករណីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ដែលបានសម្រេចបន្តរក្សាទុកជនជាប់ចោទក្នុងមន្ទីរឃុំបណ្តោះអាសន្ន។

ជាបឋមនេះ ខ្ញុំសូមធ្វើការបង្ហាញត្រួសៗអំពីមូលហេតុដែលនាំឲ្យកើតមាននូវសវនាការនៅពេលនេះ។ គឺនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយមួយដែលបញ្ជូនជនជាប់ចោទទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីធ្វើការជំនុំជម្រះ និងបានសម្រេចរក្សាជនជាប់ចោទទាំងអស់នៅក្នុងឃុំបណ្តោះអាសន្ន ទុកជូនអង្គជំនុំជម្រះសាលាដំបូងធ្វើការវិនិច្ឆ័យសេចក្តី។ ហើយដែលក្នុងនោះក៏បាន-- ក្នុងនោះក៏មានជនជាប់ចោទ ខៀវ សំផន និងអៀង ធីរិទ្ធ ផងដែរ។

[១៤:០២:១៧]

បន្ទាប់មកទៀត សហមេធាវីជនជាប់ចោទទាំងពីរបានប្តឹងប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតទៅអង្គបុរេជំនុំជម្រះ។ បន្ទាប់ពីបានពិនិត្យនិងពិចារណារួចមក អង្គបុរេជំនុំជម្រះបានចេញសាលដីកាមួយនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ដែលក្នុងនោះសម្រេចរក្សាទុកជនជាប់ចោទ ខៀវ សំផន និង អៀង ធីរិទ្ធ ឲ្យនៅក្នុងឃុំបណ្តោះអាសន្នជាបន្តទៀត។

ដោយមិនសុខចិត្តនឹងសេចក្តីសម្រេចនេះ និងដោយសារការភ័ន្តច្រឡំរបស់សហមេធាវីជនជាប់ចោទ ខៀវ សំផន និងអៀង ធីរិទ្ធ ទើបបានមានបណ្តឹងមកអង្គជំនុំជម្រះសាលាដំបូង ដើម្បីទាមទារឲ្យមានការដោះលែងកូនក្តីរបស់ខ្លួនឲ្យមានសេរីភាព ដោយសហមេធាវីការពារក្តីបានលើកឡើងនូវអំណះអំណាងរបស់ខ្លួនថា ករណីទីមួយ ពាក់ព័ន្ធនឹងជនជាប់ចោទ ខៀវ សំផន គឺមានការបកស្រាយទៅលើវិធាន៦៣(៣) នៃវិធានផ្ទៃក្នុង និងមាត្រា៣០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

ដែលទាមទារឲ្យនាំជនជាប់ចោទមកចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងរយៈពេលបួនខែ គិតចាប់ពីថ្ងៃសហចៅក្រមស៊ើបអង្កេតចេញដំណោះស្រាយ។

[១៤:០៣:៤៧]

ដូច្នេះសេចក្តីសម្រេចបន្តឃុំខ្លួនបណ្តោះអាសន្នលើរូបលោក ខៀវ សំផន របស់សហចៅក្រមស៊ើបអង្កេតបានអស់ប្រសិទ្ធភាព ហើយនិងតម្រូវឲ្យអង្គបុរេជំនុំជម្រះត្រូវតែបង្គាប់ឲ្យធ្វើការដោះលែង ខៀវ សំផន មានសេរីភាពជាបន្ទាន់។ ក្នុងករណីនេះសហព្រះរាជអាជ្ញាយល់ឃើញថា ការលើកឡើងរបស់សហមេធាវីការពារជនជាប់ចោទមិនអាចទទួលយកបានទេព្រោះថា បើពិនិត្យទៅលើវិធាន៦៨(៣) នៃវិធានផ្ទៃក្នុងបានបញ្ជាក់យ៉ាងច្បាស់ថា សេចក្តីសម្រេចរក្សាទុកជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ឬរបស់អង្គបុរេជំនុំជម្រះត្រូវអស់អានុភាពក្នុងរយៈពេលបួនខែក្រោយ។

[១៤:០៤:៤៤]

នៅពេលនេះ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលបានសម្រេចរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្នគឺត្រូវបានជំនួសដោយសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ។ ដោយហេតុថាជនជាប់ចោទបានប្តឹងមិនសុខចិត្តនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ទៅអង្គបុរេជំនុំជម្រះដើម្បីពិនិត្យនិងសម្រេច។ បន្ទាប់មក អង្គបុរេជំនុំជម្រះបានពិនិត្យលើករណីនេះតាមនីតិវិធីរហូតបានសម្រេចសេចក្តីលើករណីនេះ ដោយបានចេញសាលដីកានៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ បង្គាប់ឲ្យបន្តចិរវេលាឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន។ រហូតមកដល់ពេលដែលជនជាប់ចោទបាននាំបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

[១៤:០៥:៣៨]

លើសពីនេះទៅទៀត យើងឃើញថា សាលដីកានេះបានសម្រេចដោយបិទការតវ៉ាផងដែរ។ ដូច្នេះឃើញថា យោងវិធាន៦៨(៣) នៃវិធានផ្ទៃក្នុងគឺបានបញ្ជាក់យ៉ាងច្បាស់ថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ឬសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះត្រូវអស់អានុភាពក្នុងរយៈពេលបួនខែក្រោយ។ ពាក្យថាសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ឬសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ គឺមានន័យគ្រប់គ្រាន់ថា សេចក្តីសម្រេចនោះស្ថិតនៅក្នុងសមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ។ ហើយនៅក្នុងករណីនេះ គឺស្ថិតនៅក្នុងដំណាក់កាលសមត្ថកិច្ចរបស់អង្គបុរេជំនុំជម្រះ។ ដោយស្ថិតនៅសមត្ថកិច្ចរបស់អង្គបុរេជំនុំជម្រះ ដូច្នេះយើងអាចសំយោគអត្ថន័យនៃ

មាត្រា៦៣(៣) បានថា ក្នុងករណីណាក៏ដោយសេចក្ដីសម្រេចរក្សាទុកជនជាប់ចោទនៅក្នុងឃុំបណ្ដោះអាសន្នរបស់អង្គបុរេជំនុំជម្រះត្រូវរស់អានុភាពក្នុងរយៈពេលបួនខែក្រោយ។ ដូច្នេះការចាប់ផ្ដើមគិតរយៈពេលបួនខែនេះ គឺត្រូវគិតចាប់ពីសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះតទៅ។

[១៤:០៦:៥៦]

មានន័យថា ចាប់ពីថ្ងៃចេញសាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទលើដីកាដំណោះស្រាយ រហូតមកទល់ពេលនេះគឺមិនទាន់គ្រប់បួនខែនៅឡើយទេ។ ដូច្នេះឃើញថា ការលើកឡើងរបស់សហមេធាវីជនជាប់ចោទថាការឃុំខ្លួនជនជាប់ចោទលើសរយៈពេលនោះមិនអាចទទួលយកបានឡើយ។ ម៉្យាងទៀត សហមេធាវីការពារក្ដីជនជាប់ចោទ ខៀវ សំផន បានលើកឡើងដោយមិនមានហេតុផលសមស្របអំពីវិធាន៦៨(៣)នៃវិធានផ្ទៃក្នុង ហើយបានធ្វើការបកស្រាយដោយផ្ទុយនឹងការបកស្រាយនៃគោលការណ៍ច្បាប់ជាមូលដ្ឋាន។ ដូចដែលតុលាការអន្តរជាតិនានាបានលើកឡើងរួចមកហើយ វាជាវិធានចម្បងនៃការបកស្រាយច្បាប់ដែលគេមិនគួរបកស្រាយបញ្ញត្តិ ឬផ្នែកនៃបញ្ញត្តិច្បាប់មួយឲ្យលើសលុបនិងគ្មានន័យអ្វីនោះទេ។

[១៤:០៧:៥៦]

សច្ចធារណ៍ត្រូវបានធានា អ្នកតាក់តែងច្បាប់អនុម័ត ឬយល់ស្របទៅលើវិធានទាំងឡាយដែលបានយកមកពិចារណាយ៉ាងច្បាស់និងមានន័យពេញលេញនូវគ្រប់ធាតុរបស់វាទាំងអស់។ វាគួរឲ្យកត់សម្គាល់ថា យ៉ាងហោចណាស់ក៏មានជនជាប់ចោទម្នាក់ទទួលស្គាល់ថា អង្គបុរេជំនុំជម្រះមានអំណាចបន្តការឃុំខ្លួនបណ្ដោះអាសន្នបន្ថែមលើរយៈពេលបួនខែ ដែលមានសេចក្ដីសម្រេចបន្តឃុំខ្លួនបណ្ដោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយផងដែរ។

[១៤:០៨:៤០]

វិធាន៦៨ ស្របគ្នាជាមួយនឹងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដោយហេតុថាសភាស៊ើបសួរមានអំណាចឯករាជ្យក្នុងការបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្ន។ លើសពីនេះទៅទៀត មាត្រា២៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា សភាស៊ើបសួរបិទការស៊ើបសួរតាមសាលដីកាដំណោះស្រាយ។ កាលណាបិទការស៊ើបសួរតាមសាលដីកាដំណោះស្រាយនោះ គេនឹងអនុវត្តនូវមាត្រា២៤៧ ស្ដីអំពីដីកាដំណោះស្រាយដល់មាត្រា២៥០ ស្ដីពីដីកាដំណោះស្រាយនៃក្រមនេះដែរ។ ត្រូវយកមកអនុវត្តលើសាលដីកាដំណោះស្រាយរបស់សភាស៊ើបសួរ។ នេះជាច្បាប់

របស់កម្ពុជា។

[១៤:០៩:៤០]

ដូច្នេះឃើញថា យោងតាមអត្ថន័យខាងលើគឺបានផ្តល់អំណាចដល់សភាស៊ើបសួរដែលដើរតួនាទីក្នុងករណីអង្គបុរេជំនុំជម្រះនៅអ.វ.ត.ក គឺមានសិទ្ធិអំណាចរក្សាទុកជនជាប់ឃុំបណ្តោះអាសន្នបួនខែបន្តទៀត គឺបន្ទាប់ពីអង្គបុរេជំនុំជម្រះចេញសាលក្រមសម្រេចលើបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ។

ដូច្នេះយើងអាចលើកជាសំណួរថា តើដីកាដំណោះស្រាយចូលជាស្ថាពរនៅពេលណា? នៅក្នុងករណីនេះវាអាចមានពីរយ៉ាង។ ទីមួយ បើសិនជាគ្មានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតទេនោះ ដីកាដំណោះស្រាយដែលរក្សាទុកជនជាប់ចោទឲ្យនៅក្នុងឃុំបណ្តោះអាសន្ន រហូតដល់ពេលនាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គឺមានរយៈពេលបួនខែ។

[១៤:១០:៤៣]

តែផ្ទុយទៅវិញ បើមានបណ្តឹងឧទ្ធរណ៍ដូចករណីដែលជាក់ស្តែងដូចយើងថ្ងៃនេះ គឺមានសិទ្ធិរក្សា-- សភាស៊ើបសួរមានសិទ្ធិរក្សាទុកជនជាប់ចោទឲ្យនៅក្នុងឃុំបណ្តោះអាសន្នរហូតដល់ពេលនាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងរយៈពេលបួនខែ បន្ទាប់ពីអង្គបុរេជំនុំជម្រះចេញសាលដីកាលើដីកាដំណោះស្រាយ។ ក្នុងន័យនេះ គឺដីកាដំណោះស្រាយចូលជាស្ថាពរនៅថ្ងៃដែលសភាស៊ើបសួរឬអង្គបុរេជំនុំជម្រះចេញសាលដីកាលើដីកាដំណោះស្រាយ។

[១៤:១១:៣០]

ចំណុចទីពីរ គឺពាក់ព័ន្ធនឹងការឆ្លើយតបទៅនឹងជនជាប់ចោទ អៀង ធីរិទ្ធ គឺទាក់ទងនឹងជនជាប់ចោទ អៀង ធីរិទ្ធ នេះ គឺពាក់ព័ន្ធនឹងមាត្រា៦៨(៣) នេះដែរ គឺសហព្រះរាជអាជ្ញាគឺយកការបកស្រាយដូចគ្នានឹងករណីជនជាប់ចោទ ខៀវ សំផន ដែរ ដោយមិនចាំបាច់លើកយកមកលើកមកនិយាយសាជាថ្មីទៀតទេ។

ដោយឡែកករណីជនជាប់ចោទ អៀង ធីរិទ្ធ បានលើកឡើងបន្ថែមមួយចំណុចបន្ថែមទៀតគឺសាលដីការបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ មិនបានអនុលោមតាមតម្រូវការចាំបាច់ ដើម្បីបង្កើតបានជាសេចក្តីសម្រេចដូចដែលមានចែងក្នុងវិធាន៧៧(១៤) នៃវិធានផ្ទៃក្នុងនោះទេ។ នេះជាចំណុចមួយដែលខុសប្លែកនឹងការប្តឹងរបស់សហមេធាវីជនជាប់ចោទ ខៀវ សំផន។ ក្នុងនេះដែរ សហព្រះរាជអាជ្ញាយល់ឃើញថា ការលើកឡើងរបស់សហមេធាវីការពារក្តីរបស់ជនជាប់ចោទ

ក៏មិនអាចទទួលយកបានដូចគ្នា។

[១៤:១២:៤៣]

បើពិនិត្យទៅលើវិធានផ្ទៃក្នុងត្រង់វិធាន៧៧(១៣) បានបញ្ជាក់យ៉ាងច្បាស់ថា សាលដីការបស់អង្គបុរេជំនុំជម្រះជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។ លើសពីនេះទៀត យើងឃើញថាអង្គជំនុំជម្រះសាលដំបូងក៏មិនមែនជាសាលាឧទ្ធរណ៍ ហើយក៏គ្មានសមត្ថកិច្ចក្នុងការវាយតម្លៃអំពីសុពលភាពនៃដីការបស់អង្គបុរេជំនុំជម្រះដែរ។

ដូច្នេះសាលដីការបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ មិនអាចកែប្រែបានឡើយ។

[១៤:១៣:២៧]

ដូចដែលបានលើកឡើងក្នុងករណីជនជាប់ចោទ ខៀវ សំផន រួចមកហើយ បើអង្គជំនុំជម្រះសាលាដំបូងមានតួនាទីជាសាលាឧទ្ធរណ៍សម្រាប់វិនិច្ឆ័យសុពលភាពនៃដីការបស់អង្គបុរេជំនុំជម្រះផងនិងជាអ្នកត្រួតពិនិត្យឡើងវិញលើរាល់បញ្ហានានាដែលអង្គបុរេជំនុំជម្រះបានសម្រេចរួចជាស្ថាពរផងនោះវានឹងធ្វើឲ្យវិធាន៧៧ នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក មិនមានតម្លៃអ្វីទាំងអស់។ ដូច្នេះករណីនេះមិនអាចកើតមានបានឡើយ។

បើទោះបីជាអង្គជំនុំជម្រះសាលាដំបូង មានសិទ្ធិពិនិត្យឡើងវិញលើភាពត្រឹមត្រូវនៃសាលដីការបស់អង្គបុរេជំនុំជម្រះក្តី។ ហើយបើទោះបីជា អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សាលដីការបស់អង្គបុរេជំនុំជម្រះក្តីពុំមានសំអាងហេតុគ្រប់គ្រាន់យ៉ាងណាក៏ដោយ ក៏ពុំអាចធ្វើឲ្យសាលដីការបស់អង្គបុរេជំនុំជម្រះក្លាយជាមោឃភាពបានដែរ។

[១៤:១៤:៣៨]

យោងតាមយុត្តិសាស្ត្រតុលាការអន្តរជាតិក្នុងករណី *ផ្លូវិច* ដូចដែលសហការីរបស់ខ្ញុំលើកឡើងអម្បាញ់មិញនេះ គឺជាឧទាហរណ៍ស្រាប់ដែលគាត់លើកពីករណី នួន ជា ដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់តុលាការឧទ្ធរណ៍នៅតុលាការ *អាយ.ស៊ី.ធី.វ៉ាយ* នេះជាខ្ញុំមិនបាច់លើកឡើងវិញនូវចំណុចនេះដដែលៗទេ។

ជាមួយគ្នានេះដែរ បើពិនិត្យទៅលើសំណើរបស់សហមេធាវីជនជាប់ចោទដែលស្នើសុំជាបន្ទាន់ឲ្យដោះលែងកូនក្តីរបស់ខ្លួននោះ គឺជាបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាបង្គាប់ឲ្យបន្តថិរវេលានៃការឃុំ

ខ្លួនបណ្ដោះអាសន្នជនជាប់ចោទដែលសម្រេចដោយអង្គបុរេជំនុំជម្រះ។

[១៤:១៥:២៤]

បើពិនិត្យនិយមន័យនៃច្បាប់ជាមូលដ្ឋានពាក្យថា "ប្ដឹងឧទ្ធរណ៍" មានន័យថាស្នើសុំឲ្យតុលាការថ្នាក់លើពិនិត្យឡើងវិញ សេចក្ដីសម្រេច ឬសាលក្រម ឬសាលដីកា របស់តុលាការថ្នាក់ក្រោម។ ចំពោះសំណើនៅពេលនេះ គឺសហមេធាវីការពារជនជាប់ចោទបានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងពិនិត្យឡើងវិញនូវសុពលភាពនៃសាលដីការបស់អង្គបុរេជំនុំជម្រះ ហើយវិធានផ្ទៃក្នុងបានបញ្ជាក់យ៉ាងច្បាស់ថា សាលដីការបស់អង្គបុរេជំនុំជម្រះបិទផ្លូវតវ៉ា។

[១៤:១៦:០៥]

ការលើកឡើងនូវចំណុចនេះ ទាំងនេះពុំមែនទុកឲ្យជនជាប់ចោទគ្មានដំណោះស្រាយនោះឡើយ ហើយយន្តការដែលត្រឹមត្រូវ គឺជនជាប់ចោទអាចប្ដឹងតវ៉ាអំពីការឃុំខ្លួនរបស់គាត់ដោយដាក់ពាក្យសុំទៅអង្គជំនុំជម្រះសាលាដំបូងដោយយោងតាមវិធាន៨២(៣) នៃវិធានផ្ទៃក្នុង។ នោះមានន័យថា នៅក្នុងដំណាក់កាលនេះ សហមេធាវី ក៏ដូចជាជនជាប់ចោទអាចស្នើទៅអង្គជំនុំជម្រះសាលាដំបូងដើម្បីដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្នបាន។ នេះជាច្បាប់មួយដែលអនុញ្ញាត។

[១៤:១៦:៤១]

ចំណុចចុងក្រោយ គឺមានការកត់សម្គាល់ចំណុចសំខាន់មួយដែលៗយើងគិតថា នៅតុលាការអន្តរជាតិក៏បានអនុម័តនូវ-- អនុវត្តនៅចំណុចនេះដែរ ប្រសិនបើមានការឃុំខ្លួនដោយខុសនីតិច្បាប់ក៏ដោយ ក៏ដំណោះស្រាយដ៏សមស្របនោះ គឺមិនមែនជាការដោះលែងឲ្យជនជាប់ចោទនោះឡើយ។ ព្រោះថា បើពិនិត្យទៅលើតុលាការអន្តរជាតិនានាដែលបានលើកឡើងថា ដំណោះស្រាយចំពោះការឃុំខ្លួនបណ្ដោះអាសន្នមិនត្រឹមត្រូវតាមនីតិវិធីច្បាប់ គឺជាការការកាត់បន្ថយទោស ប្រសិនបើជនជាប់ចោទត្រូវបានកាត់ឲ្យជាប់ទោស និងសងសំណងជាហិរញ្ញវត្ថុ ប្រសិនបើជាជនជាប់ចោទត្រូវបានសម្រេចឲ្យរួចផុតពីបទចោទប្រកាន់។ នេះជាយុត្តិសាស្ត្រតុលាការអន្តរជាតិដែលបានអនុវត្តកន្លងមក។

[១៤:១៧:៣៧]

ចំណុចមួយទៀតដែរ សហព្រះរាជអាជ្ញាមានការកត់សម្គាល់ទៅលើវិធាន៦៣(៣) នៃវិធានផ្ទៃក្នុងអំពី-- ក៏ដូចជាមាត្រា២០៥ នីតិវិធីព្រហ្មទណ្ឌកម្ពុជាដែរ ស្ដីអំពីមូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន។ សហមេធាវីជនជាប់ចោទទាំងបីបានលើកឡើងកាលពីព្រឹកមិញហ្នឹងហើយ មានការកត់

សម្គាល់ផ្នែកខាងភាគបញ្ចប់នៃការសន្និដ្ឋាននោះ សហព្រះរាជអាជ្ញាពេលនេះ គឺសហការីរបស់ខ្ញុំបានលើកឡើងមួយចំនួន ហើយមួយចំនួនតូចទេដែលខ្ញុំចង់បំពេញបន្ថែមនូវចំណុចនេះ ដែលជាការមួយកត់សម្គាល់ ហើយនិងគួរឲ្យមានការចាប់អារម្មណ៍។

[១៤:១៨:២០]

អ្វីដែលសហមេធាវីជនជាប់ចោទទាំងបី មានលក្ខណៈប្រហាក់ប្រហែលគ្នា ហើយនឹងធ្វើការឆ្លើយតបនឹងមាត្រា៦៣(៣) ស្តីពីការ-- មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ននេះ។

ខ្ញុំសូមលើកនូវចំណុចមួយទាក់ទងនឹងការដែលមេធាវីទាំងបីបានលើកឡើងថា មិនមានការគាបសង្កត់ទៅលើការសាក្សី។

រហូតមកដល់ពេលនេះ យើងគិតថាសវនាការអង្គសេចក្តីហ្នឹង អត់ទាន់មានកើតនៅឡើយទេ ហើយដែលសាក្សីទាំងនោះ អង្គជំនុំជម្រះសាលាដំបូងអាចនឹងត្រូវការចាំបាច់ដើម្បីមកឆ្លើយបំភ្លឺនៅចំពោះមុខសវនាការនាពេលខាងមុខ។ ព្រោះថាជនជាប់ចោទអាចមានសិទ្ធិពិនិត្យមើលសំណុំរឿង និងអាចពិនិត្យមើលឈ្មោះសាក្សីសំខាន់ៗបាន ហើយមានសាក្សីមួយចំនួនក៏ត្រូវការវិធានការការពារផងដែរ។

[១៤:១៩:១៤]

កន្លងមកថ្មីៗនេះ ការិយាល័យសហព្រះរាជអាជ្ញាបានផ្ញើបញ្ជីឈ្មោះសាក្សីជូនទៅអង្គជំនុំជម្រះសាលាដំបូងរួចហើយ ស្តីអំពីសាក្សីដែលសុំវិធានការការពារលើករណីនេះ។ ផ្អែកតាមនេះ ហានិភ័យដែលថាគាត់នឹងអាចប្រើឥទ្ធិពលទៅលើសាក្សី ហើយដែលអាចធ្វើឲ្យសាក្សីទាំងនោះមិនហ៊ានមកផ្តល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក។

ចំណុចមួយទៀត ស្តីអំពីសុវត្ថិភាពរបស់ជនជាប់ចោទ។ ដូចយើងបានដឹងហើយថា កាលពីមុនជនជាប់ចោទទាំងអស់មិនទាន់បានចោទប្រកាន់ជាផ្លូវការទេ។ ប៉ុន្តែនៅពេលនេះ តុលាការនេះត្រូវបានកើត និងផ្សព្វផ្សាយទូទាំងពិភពលោក។ ដូច្នេះជនរងគ្រោះក៏បានស្គាល់ជនជាប់ចោទច្រើន តាមរយៈវិទ្យុក៏ដូចជាទូរទស្សន៍ ដែលធ្វើឲ្យជនរងគ្រោះមានការខឹងសម្បា អាចមានការសងសឹកទៅលើជនជាប់ចោទដែលមាននៅក្នុងនេះស្រាប់។

[១៤:២០:២៣]

ដូច្នេះចំណុចសំខាន់មួយផងដែរ ដែលទាក់ទងនឹងបញ្ហាសុខភាព ជាចំណុចមួយដែលយើងគួរឲ្យ

កត់សម្គាល់ដែរ។ ដូចយើងដឹងហើយថា ជនជាប់ចោទទាំងអស់នៅទីនេះសុទ្ធតែជាមនុស្សដែលវ័យចាស់ ហើយយើងឃើញថាសេវាពេទ្យនៅទីនេះកន្លែងនេះ ក៏ដូចមន្ទីរឃុំឃាំងគឺនៅជិត ស្ថិតនៅក្បែរ អ.វ.ត.ក យើងដែលជាលក្ខណៈងាយស្រួលក្នុងការថែទាំសុខភាព ក៏ដូចជាការមិន-- ចូលរួមក្នុងដំណើរការនីតិវិធីរបស់តុលាការមានការងាយស្រួល។ នេះជាចំណុចមួយដែលគួរឲ្យចាប់អារម្មណ៍ដែរ មិនមែនស្ថិតនៅក្នុងចំណុច ៦៣(៣) ទេ ប៉ុន្តែវាជាលក្ខណៈមួយអំណោយផល ដែលយើងគិតថា វានឹងអាចបង្កលក្ខណៈមួយដំណើរនីតិវិធីយើងបានរលូន។

[១៤:២១:០៧]

ដូច្នេះ លក្ខខណ្ឌផ្សេងៗសម្រាប់ការឃុំខ្លួនតាមវិធាន ៦៣(៣) នេះ គឺនៅតែបំពេញបានរហូតមកដល់សព្វថ្ងៃនេះ ព្រោះថាជនជាប់ចោទមិនបានបង្ហាញភ័ស្តុតាងថ្មីដើម្បីជំនួសលើភ័ស្តុតាងដែលមានស្រាប់នោះទេ។ អាស្រ័យហេតុនេះ ដូចការបកស្រាយខាងលើទាំងប៉ុន្មាននេះ សូមឲ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចបដិសេធចោលនូវបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តីជនជាប់ចោទក៏ដូចជាសហមេធាវីការពារក្តី អៀង ធីរិទ្ធ ចោលជាអសារបង់។

សូមអរគុណ។

[១៤:២១:៥៤]

**ប្រធានអង្គជំនុំ៖**

អរគុណសហព្រះរាជអាជ្ញា ដែលបានធ្វើសេចក្តីសន្និដ្ឋានតប។

ឥឡូវនេះអង្គជំនុំជម្រះបានស្តាប់នូវសេចក្តីថ្លែងការណ៍តបរបស់សហព្រះរាជអាជ្ញាចប់សព្វគ្រប់ហើយ។ សំណួរសួរថាតើមេធាវីការពារក្តីឲ្យជនជាប់ចោទទាំងបីនាក់ ឬជនជាប់ចោទដែលមានវត្តមាននៅទីនេះ តើមានអ្វីត្រូវធ្វើសេចក្តីថ្លែងការណ៍តបវិញចំពោះសេចក្តីថ្លែងការណ៍តបរបស់សហព្រះរាជអាជ្ញាដែរឬទេ? ប្រសិនបើមានសូមអញ្ជើញ។

សូមអញ្ជើញពីមេធាវីលោក-- លំដាប់ពីលោក-- មេធាវីលោក នួន ជា មេធាវីការពារក្តីឲ្យ ខៀវ សំផន ហើយនិងចុងក្រោយគឺមេធាវីការពារក្តីឲ្យលោកស្រី អៀង ធីរិទ្ធ។ ហេតុដូច្នេះហើយសូមបើ-- ប្រសិនបើមានសូមអញ្ជើញ។

សូមអញ្ជើញ!

[១៤:២២:៤០]

**លោក ហ្សាស្តេី ប៉ោះ**

លោកប្រធាន ខ្ញុំសូមសម្រាករយៈពេលដប់នាទីដើម្បីអាចឲ្យយើងរៀបចំនូវការឆ្លើយតបទៅវិញ ដោយសារតែវាជាលើកដំបូង ខ្ញុំស្តាប់ឮ--

**ប្រធានអង្គជំនុំ៖**

សុំៗ មានបញ្ហាសំឡេង ខាងអ្នកបច្ចេកទេសសំឡេងមានបញ្ហាអី? មានបញ្ហាសំឡេងទេ? មានបញ្ហាសំឡេងទេ? ចុះហេតុយ៉ាងម៉េចវាឮហ្គឹត ហ្គួតៗអ៊ីចឹង?

[១៤:២៣:៤៤]

សូមអញ្ជើញលោកមេធាវីម្តងទៀត បាទសូមនិយាយម្តងទៀត ខ្ញុំអំមិញស្តាប់អត់បានវាអស់ថ្ម។

**លោក ហ្សាស្តេី ប៉ោះ**

សូមអរគុណលោកប្រធាន។ ក្រុមមេធាវីការពារក្តីសូមសម្រាកដប់នាទីដើម្បីឲ្យយើងខ្ញុំអាចឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា។ នេះជាលើកទីមួយដែលយើងស្តាប់ចម្លើយតបពីសហព្រះរាជអាជ្ញា។ ដូច្នេះហើយការសម្រាកនេះវាអាចធ្វើឲ្យយើងមានសមភាពរវាងគូភាគីក្តីក្នុងការរៀបចំការឆ្លើយតប។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ឃើញថាសំណើសុំរបស់លោកមេធាវីមានមូលហេតុសមស្រប។ អ៊ីចឹងអង្គជំនុំជម្រះទទួលយកនូវសំណើនេះ។ ហើយអ៊ីចឹងគឺអង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះទៅរហូតដល់ម៉ោងពីរ និង សែសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ សូមសម្រាកចុះ ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលបិទ-- រូតបិទវាំងនង នៅពេលដែលអង្គជំនុំជម្រះចេញផុតពីសាលសវនាការ នឹងឲ្យបើកវិញនៅមុនពេលអង្គជំនុំជម្រះចូលមកបន្ទប់សវនាការ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:២៥នាទី ដល់ម៉ោង ១៤:៥២នាទី)*

[១៤:៥២:០១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអស់លោក លោកស្រីអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលតទៅទៀត។ ហើយជាបន្តសូមអញ្ជើញមេធាវីការពារក្តីទាំងបីក្រុមឡើងធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា។ ហើយអង្គជំនុំជម្រះសូមជម្រាបផងដែរថា មេធាវីមួយក្រុមៗសម្រាប់ជនជាប់ចោទនីមួយៗនេះមានពេល១០មីនុតក្នុងការឆ្លើយតបនេះ។ សូមអញ្ជើញមេធាវីការពារក្តី នួន ជា។

[១៤:៥៣:០៦]

**លោក សុន អរុណ៖**

សូមអរគុណ សូមគោរពអង្គសវនាការសាជាថ្មី។ ចំពោះការចោទប្រកាន់របស់សហចៅក្រម-- សហព្រះរាជអាជ្ញានៅលើចំណុចវិធាន៦៣(៣) ខ្ញុំសូមធ្វើការការពារដូចតទៅនេះ៖

ពុំមានទឡ្ហីករណ៍បន្ថែមដើម្បីធ្វើយុត្តកម្មលើការឃុំខ្លួនបណ្តោះអាសន្ន។ ដូចដែលតម្រូវដោយវិធាននិងគោលការណ៍នៃនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានធ្វើយុត្តកម្មបន្ថែមលើដីកាឃុំខ្លួនបណ្តោះអាសន្នដោយយោងទៅលើភាពគ្រោះថ្នាក់គ្មានមូលដ្ឋាន។ ហានិភ័យនៃការរត់គេចខ្លួន នួន ជា ពីដំណើរការនីតិវិធី ការជ្រៀតជ្រែកទៅលើសាក្សីសត្តានុពល ជាពិសេសអ្នកដែលសង្ស័យថា ស្ថិតនៅក្រោមការត្រួតត្រារបស់គាត់កាលពីមុន និងលទ្ធភាពនៃគំរាមកំហែងសណ្តាប់ធ្នាប់សាធារណ: និងសន្តិសុខផ្ទាល់ខ្លួនរបស់ នួន ជា។

ទោះបីយ៉ាងនេះក្តី ការធ្វើ យុត្តកម្មទាំងនេះ គឺផ្អែកតែទៅលើសញ្ញាណអរូបី ជាជាងទឡ្ហីករណ៍នៅក្នុងអង្គហេតុពិតប្រាកដ។

[១៤:៥៤:៤៣]

ខ្ញុំសូមវែកញែកនៅក្នុងជំពូក-- វិធាន៦៣(៣) ដូចតទៅនេះ៖

ពុំមានហានិភ័យពិតប្រាកដនៃការរត់គេចខ្លួនរបស់ នួន ជា ពីដំណើរការនីតិវិធីទេ។ តែមួយគត់ដែលបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួររបស់ការិយាល័យសហព្រះរាជអាជ្ញា លើចំណុចនេះគឺជា គឺថា នួន ជា កាន់លិខិតឆ្លងដែន និងរស់នៅជិតព្រំប្រទល់ប្រទេសថៃ។ ចំពោះ នួន ជា វិញគាត់បានបង្ហាញថា បើគាត់មានបំណងចង់រត់គេចខ្លួននោះ គាត់បានរត់បាត់ខ្លួនទៅ-- រត់បាត់ទៅហើយ និងគាត់មានបំណងចូលរួមក្នុងដំណើរការនីតិវិធី។

បើទោះជាគាត់បានមានឱកាសជាច្រើន និងធ្វើដូច្នេះក៏ដោយ ការិយាល័យសហចៅក្រមស៊ើបអង្កេតលើកឡើងថា ពីព្រោះ នួន ជា ប្រឈមមុខនឹងការដាក់ទោសអតិបរមា ដោយជាប់ពន្ធនាគារមួយ

ជីវិត បើរកឃើញថាមានទោស។ ចំណុចនេះធ្វើឲ្យមានការខ្លាចថា នួន ជា នឹងរត់គេចខ្លួនពីដំណើរការនីតិវិធី បើទោះបី នួន ជា ប្រកែកចំពោះការលើកឡើងនោះក៏ដោយ។

[១៤:៥៦:០៥]

ប្រជាពលរដ្ឋនៅតំបន់ប៉ៃលិនបានស្គាល់ នួន ជា កៅសិបភាគរយ។ ប្រជាពលរដ្ឋទាំងអស់នោះមិនដែលមានការទោមនស្សជាមួយ នួន ជា ឡើយ។

សក្ខីថ្មីមួយទៀតដែលទើបនឹងកើតឡើង តុលាការចង់បានបំផុតយកមកធ្វើជាសក្ខីភាព ប៉ុន្តែមិនបាន។ ប៉ុន្តែខ្ញុំសូមលើកសក្ខីភាពនេះដើម្បីជូនទៅតុលាការនេះជាសក្ខីភាពថ្មីសម្រាប់ដោះបន្ទុក នួន ជា។

[១៤:៥៦:៤៤]

ថ្មីៗនេះនៅក្នុងភាពយន្ត *អែនមី អោះ ឌឹភី ផិផល(និយាយភាសាអង់គ្លេស)*-- សត្រូវនឹងប្រជាជន។ លោក នួន ជា បានសម្ភាសន៍ជាមួយអ្នកផលិតភាពយន្តថា គាត់បានដឹងថា “មានគេចង់ចាប់គាត់” តែគាត់បានប្រាប់ទៅអ្នកថត និងអ្នកផលិតភាពយន្តនោះថា “គាត់ចង់សហការណ៍ជាមួយតុលាការ ដើម្បីបំភ្លឺទៅប្រជាជនពលរដ្ឋខ្មែរទូទាំងប្រទេស និងមតិពិភពលោកអំពីអ្វីដែលលោក នួន ជា បានធ្វើ”។

ការប្រព្រឹត្តិដែលសហព្រះរាជអាជ្ញាបានចោទនោះ តើត្រូវនឹងរឿងពិតដែលកើតឡើងទេ? ឬគ្រាន់តែមានអ្នកនិពន្ធសៀវភៅ ឬអ្នកនិពន្ធកាសែត ឬភាពយន្តបង្កើតឡើង ហើយយកមកធ្វើជាសក្ខីភាពដើម្បីចោទប្រកាន់កូនក្តីខ្ញុំ។

[១៤:៥៧:៤៧]

យើងសវនាការថ្ងៃនេះ គឺនិយាយពីការអនុវត្តនីតិវិធីរបស់អង្គបុរេជំនុំជម្រះបានធ្វើខុស គឺមាន-- គឺបានសម្រេចដាក់កូនក្តីខ្ញុំឲ្យនៅក្រៅឃុំបន្តទៅទៀត ដោយពុំបានធ្វើការសំអាងហេតុដែលខុសនឹងវិធាន ៨២(៣) និងវិធាន៦៨(៣) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

ផ្អែកតាមអង្គហេតុសញ្ញាណនៃការរត់គេចខ្លួនរបស់ នួន ជា ពីដំណើរការនីតិវិធី អ.វ.ត.ក ជាហេតុមិនអាចឲ្យជឿបាន។ តាមពិត នួន ជា បាននិយាយជាច្រើនដង ជាពិសេសនៅសវនាការអំពីការឃុំខ្លួនបណ្តោះអាសន្នថា “គាត់មានបំណងចូលរួមក្នុងដំណើរការនីតិវិធីយ៉ាងខ្លាំង។ គាត់ជាប្រជាពលរដ្ឋខ្មែរម្នាក់ ដែលពេញចិត្តនឹងខ្លួនឯង និងជាមួយគ្រួសារ និងមានបំណងជាពលរដ្ឋស៊ីវិលចំពោះប្រទេសជាតិ ហើយគ្មានបំណងរត់ចោលអ្នកទាំងនោះឡើយ”។

[១៤:៥៨:៥៦]

នួន ជា បានដឹងយ៉ាងច្បាស់ថា ការនាំខ្លួនដែលនឹងកើតមានចំពោះរូបគាត់នឹងមានបន្តស៊ើបអង្កេត និងគ្មានចេតនាប៉ុនប៉ងរត់គេចពីលំនៅរបស់គាត់នៅប៉ៃលិនឡើយ។ មិនមែនប៉ុណ្ណោះ គាត់បានដឹងមុនថ្ងៃ១៩ ខែកញ្ញា ឆ្នាំ២០០៧ ថានឹងមានគេព័ទ្ធផ្ទះគាត់ ហើយនិងចាប់គាត់មួយអាទិត្យមុន។ គាត់អត់រត់ទៅណាទេ គាត់នៅផ្ទះគាត់ ដើម្បីសហការជាមួយនឹងតុលាការ។

ជាការពិត ដោយមានអ្នកសារព័ត៌មានផងនោះ គាត់បានរង់ចាំទាំងអំណត់នូវការមកដល់នៃអាជ្ញាធរ អ.វ.ត.ក នៅព្រឹកថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧។ បើទោះបីជាការបង្ហាញកម្លាំងក្នុងការអនុវត្តដីកានាំខ្លួន ក៏ នួន ជា ស្ម័គ្រចិត្តប្រគល់ខ្លួនភ្លាម និងគ្មានការរារែកចំពោះដីកានោះដែរ។

[១៥:០០:០៣]

ខ្ញុំសូមបញ្ជាក់ថានៅថ្ងៃទៅចាប់លោក នួន ជា គឺថ្ងៃ១៩ ខែកញ្ញា ឆ្នាំ២០០៧។ អាជ្ញាធរសមត្ថកិច្ចទៅចាប់ នួន ជា ដោយគ្មានបង្ហាញដីកាឲ្យនាំខ្លួនឲ្យចាប់ខ្លួនទេ។ ថ្ងៃហ្នឹងគឺគ្មាន។ នួន ជា អត់បានឃើញដីកាឲ្យចាប់ខ្លួនទេ។ នេះជាការខុសច្បាប់មួយរបស់អាជ្ញាធរសមត្ថកិច្ច។

ជាទឡ្ហីករណ៍បើទោះជាសន្មតថា លោក នួន ជា មានបំណងរត់គេចខ្លួន ជរាភាពរបស់គាត់ រួមមាន អាយុ សុខភាព និងការខ្វះខាតធនធានហិរញ្ញវត្ថុ ធ្វើឲ្យគាត់គ្មានលទ្ធភាពធ្វើដូច្នេះបានឡើយ។

[១៥:០០:៤៣]

អាជ្ញាធរកម្ពុជា និង អ.វ.ត.ក មានប្រាកដណាស់នៅឆន្ទៈ និងលទ្ធភាពខាងសម្ភារៈគ្រប់គ្រាន់ដើម្បីឃ្លាំមើល។ កម្រិតកំណត់សកម្មភាពរបស់ នួន ជា នៅក្នុងស្រុកបានយ៉ាងប្រាកដ។ គ្មានការប៉ុនប៉ងណាមួយត្រូវបានលើកឡើងនៅឯសវនាការស្តីអំពីឃុំខ្លួន ដើម្បីទទួលបាននូវការធានានៃការចូលខ្លួនពីអ្នកធានា ឬការធានាណាមួយពី ឬ នួន ជា ហើយគ្មានសេចក្តីយោងណាមួយបានលើកឡើងក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចំពោះកត្តាជាក់លាក់នានាដែលតម្រូវ ដែលអាចគាំទ្រ ឬទាត់ចោលហានិភ័យ ឬ សុំទោស! ឬទាត់ចោលចោទហានិភ័យនៃការរត់គេចខ្លួនពីដំណើរការនីតិវិធី។

[១៥:០១:៤៣]

ចំពោះ នួន ជា ពុំមានហានិភ័យជាក់ស្តែងដែលនាំឲ្យ នួន ជា ចូលជ្រៀតជ្រែកសាក្សី។ ដើម្បីគាំទ្រចំណុចនេះ ការិយាល័យសហព្រះរាជអាជ្ញាសន្និដ្ឋានថា នួន ជា ពីមុនធ្លាប់បានស្តីបន្ទោសអ្នកក្រោមបង្គាប់របស់គាត់ថាមិនបានបំផ្លាញភ័ស្តុតាងចោល។

ជាចម្លើយតប នួន ជា បាននិយាយថា គាត់គ្មានលទ្ធភាពបំផ្លាញភ័ស្តុតាងចោលបានទេ។ គួសបញ្ជាក់ថា ដោយពិចារណាពីតំណែងតាមឋានានុក្រមរបស់ នួន ជា បើសិនទុកឲ្យគាត់នៅមានសេរីភាពនោះ ខ្លាចក្រែងគាត់នឹងប៉ុនប៉ងគាបសង្កត់សាក្សី និងជនរងគ្រោះ ជាពិសេសអ្នកធ្លាប់នៅក្រោមអំណាចរបស់គាត់។

[១៥:០២:៣៥]

ហានិភ័យនៃការរត់គេចខ្លួន គ្រោះថ្នាក់បង្កឡើងដោយការគាបគាបសង្កត់សាក្សី និងឬការបំផ្លាញភ័ស្តុតាងត្រូវបានគាំទ្រដោយអង្គហេតុជាក់លាក់ទាក់ទិនជាមួយជនត្រូវចោទ។

ទោះបីយ៉ាងណាក្តី ការចោទប្រកាន់របស់ការិយាល័យសហព្រះរាជអាជ្ញាទៅលើការរិះគន់របស់ នួន ជា កាលពីពេលមុន គឺការចោទប្រកាន់គ្មានមូលដ្ឋានក្រៅតែពីការធ្វើអត្ថាធិប្បាយមិនមាំទាំប៉ុណ្ណោះ។

ដូចគ្នានេះដែរ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នខ្វះអង្គហេតុគាំទ្រ ហើយបង្ហាញវិញនូវការអត្ថាធិប្បាយបែបសន្និដ្ឋដូចជា ខ្លាចក្រែង គាត់ប្រហែលប៉ុនប៉ង គាត់នឹងមានជំហរអាចគាបគាបសង្កត់សាក្សី និងជនរងគ្រោះ។

[១៥:០៣:៣០]

ដោយផ្អែកលើកំណត់ហេតុសព្វថ្ងៃ នេះជាការសន្និដ្ឋមិនសមហេតុសមផល និងមិនអាចអនុវត្តន៍តាមគតិយុត្តិ។ ដូច្នេះត្រូវតែបដិសេធចោល។

ដូចបានរៀបរាប់ពីខាងលើមក ជាក់ស្តែងបើទោះជា នួន ជា ទំនងជាអាចនៅមានវិធានការ មានឥទ្ធិពលមួយចំនួន ក៏មិនមានន័យថានឹងអនុវត្តន៍ឥទ្ធិពលនោះដោយខុសច្បាប់ឡើយ។ នៅក្នុងកំណត់ហេតុក៏គ្មានភ័ស្តុតាងទាល់តែសោះដែលថា នួន ជា បានធ្វើការទាក់ទងដោយមិនត្រូវតែបដិសេធចោល។

[១៥:០៤:១០]

ដូចបានរៀបរាប់មកខាងលើមកនេះ ជាក់ស្តែងបើទោះជា នួន ជា ទំនងជាអាចនៅមានវិធានការ មានឥទ្ធិពលមួយចំនួន ក៏មិនមានន័យថានឹងអនុវត្តន៍ឥទ្ធិពលនោះខុស ដោយខុសច្បាប់ឡើយ។ នៅក្នុងកំណត់ហេតុក៏គ្មានភ័ស្តុតាងទាល់តែសោះដែលថា នួន ជា បានធ្វើការទាក់ទងដោយមិនសមរម្យជាមួយសាក្សី ជនរងគ្រោះ ឬភាគីទីបីណាម្នាក់ ឬថាបានលើកទឹកចិត្តតាមវិធីផ្សេងឲ្យបំផ្លាញឯកសារទាំងឡាយទាក់ទិនជាមួយករណីប្រឆាំងគាត់។

ហើយបើសិននិយាយអំពីការសន្តិសុខរបស់ នួន ជា ហើយនិងបំផ្លាញសណ្តាប់ធ្នាប់ ឬគំរាម

កំហែងសណ្តាប់ធ្នាប់សាធារណៈទៅវិញ ខ្ញុំសូមការពារដូចតទៅនេះ៖

[១៥:០៥:០២]

ការិយាល័យអយ្យការគ្មានអង្គហេតុអ្វីទេ-- គ្មានអង្គហេតុគាំទ្រទឡ្ហីករណ៍ទាំងនេះទេ ហើយ នួន ជា បានថ្លែងជំទាស់ថា គាត់បានចុះចូលនិងចូលរួម រួបរួមក្នុងសង្គមកម្ពុជាដោយសន្តិភាពរួចមកហើយ បើនរណាមួយប្រាថ្នាធ្វើឃាតខ្ញុំ គេអាចធ្វើបាន។

ទោះយ៉ាងណាក្តីចំណុចដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានលើកឡើងថា ពីព្រោះទម្ងន់នៃបទឧក្រិដ្ឋនិងបទឧក្រិដ្ឋដែល នួន ជា បានត្រូវចោទតម្រូវឲ្យមានការឃុំខ្លួនបណ្តោះអាសន្នជំហរនេះមិនអាចអនុវត្តបានតាមគតិយុត្តិ និងជាអង្គហេតុមិនសុចរិត។ ដោយមកពីផ្អែកតែទៅទម្ងន់នៃបទឧក្រិដ្ឋដែលបានចោទដើម្បីធ្វើយុត្តិកម្ម មូលហេតុទាំងនោះហើយការិយាល័យសហចៅក្រមស៊ើបអង្កេតបានបំពានលើការអនុវត្តដែលបានហាមឃាត់ ដូចដែលបានលើកឡើងពីខាងលើ។

[១៥:០៦:១៦]

ទាក់ទិននឹងចំណុចនេះ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នទំនងជាបានចេញដោយរំពឹងទុកជាមុនឲ្យមានការឃុំខ្លួនដ៏វែងមួយ ហើយយល់ថាការិយាល័យសហៅក្រមស៊ើបអង្កេតទំនងជាបានសេចក្តីវិនិច្ឆ័យជាមុនលើបញ្ហាពិរុទ្ធភាពរបស់លោក នួន ជា។ ផ្អែកតាមគោលការណ៍ទទួលស្គាល់អន្តរជាតិការឃុំខ្លួនបណ្តោះអាសន្នផ្អែកលើការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ និងអាចមានយុត្តិកម្មបានល្គឹកណាតែមានការបង្ហាញនូវអង្គហេតុជាក់លាក់នៃការរំខានណាមួយ និងល្គឹកណាតែការឃុំខ្លួន។ ដូចដែលបានរៀបរាប់រួចមកហើយ នួន ជា បាននឹងកំពុងរស់នៅជាមួយ-- រស់នៅជាចំហ និងសុខសាន្តនៅប៉ៃលិនអស់រយៈពេលច្រើនឆ្នាំមកហើយ ដែលជារយៈពេលគ្មានអំពើហិង្សាប្រឆាំងនឹងសេរីភាពរបស់គាត់ ឬអំពើប៉ុនប៉ងសងសឹកគាត់ណាឡើយ។

[១៥:០៧:២៤]

ជាក់ស្តែងមានមុខសញ្ញារបស់អ.វ.ត.ក ដែលគេដឹងឮគ្រប់គ្នាថាកំពុងរស់នៅក្នុងប្រទេសកម្ពុជានោះ ទំនងជាមិនបានធ្វើអ្វីឲ្យរំខានសណ្តាប់ធ្នាប់សាធារណៈទេ។ ទឡ្ហីករណ៍ដែលបានលើកឡើងថាសង្គមកម្ពុជានឹងពិបាកយល់និងឆ្លើយតបដោយត្រឹមត្រូវចំពោះគំនិតអំពីការដោះលែង នួន ជា បណ្តោះអាសន្នជាទឡ្ហីករណ៍មិនត្រឹមត្រូវ និងគំនិតនេះមិនត្រូវបានយកទុក-- យកចិត្តទុកដាក់អស់ពេលជាង១០ឆ្នាំនៃប្រវត្តិសាស្ត្រកម្ពុជារួចមកហើយដែរ។

ដូចដែល នួន ជា បានថ្លែងក្នុងសវនាការស្ដីអំពីការឃុំខ្លួនបណ្ដោះអាសន្នថា "ខ្ញុំបានចេញពីក្នុងព្រៃ ខ្ញុំបានយល់ពីបន្ទាត់នយោបាយនៃរដ្ឋាភិបាលដឹកនាំដោយនាយករដ្ឋមន្ត្រីសម្ដេចនាយក ហ៊ុន សែន ជាពិសេសនយោបាយរួបរួមក្នុងសង្គមជាតិឡើងវិញ"។

[១៥:០៨:២៥]

ជាការពិតណាស់ ការអត្ថាធិប្បាយនេះសំដៅលើគោលនយោបាយដ៏ប្រជាប្រិយរបស់រដ្ឋាភិបាលដែលចាប់ផ្ដើមនៅដើមឆ្នាំ១៩៩៤ និងដែលបានបញ្ចូលអតីតសមាជិកខ្មែរក្រហមមករស់នៅក្នុងសង្គមជាតិវិញ។ នួន ជា បានចាប់ផ្ដើមចុះចូលនិងរួមរស់ជាមួយសង្គមជាតិវិញជាផ្លូវការ តាមសំណើសុំជាផ្លូវការទៅសម្ដេចនាយក ហ៊ុន សែន នៅខែធ្នូ ឆ្នាំ១៩៩៨ និងរួមទាំងលោក ខៀវ សំផន ផងត្រូវបានស្វាគមន៍ឲ្យចូលមករស់ក្នុងសង្គមវិញដោយនាយករដ្ឋមន្ត្រី។

យោបល់បន្ថែមទៀតដែលឲ្យឃុំខ្លួន នួន ជា បណ្ដោះអាសន្ន និងទប់ស្កាប់រាល់ការតវ៉ាអំពីការឈឺចាប់ ការចោទជាបញ្ហាដែរ។ ការសម្ដែងមតិជាសាធារណៈនៃការមិនសុខចិត្តចំពោះអំពើរបស់មន្ត្រីត្រូវតែលើកទឹកចិត្តឲ្យធ្វើក្នុងសង្គមចំហ។ បើការសម្ដែងមតិនោះ គ្មានបង្ហាញអំពីហិង្សាពាក់ព័ន្ធជាមួយនឹងការយកចិត្តទុកដាក់របស់អ.វ.ត.ក អំពីការបញ្ចូលសារទៅសាធារណជន នេះជាករណីមួយត្រូវគោរពតាមគោលការណ៍គតិយុត្តិដែលបាន-- ដែលមានស្រេច ហើយមិនត្រូវផ្អែកលើការប៉ាន់ស្មានមិនត្រឹមមិនត្រូវលើស្ថានភាពសន្តិសុខ ដែលលាបពណ៌ប្រជាពលរដ្ឋថា ជាហ្វូងមនុស្សឥតសណ្ដាប់ធ្នាប់ និងធ្វើអ្វីៗតាមអារម្មណ៍។

[១៥:១០:០៦]

បើនិយាយអំពី--

[១៥:១០:២៧]

ហេតុដូច្នេះ ខ្ញុំបាទក្នុងនាមជាមេធាវីការពារជនជាប់ចោទ នួន ជា ទឡ្ហីករណ៍ទាំងប៉ុន្មានដែល ខ្ញុំលើកមកជម្រាបអង្គសវនាការ សូមអង្គសវនាការមេត្តាពិចារណា ហើយសុំ-- បើយល់ឃើញថាការដោះស្រាយ និងការលើកឡើងទាំងប៉ុន្មានសមហេតុសមផលចំពោះកូនក្ដីរបស់ខ្ញុំ សូមតុលាការលើកទោស អ្ហឺ! មិនមែនលើកទោសទេ ដោះលែងកូនក្ដីខ្ញុំឲ្យនៅក្រៅឃុំតាមដែលខ្ញុំបានស្នើ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីការពារក្ដីឲ្យលោក នួន ជា--

[១៥:១១:២១]

**លោក សុន អរុណ៖**

សូមទោស, ខ្ញុំសូមជូនពាក់កណ្តាលទៀត លើការចោទប្រកាន់ពីរឿងវិធាន៨២ ហ្នឹងទៅខាងសហមេធាវីខ្ញុំបាទ បើសិនមានពេលអនុញ្ញាតទាន។

[១៥:១១:៣៦]

**ប្រធានអង្គជំនុំ៖**

ដូចជាលោកស៊ីម៉ោងអស់អំមិញជាង២០មីនុតហើយ ម្នាក់ឯង ហើយអង្គជម្រះកំណត់ឲ្យតែ១០មីនុតទេ។

[១៥:១១:៤៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១២:១៥]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះអង្គជំនុំជម្រះអនុញ្ញាតជូនលោកមេធាវី ប៉ៅ ដើម្បីធ្វើសេចក្តីតបទៅនឹងអ្វីដែលខុសគ្នារវាងសេចក្តីសន្និដ្ឋានរបស់លោកពីដើម ជាមួយនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា។ អ៊ីចឹងគឺអង្គជំនុំជម្រះកម្រិតពេលវេលាខ្លីបំផុតត្រឹមតែ៥មីនុតទេ មិនអនុញ្ញាតដល់២០មីនុតដូចមេធាវីការពារក្តីជាតិទេ។ បើពុំដូច្នោះទេ គឺនឹងរំលោភយ៉ាងច្រើនទៅលើវិធានកំណត់ពេលវេលារបស់អង្គជំនុំជម្រះ។

សូមអញ្ជើញ!

[១៥:១២:៥៥]

**លោក ហ្សាស្ទ័រ ប៉ៅ៖**

សូមអរគុណលោកប្រធាន ដែលផ្តល់ឱកាសជូនខ្ញុំ។ ជាការពិតលោក សុន អរុណ និយាយយ៉ាងច្រើនអំពីមូលដ្ឋានទាំងអស់នោះ ប៉ុន្តែខ្ញុំនឹងកម្រិតការលើកឡើងរបស់ខ្ញុំឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានតបមួយចំនួនដែលលើកឡើងពីខាងសហព្រះរាជអាជ្ញា។ ជាពិសេសទាក់ទងទៅនឹងអង្គសេចក្តី និងគោលការណ៍ដំណោះស្រាយខ្ពស់បំផុត។ ខ្ញុំនឹងនិយាយដោយសង្ខេប ដោយខ្ញុំយល់ថាពេលវេលាខ្លី។ ហើយយ៉ាងណាក៏ដោយ ខ្ញុំដឹងថាខ្ញុំនិយាយលឿនណាស់ចំពោះអ្នកបកប្រែ ខ្ញុំនឹងព្យាយាមនិយាយឲ្យបានយឺតទៅលើយោបល់របស់ខ្ញុំ។

[១៥:១៣:២៧]

ចំណុចទីមួយ សហព្រះរាជអាជ្ញាបានលើកឡើងថា ពាក្យសុំរបស់យើងមិនអាចទទួលយកបាន ដោយសារតែវាជាការប្តឹងឧទ្ធរណ៍ទៅលើសាលដីការបស់អង្គបុរេជំនុំជម្រះ។ និយាយដោយត្រង់ទៅ យើងមិនមែនប្តឹងឧទ្ធរណ៍ទៅលើសាលដីកា ឬសេចក្តីសម្រេចណាមួយនោះទេ។ យើងខ្ញុំគ្រាន់តែស្នើសុំ ដោះលែងលោក នួន ជា ដោយហេតុថា មិនមានមូលដ្ឋានផ្លូវច្បាប់ឃុំខ្លួនគាត់។ ពាក្យសុំរបស់យើងនេះ មិនមែនរារាំងដោយវិធាន៧៧ អនុវិធាន១៣ នោះទេ គឺខ្ញុំគោរពតាម ធ្វើឡើងដោយអនុលោមតាមវិធាន ៨២(៣)។ ប៉ុន្តែយ៉ាងណាក៏ដោយ នៅក្នុងពាក្យសុំរបស់យើង យើងទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងទទួលសំណុំរឿងរួចហើយ ដូច្នេះហើយវាមិនមែនរារាំងយើងក្នុងការតវ៉ាសេចក្តីសម្រេច ឬសាលដីការបស់អង្គបុរេជំនុំជម្រះថាជាសេចក្តីសម្រេចមិនត្រឹមត្រូវនោះទេ។

[១៥:១៤:២៣]

ខ្ញុំសូមលើកឡើងមូលហេតុមូលដ្ឋានផ្លូវច្បាប់ ចំណុចទីមួយ ប្រសិនបើយើងមិនប្តឹងលើកឡើង នៅទីនេះ ឲ្យយើងលើកឡើងនៅទីណា? យើងដឹងហើយ អង្គបុរេជំនុំជម្រះលើកឡើងពាក្យសុំយើងមិន អាចទទួលយកបាន។ នេះគឺតាមរយៈសំណើសុំរបស់យើង ធ្វើឡើងលើការដោះលែងឲ្យមានសេរីភាព។ នៅពេលនោះអង្គបុរេជំនុំជម្រះ បានរុញសេចក្តីសម្រេចនេះទៅអង្គជំនុំជម្រះសាលាដំបូង។ យើងបាន លើកឡើងសំណើនេះជូនអង្គបុរេជំនុំជម្រះប៉ុន្តែមិនបានសម្រេច ហើយបែរជាបង្វិលឲ្យអង្គជំនុំជម្រះ សាលាដំបូង។

[១៥:១៥:០៧]

ការពន្យារពេលឃុំខ្លួននោះគឺ ប្រសិនបើមិនធ្វើការផ្តល់សំអាងហេតុយើងឲ្យបានគ្រប់គ្រាន់ទេ គឺ ការឃុំខ្លួននោះ យើងមិនអាចយល់បាននោះទេ។ យើងដឹងហើយថា អង្គជំនុំជម្រះសាលាដំបូងទទួល បានសំណុំរឿង។ យើងមិនដែលតវ៉ាថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនោះមានមោឃភាពផ្លូវ ច្បាប់នោះទេ ប៉ុន្តែគ្រាន់តែមិនមានសំអាងហេតុចំពោះការឃុំខ្លួនលោក នួន ជា។ យើងយល់ស្របថា សាលដីការបស់អង្គបុរេជំនុំជម្រះ គឺជាសាលដីកា បន្ទាប់មកនឹងបញ្ជូនសំណុំរឿងទៅកាន់សាលាដំបូង។ យើងទទួលស្គាល់ថាមានការបញ្ជូនសំណុំរឿង។

[១៥:១៥:៥៦]

សហព្រះរាជអាជ្ញាយើងលើកឡើងថា យើងមិនបានលើកទឡ្ហីករណ៍ចំពោះការបន្តឃុំខ្លួននៅពេល

ដែលចេញដីកាដំណោះស្រាយ។ សហព្រះរាជអាជ្ញាបានលើកឡើងថា នួន ជា គាត់ដឹងសំណុំរឿងនៅពេលនេះ និងហេតុផលដែលការឃុំខ្លួន។ ចំណុចនេះ សហព្រះរាជអាជ្ញាមិនបានមើលអង្គសេចក្ដីរបស់យើង ឬក៏មើលរំលងការលើកឡើងរបស់យើង។ ជាការពិត សាលដីកាលើការឃុំខ្លួននោះ គឺមិនមានសំអាងហេតុ។ ហើយយើងមិនមែនលើកតែចំណុចនេះទេ ដូចដែលមានបង្ហាញនៅក្នុងកថាខណ្ឌរបស់ពាក្យសុំរបស់យើង។

ចំណុចដែលលើកឡើងនៅក្នុងពាក្យសុំរបស់យើង មានចំណុចដទៃៗទៀតដែលវាពាក់ព័ន្ធទៅនឹងសាលដីការបស់អង្គបុរេជំនុំជម្រះមិនមានសំអាងហេតុ។ ហើយនេះ នៅថ្ងៃនេះហើយដែលយើងតវ៉ាទៅលើបញ្ហានេះ ហើយវាជាការប៉ះពាល់ទៅដល់ជនជាប់ចោទ។ ដូចដែលសហព្រះរាជអាជ្ញាបានបញ្ជាក់ គឺគាត់មិនបានយកចិត្តទុកដាក់ទៅលើទឡ្ហីករណ៍ និងការប៉ះពាល់ទៅដល់ជនជាប់ចោទ។ ហើយយើងមិនអាចលើកឡើងអញ្ញត្រកម្មបានទេ ប្រសិនបើសេចក្ដីសម្រេច ឬសាលដីកាមិនមានសំអាងហេតុនេះនោះ។

[១៥:១៧:១៥]

យើងមិនមែន-- ចំពោះអង្គហេតុដែលថា-- យើងមិនតវ៉ាទៅលើសាលដីកាមិនមានសំអាងហេតុកាលពីលើកៗមុននោះ គឺយើងមិនបានបញ្ជាក់នៅក្នុងសេចក្ដីសន្និដ្ឋានរបស់យើងនោះទេ។ ចំពោះគោលការណ៍ដំណោះស្រាយខ្ពស់បំផុត សហព្រះរាជអាជ្ញាបានលើកឡើងថា វាមានលក្ខណៈផ្ទុយខុសពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ ខ្ញុំមិនបានលើកឡើងទៅលើចំណុចនេះទេ ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា ក្រុមមេធាវីការពារក្ដីយើងគិតថា វាមិនមែនជាគោលការណ៍របស់ប្រទេសបារាំងនោះទេ វាក៏ជាគោលការណ៍អនុវត្តនៅក្នុងប្រទេសកម្ពុជាផងដែរ។

[១៥:១៧:៥៨]

យើងកំពុងតែអនុវត្តតាមច្បាប់កម្ពុជា មាត្រា២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺចែងកំណត់រយៈពេលឃុំខ្លួនបួនខែក្នុងអំឡុងពេលនេះ។ ហើយបើសិនជាមិនដូច្នោះ ត្រូវដោះលែងជនជាប់ចោទ។ កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ក៏ចែងអំពីគោលការណ៍ដំណោះស្រាយខ្ពស់បំផុតនេះផងដែរ។ ដូច្នេះហើយវា-- ទាំងអស់នេះហើយដែលជាមូលដ្ឋានលើកឡើងនៅក្នុងទឡ្ហីករណ៍របស់យើងអនុលោមតាមវិធាន៦៣(៣) ដែលវិធាន៦៣(៣) គឺចែងថា “ជនជាប់ចោទត្រូវតែដោះលែងឲ្យមានសេរីភាពប្រសិនបើមិនមានសេចក្ដីសម្រេច ឬសាលដីកា”។

[១៥:១៨:៣៧]

ដូច្នេះខ្ញុំយល់ឃើញថា អ្វីដែលខ្ញុំលើកឡើងនិងការដកស្រង់ទៅលើឯកសាររបស់សហព្រះអាជ្ញាតាមE15/1 នោះទាក់ទងសំណើសុំដោះលែងនិងការពន្យារពេល។ល។ នោះ នៅក្នុងកថាខណ្ឌ៣ នៃឯកសារE15/1 សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ជនជាប់ចោទមិនគួរដោះលែងនោះទេ។ វិធាន អ.វ.ត.ក បញ្ជាក់អំពីផលប្រយោជន៍នៃការសន្សំធនធានរបស់តុលាការ។ ដូច្នេះហើយចំណុចនេះប្រសិនបើសហព្រះរាជអាជ្ញាគិតដូច្នោះនោះ សហព្រះរាជអាជ្ញា គឺមិនត្រូវបានអនុញ្ញាតធ្វើការតវ៉ាទៅលើវិធានមួយចំនួន ហើយចៅក្រមក៏មិនអាចធ្វើការតវ៉ាទៅលើវិធានមួយចំនួននោះផងដែរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ប៉ៅ។ ជាបន្ត គឺអញ្ជើញដល់-- អញ្ជើញមេធាវី ស សូវាន មេធាវីការពារក្តីឲ្យលោក ខៀវ សំផន។

សូមអញ្ជើញបាទ លោកមេធាវី!

[១៥:១៩:៥១]

**លោក ស សូវាន៖**

សូមគោរពលោកប្រធានដែលបានអនុញ្ញាតឲ្យខ្ញុំមានយោបល់ឆ្លើយតបនឹងព្រះរាជអាជ្ញាជាតិ។ សូមគោរពចៅក្រម និងសូមគោរពអង្គសវនាការទាំងមូល។ ខ្ញុំមិនយកពេលវេលាច្រើនទេ ទុកឲ្យនេះទៅពីព្រោះយើងចូលដល់ដំណាក់កាលមួយជជែកគ្នាអំពីការបកស្រាយច្បាប់។ ខ្ញុំសូមគោរពសហព្រះរាជអាជ្ញាជាតិ បើខ្ញុំខុសសូមមេត្តាអភ័យទោស ប៉ុន្តែខ្ញុំក៏មិនថាសហព្រះរាជអាជ្ញាជាតិគាត់ខុសដែរ ពីព្រោះការបកស្រាយច្បាប់ដែលដាក់ពន្ធនាគារកូនក្តីខ្ញុំនេះ គឺជាច្បាប់ កូនក្តីខ្ញុំងើបអម្បាញ់មិញនេះ ថាសូមឲ្យតែគោរពច្បាប់ ដល់តែច្បាប់ហ្នឹង វាការបកស្រាយខុសគ្នា។

[១៥:២០:៤១]

ឥឡូវខ្ញុំសូមឆ្លើយអ៊ីចេះយ៉ាងខ្លី។ មុននឹងឆ្លើយនឹងគំនិត គេហៅថាគ្រឹះជម្រៅនោះ វាមានទម្រង់សហភាតាខាងអ្នកការពារលោក នួន ជា គាត់បានជម្រាបអំពីទម្រង់នៃការសុំរបស់កូនក្តីខ្ញុំទៅអង្គជំនុំជម្រះសាលាដំបូងនេះ។ ខ្ញុំមិនចាត់ទុកសាលាដំបូងនេះ ជាឧទ្ធរណ៍ សាលាឧទ្ធរណ៍សម្រាប់ពិនិត្យការខ្ញុំមិនសប្បាយចិត្ត និងសាលដីការបស់អង្គបុរេជំនុំជម្រះ បញ្ជូនកូនក្តីមកឲ្យកាត់ហើយ ដាក់ជាប់ពន្ធនាគារទៀត។

[០៩:២១:២០]

ខ្ញុំអត់អីចឹងទេ ខ្ញុំសូមថាអីចេះ ថាក្នុងការបញ្ជូនកូនក្ដីខ្ញុំពីព្រឹកមិញ ខ្ញុំបានជម្រាបហើយ នៅក្នុងដីការបស់អង្គបុរេជំនុំជម្រះមិនបានជូនសំអាងហេតុនៅក្នុងសាលដីកានោះទេ នៅក្នុងសាលដីកា ក៏ប៉ុន្តែមិនគិតអីចឹងទេ ខ្ញុំគិតថាការឃុំបួនខែបន្តនេះ ពីព្រោះបីឆ្នាំ ថែមបួនខែទៀត នៅក្នុងបួនខែនេះយើងមានវិធាន-- ខ្ញុំមិនទាន់និយាយទេ វាមានវិធាន យើងនិយាយមកហើយថា គឺថាបួនខែហ្នឹងមានលក្ខណៈពិសេស គឺថាគេដាក់ឲ្យនៅក្នុងពន្ធនាគារ វាទាល់មានលក្ខណៈពិសេសស ហើយខ្ញុំសម្ដែងរាល់ថ្ងៃនេះពេលនេះ ខ្ញុំសូមឲ្យបណ្ដោះអាសន្ន។ ប៉ុន្តែតាមធម្មតា មេធាវីគេមិនសូវថាលែងបណ្ដោះអាសន្នទេ ប៉ុន្តែមហាជនត្រូវដឹងថា កូនក្ដីខ្ញុំ ឥឡូវនេះមិនមែនជាជនសង្ស័យទេ ជនជាប់ពិរុទ្ធ គេកំពុងតែចោទ។ ចាប់តាំងអំពីដីកាដំណោះស្រាយបញ្ជូនកូនក្ដីខ្ញុំមកនៅតុលាការនេះ កូនក្ដីខ្ញុំជាជនជាប់ពិរុទ្ធ ប៉ុន្តែយើងជជែកគ្នាទៅទៀត ដើម្បីរកថាតើគាត់ជាប់មែន ឬមិនមែន? បានមាន នែ៎! សាលក្រមរបស់តុលាការនេះដាក់ទណ្ឌកម្មគាត់។

[១៥:២២:៤២]

ដូច្នេះយើងមានពេលវែងណាស់ ខ្ញុំសូមទទូចម្ដងទៀតថា វាមានវិធានការដាក់គាត់បួនខែ ឬមួយក៏អីចឹងទេឲ្យគាត់នៅក្រៅឃុំ ប៉ុន្តែនៅក្រោមការពិនិត្យតុលាការ ទៅណាមកណា ដើរហោះហើរទៅណាត្រូវចូលមកប្រាប់អាជ្ញាធរ ថាលោក ខៀវ សំផន ទៅផ្សារទៅណា វាមានវិធានការ មិនមែនចាំតែដាក់គុកហ្នឹងទេ។ ប៉ុន្តែសុំអីចេះ! សហព្រះរាជអាជ្ញាជាតិមេត្តាអភ័យទោស ខ្ញុំមិនមែនចោទប្រកាន់ថា មានគំនុំគុំកួននឹងកូនក្ដីខ្ញុំទេ ពីព្រោះយើងនិយាយតែពីច្បាប់។ ដូច្នេះមិនបាច់ចាំដាក់គុកគាត់បួនខែទៅទៀតទេ ស្អែកហ្នឹងបើថាមិនលែងទេ ក៏ដាក់ឲ្យគាត់នៅក្រៅឃុំទៅ គាត់មកសហការដើម្បីរកការពិត។ ដូច្នេះយើងមានជជែកគ្នាទៀត។

[១៥:២៣:២៨]

ខ្ញុំសូមឆ្លើយសហព្រះរាជអាជ្ញាជាតិអម្បាញ់មិញថា ឥឡូវនេះពិភពលោកស្គាល់សម្បើមណាស់ នែ៎លោកប្រធាន អតីតប្រធានរដ្ឋលោក ខៀវ សំផន។ ខ្ញុំសប្បាយចិត្តណាស់ គេស្គាល់អស់ហើយ ពីព្រោះលោកប្រធានរដ្ឋគាត់មិនមែនក្រុមអ្នកប្លន់រទេះភ្លើងទេ គឺថាគាត់ធ្វើដើម្បីជាតិ ខ្ញុំប៊ាននិយាយអីចឹង ខ្ញុំមានជំនឿអីចឹង។ ហើយដូច្នេះ ខ្ញុំថាមានវិធានការ យើងអាចលែងគាត់ គាត់អត់រត់ទេ។ ខ្ញុំថាមិនបាច់និយាយតទៅទេ ពីព្រោះអង្គបុរេជំនុំជម្រះបានទទួលស្គាល់ថា មានប្រាំខ បីខ គាត់មិនរត់

គាត់មិនបំភិតបំភ័យ គាត់មិនគំហែងគំរាម នៅសល់តែពីរករណីទេ គឺថាបើគេលែងគាត់ ខ្លាចគេវ៉ៃគាត់ ខ្ញុំសរសើរ អរគុណទៅទៀត ហើយខ្លាចគាត់បង្កើតសណ្តាប់ធ្នាប់។

[១៥:២៤:១៩]

ឥឡូវនេះ ខ្ញុំវិលមកឆ្លើយនឹងសហព្រះរាជអាជ្ញាជាតិថា លោកជំទាវមានប្រសាសន៍ថា យោងទៅតាមមាត្រា៦៨(៣) ការបកស្រាយអំពីកំណត់រយៈពេលបួនខែ។ តាមទស្សនៈរបស់ពួកខ្ញុំពីព្រឹកមិញនេះ ខ្ញុំនិយាយថា ការពន្យារពេលដាក់គាត់ឃុំឃាំងបួនខែ ថែមនឹងបីឆ្នាំ វា គេចាប់រាប់ចាប់តាំងពីថ្ងៃ១៦ ខែកញ្ញា ឆ្នាំ២០១០ រហូតដល់ថ្ងៃ១៦-១-២០១១ វាបួនខែហើយ។ នៅក្នុងរយៈពេលបួនខែនេះ បើតុលាការ អង្គបុរេជំនុំជម្រះក្តី សាលាដំបូងក្តី មិនកោះហៅកូនក្តីខ្ញុំបង្ហាញទេ ត្រូវតែលែងជាស្វ័យប្រវត្តិ លែងហ្នឹង លែងឃុំបណ្តោះអាសន្ន បើមិនសប្បាយចិត្តទេ លែងបណ្តោះអាសន្ន រួចថាថែមអីឲ្យនៅក្រោមតុលាការទៀត ឲ្យគាត់មានសេរីភាព គាត់នឹងមកជួយសហការ។ ក៏ប៉ុន្តែខ្ញុំស្តាប់អម្បាញ់មិញទៅសហព្រះរាជអាជ្ញាជាតិ គាត់ថាបួនខែ ចាប់រាប់តាំងពីថ្ងៃសាលដីការបស់អង្គបុរេជំនុំជម្រះថ្ងៃ១៣ ខែ១ ២០១១។

[១៥:២៥:៣៤]

បើខ្ញុំពិចារណាទៅឃើញថា សហព្រះរាជអាជ្ញាជាតិ គាត់ដូរការបកស្រាយ ព្រោះកាលគាត់បកស្រាយ តាមរយៈគាត់ឆ្លើយតប ទៅនឹងលោក នួន ជា ថ្ងៃ១៣ ខែកញ្ញា ២០១១ គាត់មានការបកស្រាយដូចខ្ញុំជម្រាបអ៊ីចឹង ថាជាប់ដំណើររាប់តាំងពីថ្ងៃ១៦-៩ រហូតដល់ថ្ងៃ១៦-១ ដល់ឥឡូវនេះគាត់មកដូរថា ចាប់រាប់ពីថ្ងៃ១៣-១ វិញ។

[១៥:២៦:០៥]

ខ្ញុំសូមអ៊ីចេះថា ខ្ញុំមានជំនឿថា លោកជំទាវ ក៏មិនទៅស្អប់ អាក្រក់អីនឹងកូនក្តីខ្ញុំ បើមានស្អីទៀតខ្ញុំមិនដឹងទេ ក៏ប៉ុន្តែខ្ញុំសូមថា ខ្ញុំមានភ័ស្តុតាងដែលគាត់បកស្រាយ មានទៅឌុកគុយម៉ង់ (និយាយភាសាបារាំង) ទៅទៀត នៃបកស្រាយគាត់ឆ្លើយទៅលោក នួន ជា ដោយបកស្រាយតាមដំណើរចាប់រាប់ពីថ្ងៃ១៦ ខែកញ្ញា ២០១០ រហូតដល់ថ្ងៃ១៦-១ នោះ វាបួនខែ។

[១៥:២៦:៣៥]

ឥឡូវនេះ ខ្ញុំចូលមកចំណុចទីពីរ ចំណុចទីពីរនេះ ខ្ញុំមិនមែនថា ខ្ញុំវាអ្នកពូកែខាងបកស្រាយទេ។ លោក-- ខ្ញុំសូមឆ្លើយត្រង់ណោះ យើងវាស្រួលត្រង់ថា ថ្ងៃនេះ យើងជជែកគ្នាតែពីរឿងបកស្រាយច្បាប់

កូនក្តីខ្ញុំក៏គាត់ជម្រាបដែរថាគាត់សុំតែគោរពច្បាប់។ ដូច្នេះបើយើងមានមន្ទិលសង្ស័យអំពីការបកស្រាយអំមិញនេះ វិធាន៦៨(៣) នេះ ខ្ញុំសូមអានអំពីបទបញ្ញាផ្ទៃក្នុងយើងនេះ មាត្រា២១ ជាភាសាបារាំងប៉ុនខ្ញុំបកប្រែទៅ គេថា "ច្បាប់បង្កើតតុលាការខ្មែរក្រហម បទបញ្ញាផ្ទៃក្នុង សេចក្តីណែនាំ និងបញ្ញត្តិទាំងអស់ ត្រូវតែបកស្រាយ ដើម្បីការពារផលប្រយោជន៍ជនសង្ស័យ ឬមួយក៏ជនត្រូវចោទប្រកាន់ ឬមួយក៏ជនដែលគេចោទ ពីព្រោះកូនក្តីខ្ញុំហ្នឹងចូលដល់ជនគេចោទហើយ និងអ្នករងគ្រោះ ដើម្បីធានាសុវត្ថិភាព គតិយុត្តិ សុវត្ថិភាពច្បាប់ និងដើម្បីធានាឲ្យមានតុលាភាព របៀបក្តី"។

[១៥:២៧:៥២]

ដូច្នេះ ខ្ញុំសូមថា បើយើងមានមន្ទិលសង្ស័យនឹងការបកស្រាយ សូមមេត្តាយកមាត្រា២១ហ្នឹងបកស្រាយយ៉ាងម៉េច កុំឲ្យកូនក្តីខ្ញុំរងអយុត្តិធម៌ ហើយកុំឲ្យតុលាការនេះកុំឲ្យមានលក្ខណៈជាកន្លែងគុំកួន គឺស្វែងរកការពិត មិនមែនអត់មធ្យោបាយទេ ដាក់គាត់នៅក្រៅឃុំ គាត់យកមកថ្ងៃណា គង់តែបានទេ។ ហើយដល់បន្តិចទៀតទៅបីខែទៀត ដាក់គុកគាត់ ដាក់ទៅឲ្យតែរកគាត់ឃើញ។ យើងឆ្លើយទៅ រួចបរទេសស្គាល់ ខ្ញុំស្គាល់បរទេស។ រាល់ថ្ងៃនេះ ខ្ញុំហៅ ពីព្រោះសហព្រះរាជអាជ្ញាលោកចោទថា សារណាលោក ខៀវ សំផន ដែលជាប់បណ្ឌិតសេដ្ឋកិច្ច គឺមានគំនិតអាក្រក់ ខ្ញុំរកអ្នក ដែលគេហៅអ្នកជំនាញឲ្យមើល អាដែងសារណាគាត់ ដែលជាប់ *ឌុកទ័រអេសស្យង់អេកូនូមីក* (និយាយភាសាបារាំង) សូមអភ័យទោស និយាយបារាំងទៀតហើយ ខ្ញុំសូមទោស ន៎ែ!ជាប់បណ្ឌិតសេដ្ឋកិច្ចឲ្យគេអ្នកក្រៅ មើលអ្នកប្រាជ្ញ តើគាត់មានគំនិតហ្នឹងទេ? គ្មានគំនិតហ្នឹងទេ ប៉ុន្តែធ្វើម៉េច ធ្វើនយោបាយមិនមែនធ្វើម្នាក់ឯងទេ។

[១៥:២៨:៥៨]

ហើយដូច្នេះ ខ្ញុំចូលមកសង្កត់ សូមមេត្តាសង្កត់ ខ្ញុំចប់ហើយ។ មកចូលមកដល់ការបកស្រាយវិធាន៦៣(៣) ដែលយើងនិយាយថា វិធាន៦៣(៣)នេះ គឺថាជាអំណាចរបស់ចៅក្រមស៊ើបសួរដាក់គាត់ បើសិនជាមានការចាំបាច់ដាក់ឲ្យនៅឃុំ។ នៅក្នុងមាត្រា៦៣(៣)នេះ គេមានចែងប្រាំខ បីខដូចខ្ញុំបានជម្រាបពីព្រឹកមិញ អង្គជំនុំជម្រះ។ នៅសល់តែពីរខទៀតទេ បីខហ្នឹង អង្គបុរេជំនុំជម្រះគេទទួលស្គាល់ នៅសល់ពីរ។ នៅសល់ពីរនេះ មិនមែនខ្ញុំនេះ កូនក្តីខ្ញុំអ្នកបង្ហាញន៎ែ លោកសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិទេ ត្រូវលោកព្រះរាជអាជ្ញាបង្ហាញភ័ស្តុតាងថ្មីថា ឥឡូវហ្នឹងដូចជាចាក់ថាសចាស់អីចឹងនៅតែដដែលហ្នឹង។ ប៉ុន្តែតើគាត់មានលក្ខណៈអ្វី បំបាត់ ឬមួយជាប់ពិរុទ្ធអី? ខ្ញុំមិនចង់និយាយដូចនេះ

ទេ។ នៅតែពីរលក្ខណៈហ្នឹងទេ ខ្ញុំទទូចសុំថា គ្មានប្រយោជន៍អីទេ បើតុលាការនេះគ្មានការគុំក្ហួន យើងនៅសវនាការ ខ្ញុំក៏មានសាក្សីខ្ញុំដែរ មិនមែនអត់ទេ អន្តរជាតិ និងជាតិ ទូតទៅទៀត ហ្នឹងហើយមកធ្វើហ្នឹង ថាតើកូនក្តីខ្ញុំយ៉ាងម៉េច? យើងមានពេលនិយាយគ្នាទៀត។

[១៥:៣០:៣១]

ឥឡូវនេះ យ៉ាងហោចណាស់ ដើម្បីសង្ខេប សូមមេត្តាអភ័យទោស។ បើថាធ្ងន់ធ្ងរទៅ លែងគាត់ទៅ ខ្លាចគេខឹង យ៉ាងហោចណាស់ដាក់គាត់នៅក្រៅការឃុំឃាំង ឲ្យនៅក្រោមការត្រួតពិនិត្យតុលាការមាន វិធានការគេមានចែងតើ ប៉ុន្តែបើយើងមិនដាក់ទេមានសេចក្តីថាយើងគុំក្ហួន យើងមានការគុំក្ហួន។ សូមអភ័យទោស សូមអរគុណលោកប្រធានសូមចប់ត្រឹមហ្នឹង។

[១៥:៣០:៤៨]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ស សូវាន។ ហើយជាបន្តនេះ លោក ខៀវ សំផន តើលោកមានអ្វីចង់ធ្វើសេចក្តីសន្និដ្ឋានបន្ថែមតបទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាដែរឬទេ? បន្ថែមលើអ្វីដែលបានបង្ហាញឡើងដោយមេធាវីរបស់លោក។

**លោក ខៀវ សំផន៖**

បាទ, អរគុណ ខ្ញុំបាទមិនមានអីបន្ថែមទៀតទេ។

[១៥:៣១:២០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ តទៅនេះ សូមអញ្ជើញលោកមេធាវី ផាត់ ពៅស៊ាង ដែលជាមេធាវីការពារក្តីឲ្យលោកស្រី អៀង ធីរិទ្ធ ឡើងធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។ សូមអញ្ជើញ!

**លោក ផាត់ ពៅស៊ាង៖**

សូមអរគុណ ខ្ញុំបាទសូមគោរពនូវអង្គជំនុំជម្រះសាលាដំបូងម្តងទៀត ហើយនឹងសូមគោរពអង្គសវនាការទាំងមូល គឺចំពោះនាពេលនេះ គឺខ្ញុំបាទសូមអនុញ្ញាតឆ្លើយតបទៅនឹងហៅថា សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាជាតិ ដែលលោកលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង មិនមែនជាសាលាឧទ្ធរណ៍ទេ។ ខ្ញុំបាទឯកភាពទាំងស្រុង មិនមែនជាសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះនូវសេចក្តីសម្រេច

របស់អង្គបុរេជំនុំជម្រះទេ គឺខ្ញុំបាទសូមឯកភាពទាំងស្រុង។ ប៉ុន្តែពាក្យសុំរបស់ខាងក្រុមរបស់ខ្ញុំបាទហ្នឹង អត់មានបានដាក់បណ្តឹងឧទ្ធរណ៍ទេ ដាក់ថាសំណើសុំដោះលែងជាបន្ទាន់ មិនមែនជាពាក្យប្តឹងឧទ្ធរណ៍អត់មានទេ។ ដូច្នេះខ្ញុំបាទ សូមអនុញ្ញាតបញ្ជាក់ជូនច្បាស់លាស់ថា ខ្ញុំបាទអត់មានបានដាក់បណ្តឹងឧទ្ធរណ៍ឲ្យអង្គជំនុំជម្រះសាលាដំបូងដើម្បីពិចារណាទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនោះឡើយ។

[១៥:៣២:៤៨]

ចំណុចទីពីរ គឺថាខ្ញុំបាទសូមអនុញ្ញាតជម្រាបជូនថា ព្រឹកមិញខ្ញុំបាទបានលើកឡើងម្តងហើយ តែនាពេលនេះ ដើម្បីខ្ញុំបាទលើកម្តងទៀត ដើម្បីវាភ្ជាប់ទៅនឹងឃ្លាដែលត្រូវដោះស្រាយ។ គឺបានន័យថា កូនក្តីខ្ញុំបាទត្រូវបានឃុំខ្លួនតាំងពីថ្ងៃទី១៤ ខែ១១ ឆ្នាំ២០០៧ ហើយដោយផ្អែកតាមច្បាប់ គឺថាការឃុំខ្លួនហ្នឹងវាមានរយៈពេលបីឆ្នាំ។ បន្ទាប់មកគឺថាសហចៅក្រមស៊ើបអង្កេតបានបន្តឃុំខ្លួនកូនក្តីខ្ញុំបាទ តាមរយៈដីកាដំណោះស្រាយ ហើយដីកាដំណោះស្រាយហ្នឹង គឺថាបានបន្តឃុំខ្លួន។ ដូច្នេះ ក្រោយពីផុតនូវហៅថា ដីកាដំណោះស្រាយហ្នឹង ក៏មានហៅថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី១៣ ខែ១ ឆ្នាំ២០១១។

[១៥:៣៣:៣២]

ដូច្នេះ យើងលើកយកអំពីហៅថា សេចក្តីសម្រេចចុះថ្ងៃទី១៣ ខែ១ ឆ្នាំ២០១១ របស់អង្គបុរេជំនុំជម្រះមកពីពិចារណាមើលថា តើវាមានសុពលភាពអត់ ហើយយើងត្រូវអនុវត្តបានដែរអត់? គឺថាដោយផ្អែកទៅតាមហៅថា សេចក្តីសម្រេចចុះថ្ងៃទី១៣ ខែ១ ឆ្នាំ២០១១នោះ គឺថាសេចក្តីសម្រេចនេះ គ្មានៗអំពីហៅថា សំអាងហេតុទេ។ បើសេចក្តីសម្រេចមួយ ដែលគ្មានអំពីសំអាងហេតុអ៊ីចឹង យើងអាចយកមកពិចារណា-- យើងយកមកអនុវត្តបានដែរឬទេ?

[១៥:៣៤:០២]

ដូច្នេះបើសិនជានៅក្នុងករណីដែលហៅថា គ្មានសំអាងហេតុយ៉ាងដូច្នេះ គឺថាសេចក្តីសម្រេចហ្នឹង បើសិនជាមិនអាចទទួលបានទេ ការឃុំខ្លួនកូនក្តីខ្ញុំបាទហ្នឹង វាជាការខុសច្បាប់។ ដោយសារអីដោយសារដីកាដំណោះស្រាយហ្នឹងវាបានចប់ ហៅថារយៈពេលវារួចទៅហើយ។

[១៥:៣៤:២០]

ម្យ៉ាងវិញទៀត គឺថាលោកជំទាវសហព្រះរាជអាជ្ញាជាតិក៏បានលើកឡើងថា ការឃុំខ្លួនកូនក្តីខ្ញុំ

បាទ គឺហៅថា ការឃុំខ្លួនហ្នឹង មានសេវាពេទ្យអីត្រឹមត្រូវ អ៊ីចឹងទៅ បើប្រៀបធៀបទៅនឹងខាងក្រៅអ៊ីចឹងទៅ វាគ្រាន់បើជាងអី គឺខ្ញុំបាទបានពិនិត្យឃើញអ៊ីចឹងដែរ។ ក៏ប៉ុន្តែ កាលដែលហៅថា-- មនុស្សម្នាក់គាត់ត្រូវការសេរីភាពដែរ មិនមែនតែត្រូវការតែសេវាពេទ្យ ដើម្បីព្យាបាលអី ឬមួយក៏អីៗគឺថានៅក្នុងមន្ទីរឃុំឃាំងហ្នឹង គឺថាតុលាការបានដោះស្រាយបានត្រឹមត្រូវហើយ ប៉ុន្តែគាត់ក៏ត្រូវការសេរីភាពដើម្បីជួបកូន ជួបចៅ មូលកូន មូលចៅរបស់គាត់ដែរ។

[១៥:៣៥:០៥]

ដូច្នេះ ដោយផ្អែកទៅតាមមូលហេតុទាំងអស់នេះហើយ ខ្ញុំបាទនៅតែទទូចស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូង មេត្តាដោះលែងកូនក្តីខ្ញុំបាទ ដោយសារ-- ហើយថាច្បាប់បានកំណត់ថាការឃុំខ្លួនកូនក្តី គឺថាខ្ញុំបាទហ្នឹង គឺថារយៈពេលបីឆ្នាំ ឥឡូវហួសដល់រយៈពេលបីឆ្នាំ ពីរខែ ទៅហើយ។ ដោយមូលហេតុនេះហើយខ្ញុំបាទនៅតែទទូចស្នើសុំឲ្យដោះលែងកូនក្តីខ្ញុំបាទនៅក្រៅឃុំ។ សូមអរគុណ។

[០៣:៣៥:៣០]

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង ធីរិទ្ធ។

អង្គជំនុំជម្រះសាលាដំបូងសូមថ្លែងអំណរគុណដល់ភាគីទាំងអស់ដែលបានធ្វើសេចក្តីសន្និដ្ឋានថ្លែងការណ៍បញ្ជាក់អំពីបណ្តឹងទាមទារ មូលហេតុ និងសំអាងហេតុនៃការប្តឹងសុំ ហើយនិងបណ្តឹងតបហើយនិងសារណា-- និងសេចក្តីថ្លែងការណ៍តបចំពោះមុខអង្គជំនុំជម្រះ។

កិច្ចដំណើរការពិភាក្សាដេញដោល លើសំណើសុំដោះលែងជនជាប់ចោទទាំង៣នាក់ នួន ជា ខៀវ សំផន, អៀង ធីរិទ្ធ ដែលបានស្នើសុំដោយមេធាវីការពារក្តីរបស់គាត់--។

សូមអញ្ជើញលោក ស សូវាន មានការអីទៀត?

[១៥:២៦:២៧]

**លោក ស សូវាន៖**

សូមអរគុណអង្គសាលាដំបូង ខ្ញុំបាទបង្ហាញសេចក្តីឆ្លើយតបរបស់សហព្រះរាជអាជ្ញា។ ខ្ញុំសូមជូនលេខកូដ C67 ដែលថានៅក្នុងថ្ងៃ១៣ ខែកញ្ញា ឆ្នាំ២០០៨ ហ្នឹងលោកព្រះរាជអាជ្ញាលោកបកស្រាយអំពីកម្រិតបួនខែនោះ ចាប់តាំងពីថ្ងៃដែលខ្ញុំបានជម្រាបអំមិញ។ ឥឡូវខ្ញុំជូន ឯកសារនេះ C20--C65(2)។ សូមអរគុណ។

[១៥:៣៧:១១]

**ប្រធានអង្គជំនុំ៖**

កិច្ចដំណើរការពិភាក្សាដេញដោលលើសំណុំរឿងស្នើសុំដោះលែងជនជាប់ចោទទាំងបីនាក់ នួន ជា, ខៀវ សំផន, អៀង ធីរិទ្ធ ដែលបានស្នើសុំដោយមេធាវីការពារក្តីរបស់គាត់ឃើញថាដល់ទីបញ្ចប់ហើយ។ អង្គជំនុំជម្រះសាលាដំបូងបញ្ចប់សវនាការពិភាក្សាដេញដោលលើសំណើសុំឲ្យដោះលែងជនជាប់ចោទទាំងបីនាក់ត្រឹមនេះ។

អនុលោមតាមវិធាន៨២(៣) នេះវិធានផ្ទៃក្នុង អង្គជំនុំជម្រះមានរយៈពេល៣០ថ្ងៃ ដើម្បីសម្រេចលើពាក្យសុំដោះលែងទាំងនេះ។ កាលបរិច្ឆេទដំបូងបង្អស់នៃការដាក់សំណើដោះលែង គឺថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១។

សេចក្តីសម្រេចលាយលក្ខណ៍អក្សរមួយរបស់អង្គជំនុំជម្រះសាលាដំបូង នឹងចេញឆាប់ៗតាមតែអាចធ្វើទៅបាននៅក្នុងអំឡុងពេលនេះ ដែលក្នុងនោះអង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាលម្អិតអំពីទឡ្ហីករណ៍ដែលភាគីបានលើកឡើងថ្ងៃនេះ នឹងផ្តល់នូវកាលវិភាគស៊ីជម្រៅពាក់ព័ន្ធនឹងអង្គច្បាប់ដែលមានភាពសាំញ៉ាំ ស្មុគស្មាញ នៅក្នុងរឿងក្តីនេះ។

អង្គជំនុំជម្រះសាលាដំបូងសូមប្រកាសបិទសវនាការថ្ងៃនេះត្រឹមនេះ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទឈ្មោះ ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។ មន្ត្រីរដ្ឋបាលតុលាការ សូមរូតវាំងននបិទក្រោយពេលដែលអង្គជំនុំជម្រះសាលាដំបូងបានចាកចេញផុតពីបន្ទប់សវនាការ៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការបញ្ចប់នៅម៉ោង ១៥:៣៩ នាទី)*